# អត្ថបទព្រះធម៌

## ភាគ៣



ដោយ

ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណ**

ព.ស.២៥៥២ គ.ស.២០០៨

www.hoksavann.org

# ប្រវត្តិរូបសង្ខេប
# ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

ប្រសូត ថ្ងៃ១០មីនា១៩៤០ នៅឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ ប្រទេសកម្ពុជា ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណ** ជាបុត្រទី៣ក្នុងបណ្តាបុត្រទាំង៥នាក់ បិតានាម **ហុក ហៃ** មាតានាម **សុខ យឹម**។ ព្រះជន្ម១៥ឆ្នាំ បានបួសជាសាមណេរ លុះព្រះជន្ម២១ឆ្នាំ បានបំពេញឧបសម្បទាជាភិក្ខុ។ កាលប្រព្រឹត្តការណ៍ឆ្នាំ១៩៧៥ ព្រះអង្គបានភៀសខ្លួនទៅប្រទេសថៃ បន្ទាប់មកបានទៅរស់នៅទីក្រុងម៉ុងរេអាល់ ប្រទេសកាណាដា នៅថ្ងៃ២៣មេសា១៩៨១។

កាលពីកុមារភាព ព្រះអង្គបានសិក្សាអក្សរសាស្ត្រជាតិចប់បឋមសិក្សា។ ពេលចូលកាន់ផ្នួស ព្រះអង្គបានសិក្សាធម្មវិន័យទាំង៣ថ្នាក់ត្រីទោឯក បានសិក្សានៅពុទ្ធិកសិក្សា ជាប់ពុទ្ធិកបឋមសិក្សា ពុទ្ធិកមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ និងពុទ្ធិមហាវិទ្យាល័យព្រះសីហនុរាជ។ ឆ្លៀតទៅរៀនអក្សរសាស្ត្រនិងមនុស្សសាស្ត្រនៅសាកលវិទ្យាល័យភ្នំពេញ។ ក្រៅពីសិក្សាគន្ថធុរៈ ព្រះអង្គបានប្រតិបត្តិវិបស្សនាធុរៈអស់ជាច្រើនឆ្នាំ។

នៅបរទេស ព្រះអង្គបានសិក្សាបន្តជាប់អនុបណ្ឌិត (Master′s degree) ទីបំផុត ជាប់បណ្ឌិតទស្សនាវិជ្ជាផ្នែកព្រះពុទ្ធសាសនា (Doctor of Philosophy on Buddhism) នៅសាកលវិទ្យា-ល័យញូដេលលី្ល នៃប្រទេសឥណ្ឌា នៅថ្ងៃ២៨កុម្ភៈ ២០០៤។

នៅក្នុងប្រទេសក៏ដូចជានៅក្រៅប្រទេស ព្រះអង្គបានជួយសង្គមខ្មែរយ៉ាងច្រើនផ្នែកបញ្ញាស្មារតី ដោយវិធីទេសនាពន្យល់តាមមាគ៌ាព្រះពុទ្ធសាសនា។

# មាតិកាអត្ថបទ


- ប្រវត្តិរូបសង្ខេប ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណា**

| | |
|---|---|
| ១. ស្ថានសួគ៌ | ១ |
| ២. ស្ថាននរក | ៦ |
| ៣. អាណាចក្រ និង ពុទ្ធចក្រ | ១១ |
| ៤. អរិយធម៌ខ្មែរ | ១៤ |
| ៥. ឯករាជ្យតាមផ្លូវលោក និង តាមផ្លូវធម៌ | ១៧ |
| ៦. អំពីយុត្តិធម៌និងអយុត្តិធម៌តាមផ្លូវលោកនិងផ្លូវធម៌ | ១៩ |
| ៧. សេរីភាពតាមផ្លូវលោក និង តាមផ្លូវធម៌ | ២២ |
| ៨. ព្រះពុទ្ធសាសនាជាព្រលឹងខ្មែរ | ២៤ |
| ៩. វិសេសភាពនៃវប្បធម៌ខ្មែរ | ៣៣ |
| ១០. សទ្ធាក្នុងព្រះពុទ្ធសាសនា | ៣៥ |
| ១១. បុណ្យទក្ខិណានុប្បទាន | ៣៧ |
| ១២. អត្ថន័យបុណ្យចូលឆ្នាំខ្មែរ | ៤០ |
| ១៣. បុណ្យមាឃបូជា | ៤៦ |
| ១៤. បុណ្យកាន់បិណ្ឌ និង ភ្ជុំបិណ្ឌ | ៥០ |
| ១៥. បុណ្យកឋិនទាន | ៥៥ |
| ១៦. បុណ្យពិសាខបូជា | ៥៩ |


---

១៧. រឿងកូនចៀម និង ឆ្កែចចក ៦២
១៨. ប្រយ័ត្នខ្លាចាស់ចាំសីល ៦៦
១៩. ផលវិបាកនៃការឈ្លោះគ្នា ៦៩
២០. ទោសនៃការផឹកនិងជក់គ្រឿងស្រវឹង ៧១
២១. ទសពិធរាជធម៌១០យ៉ាង ៧៧
២២. ធម៌ដែលមាតាបិតាត្រូវសង្គ្រោះកូន ៨១
២៣. ធម៌ដែលបុត្រធីតាប្រុសស្រីតបគុណមាតាបិតា ៨៤
២៤. ភារកិច្ចរបស់មាតាបិតានិងបុត្រធីតានៅបរទេស ៨៧
២៥. ពុទ្ធមណ្ឌលកម្ពុជា ៩៣
- នាមអ្នកបរិច្ចាគបច្ច័យបោះពុម្ព

# ស្ថានសួគ៌

ស្ថានសួគ៌ និងអ្នកដែលទៅកើតក្នុងស្ថានសួគ៌ ដែលមាននិយាយក្នុងពុទ្ធសាសនាគឺជាតួព្រះពុទ្ធដីកាពុំមែនអដ្ឋកថាសំដែងទេ ហើយស្ថានសួគ៌និងអ្នកដែលទៅកើតក្នុងទីនោះ គឺកើតឡើងដោយកុសលកម្មដែលមនុស្សសត្វបានសាង ពុំមែនកើតពីព្រះជាម្ចាស់អង្គណាបង្កើតឡើងសម្រាប់ផ្តល់រង្វាន់ឱ្យដល់អ្នកជឿឡើយ។ ពាក្យថា សួគ៌ឬស្ថានសួគ៌នេះ ជាពាក្យខ្មែរដែលចេញពីភាសាសំស្ក្រឹតថា **សគ៌ះ** បាលីថា **សគ្គះ** ដែលចែកចេញជាពីរបទគឺ **ស** មួយបទ **គ្គ** មួយបទ។ **ស** សព្ទដើមជា **សុ** ប្រែថាល្អ ស្អាតឬងាយ ឯ **គ្គ** សព្ទដើមជា **អគ្គ** ប្រែថា ចុងកំពូលឬលើស។ រួមពាក្យទាំងពីរគឺ **ស** និង **គ្គ** ជា **សគ្គ** ប្រែថាល្អលើស ស្អាតលើស ងាយលើស គឺល្អស្អាតងាយលើសផ្លូវលោកដោយរូប សំឡេង ក្លិន រស សម្ផស្ស ទ្រព្យ យស សុខ សរសើរ អាយុពណ៌សម្បុរជាដើម។ ស្ថានសួគ៌ក៏ដូចស្ថាននរកដែរ មាននិយាយក្នុងគម្ពីរព្រះត្រៃបិដកជាគម្ពីរដ៏ធំក្នុងព្រះពុទ្ធសាសនា។ ពួកទេវតានិងស្ថានសួគ៌ត្រូវព្រះពុទ្ធសំដែងដោយផ្ទាល់ រួចអដ្ឋកថាយកមកសំដែងពង្រីកសេចក្តីបន្ថែមទៀត។ **គាមាវចរកុសល** មាននិយាយពីស្ថានសួគ៌៦ជាន់ហើយថាព្រះពុទ្ធបានយាងប្រោសពុទ្ធមាតានៅស្ថានត្រៃត្រឹង្សជាស្ថានសួគ៌ជាន់ទី២ផង។ ពុទ្ធកិច្ច៥របស់ព្រះពុទ្ធមាននិយាយថា ពេលពាក់កណ្តាលអធ្រាត្រស្ងាត់ព្រះអង្គបានដោះស្រាយប្រស្នារបស់ពពួកទេវតាទាំងឡាយដែលបានមកសាកសួរព្រះអង្គ ដូច

មានក្នុងសូត្រជាច្រើន មានមង្គលសូត្រជាដើម។ នៅក្នុងប្រសូត្រទាំងនោះក៏មានពាក្យរបស់ទេវតាដែលបញ្ចេញទស្សនៈរបស់ខ្លួនដែលហៅថា **ទេវតាសុភាសិត** ហើយព្រះពុទ្ធបានពោលកែពាក្យរបស់ទេវតាទាំងនោះផង។ មនុស្សសត្វដែលបានកើតក្នុងស្ថានសួគ៌ គឺដោយសារបានប្រព្រឹត្តតាមទេវធម៌ គឺធម៌សម្រាប់កើតជាទេវតា។ **ទេវធម៌** គឺការមានហិរិឱត្តប្បៈខ្មាសបាបខ្លាចបាប ដែលជាហេតុនាំឱ្យមានសីល៥មានការមិនសម្លាប់សត្វបំបាត់ជីវិតគេជាដើម។ នាំឱ្យមានការបម្រើមាតាបិតាឱ្យគាត់រស់នៅសុខស្រួលព្រមទាំងញុំាងគាត់ឱ្យស្ថិតនៅក្នុង **សទ្ធាសម្បទា សីលសម្បទា ចាគសម្បទា** និង **បញ្ញាសម្បទា**។ នាំឱ្យធ្វើទានរក្សាសីលគោរពសមណៈអ្នកមានគុណធម៌មានសីលគុណជាដើម។ នាំឱ្យធ្វើសាធារណប្រយោជន៍ដល់ជនដទៃដោយការអាណិតអាសូរចំពោះជនដែលមានសេចក្តីទុក្ខលំបាក។

ចំពោះសំណួរថាបើស្ថានសួគ៌មានពិតមែន តើស្ថិតនៅទីណា ព្រោះគេពុំឃើញមានក្នុងផែនទីពិភពលោកឡើយ។ តាមពិតស្ថានសួគ៌ផ្សេងពីស្ថានមនុស្សតែស្ថិតនៅលើដីជាមួយមនុស្ស។ ស្ថានសួគ៌៦ជាន់ក្នុងកាមលោក ស្ថានព្រហ្មមានរូប១៦ជាន់ជារូបព្រហ្មនិងអរូបព្រហ្ម៤ជាន់ ស្ថិតនៅទាក់ទងនឹងផែនដី។ ក៏ដូចគ្នានឹងរុក្ខទេវតា គឺទេវតាអាស្រ័យនៅនឹងដើមឈើ ភុម្មទេវតាគឺទេវតាស្ថិតនៅដីស្រែចម្ការ សុទ្ធតែស្ថិតនៅទាក់ទងនឹងផែនដី។ **ធម៌សង្គេ ភាមេ** ដែលព្រះសង្ឃសូត្រពេលចំរើនព្រះបរិត្តបកប្រែថា ទេវតាទាំង

ឡាយដែលស្ថិតនៅក្នុងស្ថានសួគ៌ ដែលជាកាមភពនិងរូបភពក្តី ភូមិទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី ពួដ៏អាកាសក្តី នៅនាកោះនិងដែននិងស្រុកក្តី នៅនាដើមព្រឹក្សានិងព្រៃញាតស្បាត ឬទីស្រែចម្ការក្តីប៉ុណ្ណេះជាដើម បញ្ជាក់ថា ទេវតាស្ថិតនៅទាក់ទងនឹងផែនដី។ មនុស្សពុំអាចមើលឃើញពួកទេវតាទាំងនោះដោយ **មំសចក្ខុ** គឺសាច់ភ្នែកធម្មតាបានឡើយព្រោះមានធាតុខុសគ្នា ប៉ុន្តែគេអាចឃើញឬដឹងបានតាមរយៈការអប់រំផ្លូវចិត្ត តាមវិធីសមថៈនិងវិបស្សនារហូតកើតទិព្វចក្ខុផ្នែកអភិញ្ញា។ ពួកទេវតាត្រូវផុតវិស័យវិទ្យាសាស្ត្រ ដែលអាចពិសោធឃើញតាមភ្នែកធម្មតា ឬតាមឧបករណ៍ **អតិសុខុមទស្សន៍**។ មានសេចក្តីបញ្ជាក់ក្នុងព្រះអភិធម្មនៃគម្ពីរព្រះពុទ្ធសាសនាថា កាមាវចរសត្វមុននឹងដាច់ខ្យល់ស្លាប់ត្រូវតោងយក **និមិត្ត៣** និមិត្តណាមួយដើម្បីចាប់បដិសន្ធិគឺ **កម្ម កម្មនិមិត្ត** និង **គតិ-និមិត្ត**។ **គតិនិមិត្ត** ផ្នែកកុសលឃើញទេវតាយករាជរថមកទទួល ឮសំឡេងតូរ្យតន្ត្រី លុះមនុស្សនោះស្លាប់ទៅក៏ទៅកើតជាទេវតា។ មានសេចក្តីដំណាលក្នុងជាតកថា ភិក្ខុមួយអង្គបានចំរើនធម៌កើតទិព្វចក្ខុ ក្រឡេកមើលលើផែនដីឃើញវិមានទេវតាស្ថិតនៅពាសពេញ កាលពុំទាន់កើតទិព្វចក្ខុគ្មានឃើញវិមានទាំងនោះសោះ។ ព្រះនាមរបស់ព្រះពុទ្ធមួយបទថា **លោកវិទូ** ប្រែថាព្រះអង្គជ្រាបច្បាស់នូវលោក គឺជ្រាបនូវមនុស្សលោកទេវលោកយមលោកគឺនរកនិងព្រហ្មលោក។ គេពុំអាចបដិសេធថាគ្មាននូវអ្វីដែលខ្លួនពុំបានឃើញនោះឡើយ ព្រោះរបស់មានពិតតាមសភាពរបស់ខ្លួនវា មានស្ថានសួគ៌ ស្ថាន

នរកជាដើម ប៉ុន្តែមើលពុំឃើញដោយខ្វះសមត្ថភាពដែលនាំឱ្យមើលឃើញ។ អ្នកខ្លះយល់ថា អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានរឹទ្ធា មានបុណ្យស័ក្តិ មានអំណាចនោះឯងជាទេវតាជាស្ថានសួគ៌។ តាមពិតក្នុងព្រះពុទ្ធសាសនាមាននិយាយអំពីពាក្យសម្មតិទេព គឺទេវតាដោយសន្មតនោះសំដៅយកអ្នកមានធម៌ក្នុងខ្លួន មានហិរិឱត្តប្បៈខ្មាសបាបខ្លាចបាបប្រព្រឹត្តទេវធម៌ជាធម៌ទេវតានៅលើផែនដីនៃមនុស្សលោក។ ស្ថានទេវតាពិតវិញបានដល់ឧប្បត្តិទេពគឺទៅកើតជាទេវតាក្នុងស្ថានសួគ៌បន្ទាប់ពីអ្នកនោះស្លាប់ទៅ។ ចំណែកអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានអំណាចបុណ្យស័ក្តិខ្ពង់ខ្ពស់ បើរបស់និងអំណាចទាំងនោះបានមកដោយអំពើទុច្ចរិតគ្មាន**ហិរិឱត្តប្បៈ**ទេ នោះពុំមែនជាអំពើប្រព្រឹត្តដើម្បីស្ថានសួគ៌ទេ គឺជាអំពើប្រព្រឹត្តទៅដើម្បីស្ថាននរកវិញទេ។ ដូច្នេះស្ថានសួគ៌ពិតជាមានសម្រាប់អ្នកសាងកុសលដែលស្ថិតនៅទាក់ទងនឹងផែនដីដែលមនុស្សពុំអាចមើលឃើញឡើយ។ ស្ថានសួគ៌៦ជាន់ខ្ពស់ទាបជាងគ្នាដោយឋានៈ គឺដោយបុណ្យកុសលដែលខ្លួនបានកសាង គឺពុំមែនខ្ពស់ទាបដោយទីកន្លែងឡើយ។ ឯ**រុក្ខទេវតា អាកាសទេវតា ភុម្មទេវតា** មានបុណ្យ ស័ក្តិតិចជាងទេវតា៦ជាន់ខាងលើនេះ។ ដូចមនុស្សបច្ចុប្បន្ននេះ អ្នកធំអ្នកតូច អ្នកមាន អ្នកក្រស្ថិតនៅលើដីដូចគ្នា ប៉ុន្តែបើនិយាយពីឋានៈ មានលក្ខណៈខុសៗគ្នា។ ចំពោះទេវតា៦ជាន់ដែលហៅថា ទេវតាក្នុងឆកាមាសួគ៌៦ជាន់ គឺទេវតាស្ថិតនៅជាន់**ចាតុម្មហារាជិកា តាវត្តិំឞ យាមា តុសិតា និម្មានរតី** និង**បរនិម្មិតវសវត្តី** ថានៅលើភ្នំព្រះសុមេរ៍នោះ មានអ្នកខ្លះបញ្ចេញទស្សនៈថា

តើស្ថានសួគ៌និងទេវតាទាំងនោះស្ថិតនៅនិងរស់នៅដូចម្តេចកើត បើទីនោះមានសុទ្ធតែទឹកកកបានអ្វីទទួលទាន។ ទស្សនៈនេះគេដោះស្រាយទេវតាដូចជាមនុស្ស តាមពិតទេវតាសោយទិព្វសម្បត្តិទាំងទីកន្លែងទាំងចំណីអាហារទាំងការសប្បាយនឹងកាមគុណពុំមែនដូចមនុស្សទេ។ បើស្ថានសួគ៌៦ជាន់ស្ថិតនៅភ្នំព្រះសុមេរ៍មែននោះ ពុំមែនស្ថិតនៅលើភ្នំតាមភ្នែកមើលឃើញនោះទេ គឺជាស្ថានមួយផ្សេងដែលភ្នែកធម្មតាមើលពុំឃើញ ដូច្នេះមិនត្រូវយកភ្នែកធម្មតាមកដោះស្រាយនូវភាពអាថ៌កំបាំងនេះឡើយ។

# ស្ថាននរក

ស្ថាននរក និងអ្នកទៅកើតក្នុងស្ថាននរក ដែលមាននិយាយក្នុងព្រះពុទ្ធសាសនាគឺកើតឡើងដោយអកុសលកម្មដែលមនុស្សសត្វបានកសាងពុំមែនកើតពីព្រះជាម្ចាស់អង្គណាបង្កើតឡើង សម្រាប់ដាក់ទណ្ឌកម្មដល់អ្នកដែលពុំជឿឡើយ។ ពាក្យថា **នរក** ចេញពីសព្ទថា **និរយៈ** ដែលប្រែថា គ្មានសេចក្តីចំរើន គ្មានសេចក្តីសុខ គឺមិនមានសេចក្តីចំរើនដោយ **លាភ យស ទ្រព្យ សុខ សរសើរ** ឡើយ មានតែសេចក្តីទុក្ខតែម្យ៉ាងពុំមានសេចក្តីសុខសូម្បីតែមួយនាទីក៏គ្មានដែរ។ ក្នុង **អបាយភូមិ៤** គឺ **នរក ប្រេត តិរច្ឆាន** និង **អសុរកាយ**។ សត្វដែលកើតក្នុងឋាននរក មានសេចក្តីទុក្ខជាងសត្វដែលកើតក្នុងភពទាំងបី។ ស្ថាននរកដែលព្រះពុទ្ធសាសនានិយាយនេះ គឺព្រះពុទ្ធបានសំដែង ពុំមែនអដ្ឋកថាបានថែងឡើយ។ ក្នុងគម្ពីរអភិធម្មដែលសំដែងឡើងដោយព្រះពុទ្ធមាននិយាយពីភពបីគឺ **កាមភព រូបភព** និង **អរូបភព** ស្ថាននរកស្ថិតក្នុងកាមភពផ្នែកអបាយភូមិបួន។ នៅក្នុង **ទេវទូតសូត្រ** និង **នេមិរាជជាតក** នៃ **គម្ពីរសុត្តន្តបិដក** ក៏មាននិយាយពីស្ថាននរក។ មួយទៀត ក្នុងព្រះសូត្រមាននិយាយថា ព្រះមោគ្គល្លានជាសាវ័កឆ្វេងរបស់ព្រះពុទ្ធជាម្ចាស់ បាននិមន្តទៅស្ថានសួគ៌និងស្ថាននរកដោយឫទ្ធិរបស់លោកព្រមទាំងបានទទួលពាក្យផ្តាំផ្ញើពីសត្វនរកដែលកំពុងរងទុក្ខវេទនាផង។

នៅក្នុងគម្ពីរអភិធម្មនិយាយថា **អកុសលចិត្ត១២** គឺ **លោភមូល៨ ទោសមូល២** និង **មោហមូល២** ជាឫសគល់អកុសលនាំឱ្យសត្វប្រព្រឹត្ត អំពើបាបកម្ម ដែលនាំឱ្យមានផលវិបាកកើតក្នុងអបាយភូមិមានកើតក្នុងនរក ជាដើម។ ការប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សេចក្តីសុខដទៃ ដូចជាបៀតបៀន ធ្វើឱ្យគេមានទុក្ខតាមផ្លូវកាយនិងតាមផ្លូវចិត្ត រហូតដល់ថ្នាក់បំបាត់ជីវិតគេ ធ្វើឱ្យគេបាត់បង់ទ្រព្យសម្បត្តិ ព្រាត់ប្រាសប្រពន្ធកូនចៅគេជាដើម នេះជា អំពើធ្លាក់នរក។ ពុទ្ធសាសនាមាននិយាយអំពីនរកជាច្រើនប្រភេទមានទោស ធ្ងន់ស្រាលទៅតាមអំពើដែលបានប្រព្រឹត្តដូចជានរក ឈ្មោះ **សញ្ជីវនរក** ប្រែថា នរកមានជីវិតរស់ឡើងដោយខ្លួនឯង។ សត្វនរកនេះត្រូវ **នាយនិរយ-បាល** ចាក់កាប់ដោយដាវលំពែងដាច់សាច់ចេញឈាមស្លាប់ភ្លាមរួចរស់ឡើង វិញ ត្រូវនាយនិរយបាលធ្វើទណ្ឌកម្មដូចមុនសោយទុក្ខវេទនាស្រែកទ្រហោយំ រហូតអស់បាបកម្ម។ ព្រះពុទ្ធសំដែងថា សត្វធ្លាក់នរកនេះដោយទោសសម្លាប់ មនុស្សលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ លួចប្រពន្ធកូនអ្នកដទៃ រំលោភឬកេង ប្រវ័ញ្ចយកដីអ្នកដទៃ។ នរកនេះមានអាយុ៥០០ឆ្នាំទិព្វ។ ចំនួន៩លានឆ្នាំ មនុស្សបានតែ១យប់១ថ្ងៃរបស់នរកនេះ។ **នរក** មួយទៀតឈ្មោះ **លោហ-កុម្ភីនរក** ប្រែថា នរកខ្ទះទង់ដែង។ សត្វនរកនេះត្រូវរងទុក្ខនៅក្នុងខ្ទះ ទង់ដែងដ៏ក្តៅលិចចុះទៅដល់បាតខ្ទះ៣ម៉ឺនឆ្នាំ ផុសឡើង៣ម៉ឺនឆ្នាំ លិចចុះ អណ្តែងឡើងតែយ៉ាងនេះ សោយទុក្ខរហូតដល់អស់បាបកម្ម។ ទោសធ្លាក់ នរកនេះដោយការធ្វើបាបអ្នកមានគុណ ប្រមាថអ្នកមានសីល រំលោភយក

ប្រពន្ធកូនអ្នកដទៃខាងផ្លូវ**កាមគុណ** ដូចរឿង **សេដ្ឋីបុត្រ**៤នាក់ប្រព្រឹត្តធ្វើអំពើបែបនេះបានធ្លាក់ទៅសោយទុក្ខក្នុងលោហកុម្ភីនរកនេះ។ នរកមួយទៀតឈ្មោះ **សិម្ពលីនរក** ប្រែថានរកដើមរកា។ ដើមរកានេះមានបន្លាច្រូងច្រាងស្រួចមុតដូចកាំបិតកោរ។ នាយនិរយបាលដេញចាប់សត្វនរកឱ្យឡើងដើមរកានេះ ត្រូវបន្លាមុតចេញឈាមសស្រាក់ស្រែកទ្រហោយំថែមទាំងមានឆ្កាតដេញចឹកពីក្រោយថែមទៀត។ រងទុក្ខវេទនាតែយ៉ាងនេះរាល់ថ្ងៃរហូតអស់បាបកម្ម។ ក្នុងអដ្ឋកថានិយាយថា នាយនិរយបាលដែលធ្វើទារុណកម្មដល់សត្វនរកកើតឡើងដោយអំពើបាបរបស់សត្វ។ ទោសនៃការធ្លាក់នរកនេះ ដោយការប្រព្រឹត្តខុសកាមេសុមិច្ឆាចារៈ គឺប្រព្រឹត្តកន្លងប្រវេណីកូនប្រពន្ធប្តីអ្នកដទៃគឺលួចប្រពន្ធ លួចប្តី លួចកូនក្រមុំអ្នកដទៃ។ ពាក្យខ្មែរ ក៏បានពោលថា កុំលួចប្រពន្ធកូនអ្នកដទៃប្រយ័ត្នឡើងដើមរកាដែក។

តាមការអធិប្បាយមកនេះបញ្ជាក់ថា គម្ពីរព្រះពុទ្ធសាសនាបាននិយាយថាស្ថាននរកមានពិតមែន ហើយតួព្រះពុទ្ធដីកាបានសំដែងថែមទៀត តើស្ថាននរកនោះមានទីតាំងនៅកន្លែងណា? ហេតុអ្វីបានជាវិទ្យាសាស្ត្រស្រាវជ្រាវមិនឃើញ? ខ្លះថានរកស្ថិតនៅក្នុងខ្លួនយើងនេះឯង គឺបើយើងកើតទុក្ខឈ្មោះថាយើងចុះនរកហើយ។ ខ្លះថាអ្នកធ្លាក់នរកសំដៅយកអ្នកធ្វើអំពើអាក្រក់ធ្ងន់ៗ ឈ្មោះថាគេចុះនរកហើយ។ ទាំងអស់នេះជាពាក្យដែលគេនិយាយអំពីនរកក្នុងជីវិតមនុស្សក្នុងស្ថានមនុស្ស ពុំបានបង្ហាញត្រង់ណាជាស្ថាននរកពិតប្រាកដទេ។ សៀវភៅខ្លះសរសេរនរកស្ថិតនៅឆ្ងាយពីផែនដីរាប់ពាន់រាប់

ម៉ឺនយោជន៍។ អ្នកខ្លះបើនិយាយពីស្ថាននរក គេចង្អុលចុះក្រោម គឺនរកនៅក្រោមដី ។ សេចក្តីពិត នរកមានស្ថានមួយសម្រាប់សត្វនរកពិតប្រាកដ ពុំមែនស្ថិតនៅក្រោមដីឬនៅឆ្ងាយពីផែនដីឡើយ ដោយសម្អាងរឿងរ៉ាវក្នុងសុត្តន្តបិដក ជាពិសេសរឿងនៅក្នុងគម្ពីរធម្មបទជាច្រើនកន្លែងដែលនិយាយជាច្រើនដងថា ព្រះពុទ្ធបានធ្វើព្រះភ័ក្ត្រញញឹម សាវ័ករបស់ព្រះអង្គបានទូលសួរអំពីការញញឹមនេះ ព្រះអង្គបានសំដែងអំពីសត្វនរកឬប្រេតដែលព្រះអង្គបានទតឃើញ នៅលើផែនដីមានស្ថិតនៅលើភ្នំគិជ្ឈកូដជាដើម។ ពេលខ្លះព្រះមោគ្គល្លាននិងព្រះសារីបុត្របានទតឃើញ។ ដោយមានសាក្សី ទើបព្រះពុទ្ធជាម្ចាស់សំដែងអំពីបុព្វកម្មនៃសត្វប្រេតនិងសត្វនរកនោះ។ ដូច្នេះបញ្ជាក់ថា សត្វនរកនិងសត្វប្រេតស្ថិតនៅលើផែនដីនេះឯង ប៉ុន្តែជាធាតុមួយផ្សេងក្រៅពីធាតុមនុស្សដែលគេពុំអាចមើលឃើញឡើយ។ សូម្បីយកអតិសុខុមទស្សន៍របស់អ្នកវិទ្យាសាស្ត្រ ដែលអាចពង្រីកបានរាប់រយពាន់ដងក៏ដោយក៏ពុំអាចមើលសត្វនរកនិងស្ថាននរកឃើញឡើយ។ គឺហួសវិស័យពីក្រុមវិទ្យាសាស្ត្រផ្នែក**សម្ភារនិយម**ដែលអាចមើលឃើញដោយមំសចក្ខុគឺដោយភ្នែកធម្មតាឬដោយប្រដាប់សម្រាប់ឆ្លុះឡើយ។ ពុទ្ធសាសនាបានពោលថា គេអាចមើលឃើញសត្វនរកនិងសត្វប្រេតបានដោយការអប់រំចិត្ត រហូតកើតឈានចិត្តជាអប្បនាចិត្ត ហើយចំរើនឱ្យកើតអភិញ្ញាជាទិព្វចក្ខុទើបឃើញអបាយសត្វទាំងនោះ។ មួយផ្នែកទៀត ក្នុងអភិធម្មផ្នែក**កាមាវចរចិត្ត** ខាង**អកុសល** និយាយថា មនុស្សសត្វដែលសាងបាបកម្មពេលជិតដាច់ខ្យល់ស្លាប់មាននិមិត្ត៣ប្រភេទបាន

កើតឡើង និមិត្តបែបណាមួយឱ្យអ្នកជិតស្លាប់នោះឃើញគឺ **កម្ម កម្មនិមិត្ត** និង **គតិនិមិត្ត**។ ចំពោះគតិនិមិត្តផ្នែកអកុសលឃើញនាយនិរយបាលមកចាប់ចងខ្លួនហើយអូសទាញទៅជាសញ្ញាថា អ្នកនោះស្លាប់ទៅពិតជាទៅសោយទុក្ខក្នុងនរក។ អាថិកំបាំងក្នុងលោកមានច្រើនយ៉ាងណាស់ ដែលក្រុមវិទ្យាសាស្ត្រកំពុងរុករក ឬពុំអាចរកឃើញមានស្ថាននរកនេះជាដើម។ ប៉ុន្តែក្រុមវិទ្យាសាស្ត្រទាំងនោះនៅរក្សាគោលគំនិតមួយថា គេពុំអាចបដិសេធនូវអ្វីមួយដែលគេពុំអាចរកឃើញនោះទេ គេទុកជាកម្មវត្ថុសម្រាប់ស្រាវជ្រាវតទៅទៀត។ អ្នកធ្វើបាបកម្មក្នុងលោកនេះ ត្រូវទទួលទោសទណ្ឌកម្មក្នុងបច្ចុប្បន្នដោយច្បាប់រដ្ឋនិងស្លាប់ទៅនឹងធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិមាននរកជាដើម។

# អាណាចក្រ និង ពុទ្ធចក្រ

## ១- <u>អាណាចក្រ</u> :

ពាក្យថា **អាណាចក្រ** កាត់ជាពីរបទ គឺ **អាណា** មួយបទ និង **ចក្រ** មួយបទ។ ពាក្យថា **អាណា** ជាភាសាបាលី ភាសាសំស្រ្កឹតថា **អាជ្ញា** ប្រែថា អំណាច ច្បាប់បញ្ញត្តិ ការគ្រប់គ្រង ការបង្គាប់បញ្ជា។ ពាក្យថា **ចក្រ** សរសេរជា **ចក្រ** ក៏បានសរសេរជា **ចក្ក** ក៏បានប្រែថា ការប្រព្រឹត្តទៅ ឬការអនុវត្តច្បាប់។ រួមពាក្យទាំងពីរ **អាណាចក្រ** ប្រែថា អំណាចនៃការគ្រប់គ្រងប្រទេសនីមួយៗដែលប្រព្រឹត្តទៅដូចកង់រទេះដែលវិលទៅមុខ។ បានដល់ច្បាប់សម្រាប់ប្រទេសដូចជាច្បាប់កំពូលរបស់រដ្ឋ គឺច្បាប់រដ្ឋធម្មនុញ្ញដែលទាំងប្រជាពលរដ្ឋ ទាំងអ្នករដ្ឋការត្រូវអនុវត្តទាំងអស់គ្នា ដើម្បីសុខសន្តិភាពនិងការចំរើនលូតលាស់នៃប្រទេសរបស់ខ្លួន ។

## ២-<u>ពុទ្ធចក្រ</u> :

ពាក្យថា **ពុទ្ធចក្រ** ប្រែថា ការប្រព្រឹត្តនៃធម៌របស់ព្រះពុទ្ធ ដូចជាព្រះពុទ្ធសំដែងធម៌ទេសនាជាដំបូងប្រោសភិក្ខុ៥អង្គ ដែលហៅថា **ធម្មចក្កប្បវត្តនសូត្រ** គឺព្រះសូត្រដែលព្រះអង្គបានឱ្យប្រព្រឹត្តទៅហើយគឺបានសំដែងហើយក្នុងលោក។ ធម៌នោះបានដល់អរិយសច្ច៤ មានទុក្ខសច្ចជាដើម ដែលជាធម៌ចេញចាកទុក្ខហើយគ្មានតាបសឥសីណារកឃើញនិងសំដែងឡើយ។ មគ្គសច្ចនៅក្នុងអរិយសច្ច៤ គឺមគ្គប្រកបដោយអង្គ៨ បានដល់ **សីល សមាធិ**

**បញ្ញា** ជាមាគ៌ាដ៏បរិសុទ្ធឆ្ពោះទៅរកសុខសន្តិភាពនៃមនុស្សជាតិក្នុងសង្គម ជាពិសេសចំពោះសព្វសត្វទាំងអស់ក្នុងភពបី ដើម្បីរំដោះខ្លួនចេញចាកទុក្ខមានជាតិទុក្ខជាដើម បានដល់ព្រះនិព្វាន ។

## ៣-ទំនាក់ទំនងផ្លូវអាណាចក្រ និង ពុទ្ធចក្រ :

ចំពោះប្រទេសកម្ពុជា ផ្លូវអាណាចក្រត្រូវមានពុទ្ធចក្រដើរទៅជាមួយព្រោះថា ច្រើនសតវត្សរ៍មកហើយ ព្រះពុទ្ធសាសនាជាមាគ៌ាដែលប្រជាពលរដ្ឋខ្មែរបានអនុវត្តតាមតែងបានទទួលសុខសាន្ត។ ប៉ុន្តែមានសម័យខ្លះ អ្នកដឹកនាំខ្មែរបានដើរខុសពីមាគ៌ារបស់ព្រះពុទ្ធ បានធ្វើឱ្យប្រជាពលរដ្ឋខ្មែរបែកបាក់សាមគ្គីគ្នា ឆ្លៀតឱកាសនេះ បរទេសបានចូលមករំលោភឈ្លានពានប្រទេសកម្ពុជារហូតទឹកដីរួញតូចដូចសព្វថ្ងៃ។ ព្រះពុទ្ធសាសនាជាមាគ៌ាបង្រួបបង្រួមជាតិខ្មែរជាមូលដ្ឋាននៃអត្តសញ្ញាណជាតិខ្មែរ ព្រោះព្រះពុទ្ធសាសនាបានបង្រៀនឱ្យមនុស្សស្រឡាញ់រាប់អានជាតិខ្លួន និងមនុស្សក្នុងសកលលោក ដោយព្រះធម៌ប្រៀនប្រដៅទាំងឡាយមានមេត្តាករុណា ដែលមាននៅក្នុងព្រហ្មវិហារធម៌ជាដើម។ **ផ្លូវអាណាចក្របានដាក់អាជ្ញាឱ្យមនុស្សខ្លាចច្បាប់កុំឱ្យប្រព្រឹត្តខុស**។ ឯ**ផ្លូវពុទ្ធចក្របង្រៀនមនុស្សឱ្យខ្លាចកំហុសខ្លួនឯង**។ បានសេចក្តីថា កំហុសដែលគេបានប្រព្រឹត្តទោះបីគេពុំបានដឹងបានឮក៏ដោយ ក៏ខ្លួនឯងដឹងឮខ្លួនឯងសៅហ្មងចិត្តខ្លួនឯង បានទទួលទោសខ្លួនឯងរួចទៅហើយ។ ផ្លូវពុទ្ធចក្រទុកដូចជាអ្នកកាច់ចង្កូតផ្លូវអាណាចក្រគឺនាវាកម្ពុជាឱ្យដើរទៅតាមផ្លូវសច្ចធម៌ យុត្តិធម៌ និងផ្លូវសន្តិភាព។ ព្រះពុទ្ធសាសនា ជាឱសថសំរាប់រំលត់ភ្លើង

សង្គ្រាម ជំរុញឱ្យមានសីលធម៌ដោយការមិនបៀតបៀនគ្នា ដែលជាប្រភពសន្តិភាពពិភពលោក ជាពិសេសប្រទេសកម្ពុជា។ ផ្លូវពុទ្ធចក្រជាជំនួយមួយសំខាន់ណាស់សម្រាប់ជួយឧបត្ថម្ភផ្លូវអាណាចក្រ។ ឧទាហរណ៍ ការបង្កើតប៉ូលីសទាហាន ដើម្បីរក្សាសន្តិសុខនិងរបៀបរៀបរយសណ្តាប់ធ្នាប់ក្នុងសង្គម ព្រោះមានមនុស្សបៀតបៀនគ្នារំលោភលើគ្នា។ ចុះបើទាំងអស់គ្នា ខ្លាចអំពើបាបពុំប្រព្រឹត្តធ្វើអំពើទាំងនោះតាមផ្លូវពុទ្ធចក្រនោះ ប៉ូលីសទាហានមិនជាការចាំបាច់ដែលត្រូវបង្កើតឱ្យមានទេ។ ផ្លូវអាណាចក្រមនុស្សប្រព្រឹត្តរំលោភច្បាប់របស់ប្រទេសអាចរួចចាកទោសបើគេពុំដឹង។ ប៉ុន្តែផ្លូវពុទ្ធចក្រវិញនឹងគេចពុំរួចឡើយ ព្រោះអ្នកធ្វើអំពើបាបដឹងខ្លួនឯងនឹងទទួលផលបាបក្នុងពេលណាមួយពុំខានឡើយ ទោះបីពេលនេះបានបិទបាំងបានមួយពេលក៏ដោយ។ អំពើផ្តាច់ការរបស់អ្នកកាន់អំណាចរដ្ឋក្នុងការរំលោភបៀតបៀនរហូតមានការកាប់សម្លាប់ប្រជាពលរដ្ឋរបស់ខ្លួនពុំកើតមានឡើយ បើគេគោរពតាមផ្លូវពុទ្ធចក្រ។ ក៏ដូចគ្នានឹងអំពើពុករលួយគ្រប់យ៉ាងរបស់អ្នករដ្ឋការគ្រប់តំណែង ដែលពិភពលោកគ្រប់ប្រទេសកំពុងកំចាត់ក៏ពុំកើតមានដែរ ព្រោះអនុវត្តតាមធម៌ព្រះពុទ្ធផ្លូវពុទ្ធចក្រ។ ដូច្នេះពុទ្ធចក្រទុកដូចជាទីប្រឹក្សាឬជាប្រទីបដ៏ភ្លឺថ្លាសម្រាប់បំភ្លឺផ្លូវអាណាចក្រឱ្យធ្វើដំណើរឆ្ពោះទៅរកសន្តិភាព និងវឌ្ឍនភាពនៃសង្គមខ្មែរ។ បើប្រទេសកម្ពុជាបានអនុវត្តបានត្រឹមត្រូវនូវធម៌ព្រះពុទ្ធ នោះអំពើហិង្សាគ្រប់យ៉ាងរវាងបុគ្គលនិងបុគ្គលក្តី រវាងអ្នកនយោបាយក្តី ដែលកម្ពុជាកំពុងជួបប្រទះនេះនឹងពុំកើតមានឡើយ។

# អរិយធម៌ខ្មែរ

ពាក្យថា **អរិយធម៌** ប្រែថា ធម៌ ឬសភាពប្រសើរខ្ពង់ខ្ពស់ ថ្លៃថ្នូររុងរឿង។ បានដល់ការរស់នៅប្រសើរ គឺការរៀបចំជីវភាពប្រកបដោយសេចក្តីសុខចំរើនក្នុងសង្គមមនុស្ស។ **អរិយធម៌** សម្គាល់នូវការចំរើនលូតលាស់នៃមនុស្សជាតិ។ គ្រប់ជនជាតិទាំងអស់សុទ្ធមានអរិយធម៌រៀងៗខ្លួន ប្លែកតែត្រង់អរិយធម៌នៃជនជាតិខ្លះបានចំរើនលូតលាស់ អរិយធម៌ជនជាតិខ្លះនៅទន់ខ្សោយប៉ុណ្ណោះ។ អរិយធម៌នេះហើយដែលចែកជាវប្បធម៌និងសង្គមធម៌។

ពាក្យថា **វប្បធម៌** ប្រែថា ធម៌ ឬសភាពដែលបណ្តុះបណ្តាលឱ្យចំរើនលូតលាស់ខាងចំណេះវិជ្ជា សីលធម៌ ដូចជាជំនឿ សាសនា ភាសា អក្សរ ការសិក្សាអប់រំ អក្សរសាស្ត្រ សិល្បៈ ទំនៀមទម្លាប់ប្រពៃណីជាដើម។

ពាក្យថា **សង្គមធម៌** បានដល់ការរីកចំរើនលូតលាស់ខាងសម្ភារៈ ដូចដូចជាទីលំនៅ ប្រដាប់ប្រដាប្រើប្រាស់ ចំណីអាហារបរិភោគ សម្លៀកបំពាក់ ថ្នាំកែរោគ ប្រដាប់បច្ចេកទេស សេដ្ឋកិច្ចជាដើម ។

**ទំនាក់ទំនងរវាងវប្បធម៌** និង **សង្គមធម៌:** វប្បធម៌និងសង្គមធម៌ត្រូវមានទំនាក់ទំនងគ្នាជាដរាប ទើបធ្វើឱ្យសង្គមបានសុខសន្តិភាពនឹងចំរើនលូតលាស់។ វប្បធម៌បានចំរើនមនុស្សមានចំណេះដឹង ចេះគិតគូរពិចារណាបង្កើតសម្ភារៈគ្រប់យ៉ាងសម្រួលដល់ការរស់នៅរបស់សង្គមមនុស្សឱ្យកាន់តែប្រសើរឡើង។ នយោបាយក៏ចាត់ចូលក្នុងផ្នែកវប្បធម៌ គឺបើវប្បធម៌បានចាក់

គ្រឹះយ៉ាងមាំ បណ្តុះគំនិតជាតិនិយមឱ្យបានខ្លាំងក្លា ផ្លូវនយោបាយក៏មានថាម-ពលខ្លាំងដែរ។ បើសង្គមធម៌មិនបានចំរើនលូតលាស់ខាងសម្ភារៈ គេអាចយកជាឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងការសិក្សាអប់រំ និងពិសោធរកបច្ចេកទេសថ្មីៗទៀត។ គេអាចយកបច្ចេកទេសទំនើបទៅប្រើប្រាស់ក្នុងការផ្សព្វផ្សាយនូវសាសនា សិល្បៈវប្បធម៌ដែលបណ្តុះគំនិតប្រាជ្ញាស្មារតី និងសីលធម៌ឱ្យកើតកាន់តែរហ័សឡើង ដូចជាមធ្យោបាយផ្សាយតាមវិទ្យុ ទូរទស្សន៍ សៀវភៅទស្សនាវដ្តី ភាពយន្តជាដើម។ ដូច្នេះវប្បធម៌និងសង្គមធម៌ត្រូវមានទំនាក់ទំនងគ្នាទៅវិញទៅមក គឺវប្បធម៌ផ្តល់សេចក្តីសុខឱ្យដល់សង្គមមនុស្សតាមផ្លូវចិត្ត និងជាគ្រឿងបំភ្លឺដល់ការស្វែងរកផ្លូវសម្ភារៈ ឯសង្គមធម៌ផ្តល់សេចក្តីសុខឱ្យដល់សង្គមមនុស្សតាមផ្លូវសម្ភារៈ។ បើចំរើនតែម្ខាងខ្លាំងពេក នឹងមានគ្រោះថ្នាក់ដល់សង្គមមនុស្ស ដូចជាសម្ភារៈលឿនខ្លាំង ចំណែកផ្លូវសីលធម៌ ពុំសូវចំរើនសង្គមមនុស្សនឹងបៀតបៀនគ្នារំលោភលើគ្នា នឹងធ្វើឱ្យពិភពលោកធ្វើដំណើរឆ្ពោះទៅរកចម្បាំងដែលផ្ទុយពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលព្រះអង្គត្រាស់ថា សេចក្តីសុខសន្តិភាពកើតឡើងពីចិត្តស្ងប់ពុំបៀតបៀនគ្នា។ វិទ្យាសាស្ត្រមួយផ្នែកចំរើនឡើង ដើម្បីធ្វើឱ្យសង្គមមនុស្សបានសុខដូចជាការលូតលាស់ ខាងទីលំនៅ ប្រដាប់ប្រដាប្រើប្រាស់ បច្ចេកទេសពេទ្យ យានយន្តគ្រប់ប្រភេទសម្រាប់ធ្វើដំណើរជាដើម។ ប៉ុន្តែការចំរើនលូតលាស់របស់វិទ្យាសាស្ត្រមួយផ្នែកទៀត គឺធ្វើឱ្យលោកវិនាសដូចជាការបង្កើតសាស្ត្រាវុធគ្រប់ផ្នែក ការបង្កើតគ្រាប់មីនកប់ក្នុងដីរហូតដល់ការបង្កើតគ្រាប់បែកបរមាណូនៃ

ប្រទេសខ្លះ បើគ្មានវប្បធម៌ផ្អែកសីលធម៌ជួយទប់ទេនឹងយកទៅប្រើធ្វើឱ្យលោកវិនាស ។

# ឯករាជ្យតាមផ្លូវលោក និង តាមផ្លូវធម៌

## ១. ឯករាជ្យតាមផ្លូវលោក :

ពាក្យថា **ឯករាជ្យ** តាមផ្លូវលោក បើតាមវចនានុក្រមខ្មែរសរសេរថា ភាពនៃរដ្ឋឬប្រទេស ដែលមានសិទ្ធិ និងសេរីភាពពេញបរិបូណ៌ក្នុងការគ្រប់គ្រងខ្លួនឯង ពុំចំណុះប្រទេសដទៃ គឺគ្រប់គ្រងឯករាជ្យការពារឯករាជ្យខ្លួនឯងបាន។ បើយកន័យខ្លះ តាមវចនានុក្រមពួកបស្ចឹមប្រទេសថា សេរីភាពរបស់រដ្ឋនីមួយៗ គ្រប់គ្រងឬត្រួតត្រាដោយខ្លួនឯង ឈរលើខ្លួនឯងបាន មិនចំណុះប្រទេសដទៃ។ ការឱ្យន័យតាមប្រភពផ្សេងៗគ្នា ប៉ុន្តែមាននយ័ដូចគ្នាគឺ ពាក្យថា **ឯករាជ្យ** បានដល់ប្រទេសដែលមានអំណាចខ្លួនឯង គ្មានប្រទេសណាធ្វើអាណានិគមនិយមត្រួតត្រាលើខ្លួន ។

## ២. ឯករាជ្យតាមផ្លូវធម៌ :

ពាក្យថា **ឯករាជ្យ** តាមន័យផ្លូវធម៌របស់ព្រះពុទ្ធសាសនា បានដល់ការផ្ដាច់ចិត្តចេញពីឧបក្កិលេសជាចិត្តឯករាជ្យ ព្រោះឧបក្កិលេសនេះ ដឹកនាំចិត្តឱ្យធ្វើអំពើអាក្រក់ផ្សេងៗទៅតាមសភាពរបស់ឧបក្កិលេស ដែលមានឥទ្ធិពលមានអំណាចទៅលើផ្លូវចិត្ត។ ចិត្តដែលបានឯករាជ្យ តម្កល់ក្នុងកុសលធម៌មកពីគ្មានឧបក្កិលេសត្រួតត្រាទៅលើចិត្ត ។ ចិត្តនៅមានកិលេសតណ្ហាបញ្ជាពីលើពុំឈ្មោះថា ចិត្តមានឯករាជ្យទេ គឺចិត្តជាខ្ញុំនៃតណ្ហា ចិត្តនៅក្រោមបង្គាប់នៃតណ្ហា។ ចិត្តដែលបានទទួលឯករាជ្យពេញបរិបូរ គឺលោកុត្តរចិត្តជាចិត្តរំដោះ

ខ្លួនចេញពីតណ្ហារហូតបានសម្រេចព្រះនិព្វាន ។

**៣- ទំនាក់ទំនងឯករាជ្យតាមផ្លូវលោក និង ផ្លូវធម៌ :**

ប្រវត្តិសាស្ត្របញ្ជាក់ថា ការបាត់បង់**ឯករាជ្យ**រហូតបាត់បង់ទឹកដី ឬទឹកដីរួមតូចកាលពីជំនាន់ដើម រហូតមកដល់ពេលពេលបច្ចុប្បន្ននៃប្រទេសខ្លះ ដូចប្រទេសកម្ពុជាជាដើម មកអំពីការគ្រប់គ្រងប្រទេសធ្វេសប្រហែសពុំបានប្រុងប្រយ័ត្ន កើតមានការបែកបាក់សាមគ្គីផ្ទៃក្នុងពុំមានឯកភាពជាតិ ។ ការបែកបាក់ផ្ទៃក្នុងជាកត្តាចម្បងដែលនាំឱ្យបាត់បង់ **ឯករាជ្យ** ឬ**អធិបតេយ្យជាតិ** ហើយជាកត្តានាំឱ្យអស់ទឹកដីរបស់ខ្លួន ព្រោះបរទេសដែលអាចលូកដៃចូលមកឈ្លានពានប្រទេសណាមួយបានភាគច្រើនដោយការបែកបាក់ផ្ទៃក្នុង។ ក្នុងន័យនេះទំនាក់ទំនងផ្លូវធម៌ គឺអ្នកដឹកនាំមានមហិច្ឆតាផ្ទាល់ខ្លួនដោយអំពើអយុត្តិធម៌ ធ្វើឱ្យប្រជាពលរដ្ឋក្តៅក្រហាយប្រឆាំងតបវិញ អ្នកមានអំណាចគ្មានសមត្ថភាពទប់ទល់បាន ក៏ទៅពឹងបរទេសឱ្យមកជួយបង្ក្រាប។ បើការបង្ក្រាបនោះមានជ័យជំនះ ហើយបើប្រទេសដែលជួយច្បាំងនោះមានមហិច្ឆតាផង ក៏ធ្វើអាណានិគមនិយមលើប្រទេសខ្លួនទៅ **ឯករាជ្យ** ក៏ត្រូវបាត់បង់។ នេះមកអំពីអ្នកដឹកនាំប្រទេសប្រាសចាកផ្លូវធម៌ បណ្តោយឱ្យមហិច្ឆតា ឬតណ្ហារបស់ខ្លួនដឹកនាំរហូតបាត់បង់ **ឯករាជ្យ** ។ បើគោរពសិទ្ធិរបស់ប្រជាពលរដ្ឋឱ្យបានពេញលេញនោះ សាមគ្គីនឹងកើតមាន ហើយបរទេស ទោះបីមានមហិច្ឆតាខ្លាំងក្លាយ៉ាងណា ក៏ពុំហ៊ានចូលឈ្លានប្រទេសខ្លួនបាន **ឯករាជ្យ** ក៏ស្ថិតនៅគង់វង់។

# អំពីយុត្តិធម៌ និង អយុត្តិធម៌ តាមផ្លូវលោក និង ផ្លូវធម៌

## អំពីអំពើយុត្តិធម៌ និង អយុត្តិធម៌ តាមផ្លូវលោក ៖

ពាក្យថា **យុត្តិធម៌** តាមទស្សនៈរបស់ក្រុមនីតិវិទ្យាក្នុងផ្លូវអាណាចក្រឱ្យន័យថា ភាពត្រឹមការសមហេតុសមផល ។ ឯពាក្យថា **អយុត្តិធម៌** មានន័យផ្ទុយគ្នា គឺភាពពុំត្រឹមត្រូវ ភាពពុំសមហេតុផល ។ ភាពត្រឹមត្រូវ និងពុំត្រឹមត្រូវនេះ តាមផ្លូវលោក គឺយោលទៅតាមក្របខណ្ឌនៃច្បាប់របស់ប្រទេសនីមួយៗ និងរបស់អង្គការសហប្រជាជាតិដែលគេបានអនុម័តយកមកប្រើ ។ បានសេចក្តីថា យុត្តិធមិ ឬពុំយុត្តិធមិ ស្រេចតែការព្រមព្រៀងគ្នា សន្មតយកមកអនុវត្ត ។ ក្នុងន័យនេះហើយ បានជាគេជ្រើសរើសអ្នកចេះច្បាប់អ្នកមិនប្រកបដោយអគតិធមិមកសរសេរព្រាងច្បាប់ជាដំបូងដើម្បីឱ្យអត្ថន័យច្បាប់បានល្អ មានយុត្តិធមិបន្ទាប់មកទើបសភាធម្មនុញ្ញ យកសេចក្តីព្រាងនេះទៅពិភាក្សាអនុ-ម័ត ។ លុះសភាធម្មនុញ្ញអនុម័តហើយ គេត្រូវដាក់ឱ្យប្រជាពលរដ្ឋបញ្ចេញមតិលើច្បាប់នោះមួយជាន់ទៀត ។ នេះនិយាយអំពីរបៀបចាត់ចែងនៃប្រទេសដែលកាន់របបប្រជាធិបតេយ្យសេរី ។ បើច្បាប់នោះតាក់តែងឡើងដោយជនឬក្រុមផ្តាច់ការ ឬលទ្ធិកុម្មុយនិស្ត ច្បាប់នោះពុំមានយុត្តិធមិឡើយ គឺគេតាក់តែងច្បាប់ទៅតាមអំពើផ្តាច់ការរបស់គេ ។ នេះនិយាយអំពីយុត្តិធមិ ឬពុំយុត្តិធមិក្នុងការតាក់តែងច្បាប់ និងអនុម័តច្បាប់ ។ ឯការបកស្រាយច្បាប់ដើម្បី

អនុវត្តឱ្យបានត្រឹមត្រូវ គឺជាភារៈរបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញដែលបានជ្រើសតាំងពីអ្នកមានចំណេះខាងច្បាប់ ហើយជាស្ថាប័នឯករាជ្យត្រូវបកស្រាយ ឯអ្នកមានអំណាចដែលកាន់នីតិប្រតិបត្តិ មានសិទ្ធិស្នើច្បាប់ តែគ្មានសិទ្ធិបកស្រាយច្បាប់ឡើយ។

**អំពើយុត្តិធម៌ និង អយុត្តិធម៌តាមផ្លូវធម៌ :**

**ច្បាប់យុត្តិធម៌** និង **អយុត្តិធម៌** ដែលសំដែងឡើងដោយ **ព្រះសម្មាសម្ពុទ្ធ** ជាច្បាប់មានសច្ចធម៌ ជាច្បាប់ធម្មជាតិសាកល។ ពាក្យថា **យុត្តិធម៌** ស្មើគ្នានឹងពាក្យថាអំពើបុណ្យ អំពើជាកុសល និង អំពើសុចរិត។ ឯពាក្យថា អយុត្តិធម៌ ស្មើគ្នានឹងពាក្យថាអំពើបាប អំពើជាអកុសល និង អំពើទុច្ចរិត។ ពាក្យទាំងពីរក្រុមនេះផ្ទុយគ្នា ប្រើផ្លាស់ប្តូរគ្នាបាន។ យុត្តិធម៌ ប្រែថាប្រកបដោយធម៌ បានដល់បុណ្យ កុសល និង សុចរិត, ឯអយុត្តិធម៌ ប្រែថា មិនប្រកបដោយធម៌ បានដល់បាបអកុសលនិងទុច្ចរិត។ បើនិយាយដល់ជម្រៅព្រះពុទ្ធសាសនា មូលហេតុដែលនាំឱ្យប្រព្រឹត្តអំពើយុត្តិធម៌ និងអយុត្តិធម៌ គឺបើចិត្តបរិសុទ្ធប្រាចាក **លោភៈ ទោសៈ មោហៈ** នាំឱ្យប្រព្រឹត្តអំពើយុត្តិធម៌ បើចិត្តសៅហ្មងប្រកបដោយ **លោភៈ ទោសៈ មោហៈ** នាំឱ្យប្រព្រឹត្តអំពើអយុត្តិធម៌។ យុត្តិធម៌ជាគុណធម៌ដ៏ខ្ពង់ខ្ពស់នាំឱ្យអ្នកប្រព្រឹត្តបានសុខ ឯអយុត្តិធម៌ជាគុណវិបត្តិនាំឱ្យអ្នកប្រព្រឹត្តបានទុក្ខ។ ច្បាប់យុត្តិធម៌ និងអយុត្តិធម៌ដែលរកឃើញដោយព្រះពុទ្ធនេះ គឺជាសច្ចសាកលត្រូវគ្រប់ពេល

វេលា និងគ្រប់ទីកន្លែង ផ្ទុយគ្នាពីច្បាប់ផ្លូវលោកដែលបញ្ញត្តិឡើងតាមការស្រុះស្រួលគ្នាអនុម័ត ពុំអាចមានយុត្តិធម៌ដូចច្បាប់ផ្លូវធម៌ឡើយ។ បើគេប្រព្រឹត្តល្អដោយ កាយ វាចា ចិត្ត ឈ្មោះថាគេប្រព្រឹត្តអំពើយុត្តិធម៌។ ដូច្នេះបានសេចក្តីថា អំពើយុត្តិធម៌ និងអយុត្តិធម៌នេះ ពុំមែនសំដៅយកតែចៅក្រមកាត់សេចក្តីឡើយ គឺសំដៅយកអំពើល្អនិងអាក្រក់ជាទូទៅ។ ព្រះធម៌របស់ព្រះពុទ្ធសាសនាមានយុត្តិធម៌ណាស់ ជាច្បាប់ធម្មជាតិសាកល គឺបុគ្គលបានសុខទុក្ខចំរើន ឬវិនាសស្របតាមអំពើរបស់ខ្លួន។ បានសេចក្តីថា អំពើកម្មរបស់ខ្លួនជាអ្នកកាត់សេចក្តីជាស្វ័យប្រវត្តិ។ ព្រះពុទ្ធសាសនាសំដែងអំពីទំនាក់ទំនងរវាងហេតុនិងផល, គឺហេតុយ៉ាងណា ផលក៏យ៉ាងនេះដែរ។ បានសេចក្តីថា បើហេតុល្អ បានផលល្អ បើហេតុអាក្រក់ បានផលអាក្រក់។ ព្រះពុទ្ធសាសនាបានបញ្ជាក់ទៀតថា ហេតុល្អនិងហេតុអាក្រក់នោះ ទោះបីប្រព្រឹត្តដោយបិទបាំងមិនឱ្យអ្នកដទៃដឹង ក៏នៅតែឱ្យផលនៅពេលណាមួយពុំខានឡើយ។ តាមពិតសេចក្តីបរិសុទ្ធនិងសៅហ្មង គឺខ្លួនឯងដឹងរួចហើយ នេះហើយជាការសំខាន់ពុំមែនស្ថិតនៅលើអ្នកដទៃដឹង ឬពុំដឹងឡើយ។

# សេរីភាពតាមផ្លូវលោក និង តាមផ្លូវធម៌

## ១. អំពីសេរីភាពតាមផ្លូវលោក :

ពាក្យថា **សេរីភាព** ដែលភាសាបារាំងថា *Liberté* អង់គ្លេសថា *Liberty* ឬ *Freedom,* តាមផ្លូវលោកដែលគេឱ្យន័យហើយថា គឺជាសិទ្ធិឬអំណាចច្បាប់សង្គម។ សង្គមមនុស្សជាសង្គមមានបញ្ញាជាងសង្គមសត្វតិរច្ឆាន ចេះរៀបចំសង្គមរបស់ខ្លួនឱ្យបានលូតលាស់ចំរើន និងប្រកបដោយសីលធម៌ថ្លៃថ្នូរ ដូចជាការចេះគោរពសិទ្ធិគ្នាទៅវិញទៅមកជាដើម។ សេរីភាពរបស់បុគ្គលមួយរូបៗដែលអង្គការសហប្រជាជាតិ និងប្រទេសកាន់របបប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្សបានចែងក្នុងច្បាប់ថា បុគ្គលគ្រប់រូបមានសេរីភាពខាងការនិយាយ បញ្ចេញមតិ មានសេរីភាពខាងការតាំងទីលំនៅ មានសេរីភាពខាងការធ្វើនយោបាយ មានសេរីភាពខាងការសរសេរសារព័ត៌មាន មានសេរីភាពខាងការធ្វើបាតុកម្មជាដើម។ ច្បាប់សេរីភាពនេះបានចែងជាគោលការណ៍ថា ជនគ្រប់រូបអាចធ្វើអ្វីបានទាំងអស់ កុំឱ្យតែប៉ះពាល់ដល់សិទ្ធិអ្នកដទៃ។

## ២. អំពីសេរីភាពតាមផ្លូវធម៌ :

សេរីភាពតាមផ្លូវព្រះធម៌នៃព្រះពុទ្ធសាសនា គឺការរំដោះខ្លួនចេញពីកិលេសតណ្ហា ព្រោះកិលេសតណ្ហានេះរុំព័ទ្ធចិត្តគំនិតរបស់មនុស្សមិនឱ្យចិត្តគំនិតមានសិទ្ធិសេរីភាព។ មនុស្សសត្វជាខ្ញុំនៃតណ្ហា តណ្ហាដឹកនាំមនុស្សសត្វឱ្យ

ធ្វើល្អខ្លះអាក្រក់ខ្លះ។ តណ្ហាមានកង្វះខាតជានិច្ច មិនចេះគ្រប់គ្រាន់ឡើយ ប្រៀបដូចទឹកសមុទ្រមិនចេះពេញប្រៀបដោយទឹក។ បុគ្គលខ្លះក្នុងលោកនេះ ដោយសារកិលេសតណ្ហារបស់ខ្លួនខ្លាំងបានប្រព្រឹត្តធ្វើអំពើដ៏អាក្រក់ទៅលើជនដទៃដើម្បីបំពេញតណ្ហារបស់ខ្លួន។ បើបុគ្គលមិនលុះក្នុងអំណាចតណ្ហាដឹកនាំ មានបញ្ញាស្មារតីត្រួតត្រាលើចិត្តរបស់ខ្លួនបាន បុគ្គលនោះ ចាត់ជាអ្នកជាបាន ទទួលសេរីភាព ពុំស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់កិលេសតណ្ហាឡើយ។

ប្រភេទនៃសេរីភាពទាំងពីរនេះមានលក្ខណៈខុសគ្នាខ្លះ គឺសេរីភាពផ្លូវលោក និយាយពីការរំដោះខ្លួនចេញពីការជិះជាន់ ការកៀបសង្កត់ ការបំបិទសេរីភាពរបស់ជនដទៃ របស់ប្រទេសដទៃ ជាពិសេសរបស់រដ្ឋាភិបាលរបស់ខ្លួន។ ការចំរើនលូតលាស់គ្រប់យ៉ាង មានការចំរើនលូតលាស់ខាងវិទ្យាសាស្ត្រជាដើម ដោយសារមនុស្សមានសេរីភាពបំពេញកិច្ចការដោយគ្មានអ្វីមករារាំង។ ប៉ុន្តែសេរីភាពរបស់ផ្លូវលោក ពុំបាននិយាយអំពីការរំដោះខ្លួនចេញពីកិលេសតណ្ហាឡើយ។ ចំណែកសេរីភាពតាមផ្លូវធម៌មិបាននិយាយទាំងពីរ គឺត្រូវរំដោះខ្លួនចេញពីការបំបិទសេរីភាពផង ចេញពីកិលេសតណ្ហាដែលស្ថិតនៅក្នុងចិត្តរបស់ខ្លួនផង ដោយវិធីអប់រំចិត្តក្នុងផ្លូវសមថៈ និងវិបស្សនា។ តួយ៉ាងដូចជាព្រះពុទ្ធ ដោយសារព្រះអង្គមានសិទ្ធិសេរីភាពក្នុងការស្វែងរកព្រះធម៌ ទើបព្រះអង្គបានត្រាស់ជាព្រះពុទ្ធ។

# ព្រះពុទ្ធសាសនាជាព្រលឹងខ្មែរ

ព្រះពុទ្ធសាសនាសំដែងថា មនុស្សជាសត្វពិសេសមានប្រាជ្ញាជាងសត្វតិរច្ឆាន ព្រោះមនុស្សមានសក្តានុភាពទាំងកាយសម្បទានិងចិត្តគំនិតអាចបណ្តុះបណ្តាលឱ្យចំរើនលូតលាស់ខាងវប្បធម៌និងសង្គមធម៌។ តាមព្រះពុទ្ធសាសនា ការចំរើនលូតលាស់នេះអាស្រ័យហេតុពីរប្រការគឺអាស្រ័យឧបនិស្ស័យដែលបានកសាងល្អពីមុន និងការព្យាយាមត្រូវក្នុងបច្ចុប្បន្ន (**បុព្វេកត បុញ្ញតា អត្តសម្មាបណិធិ**)។

មនុស្សជាតិកើតមកជាដំបូងពុំទាន់ចេះដឹងអ្វីនៅឡើយ ពួកគេរស់នៅជាមួយធម្មជាតិ តាមរអាងភ្នំ ក្រោមម្លប់ព្រៃព្រឹក្សា ចាប់សត្វបានហែកចែកគ្នាស៊ីជាដើម។ ក្នុងផ្លូវជំនឿ គេជឿថាវត្ថុធម្មជាតិ មានចិត្ត មានវិញ្ញាណដូចជាខ្យល់ព្យុះ រន្ទះបាញ់ ភ្នំភ្លើងផ្ទុះ ផែនដីញ័រ ពេលដែលបាតុភូតទាំងនេះកើតឡើង ពួកគេមានការភ័យតក់ស្លុត ទើបបន់ស្រន់កុំឱ្យធម្មជាតិទាំងនោះកើតឡើង។ ជំនឿបែបនេះហៅថា ជំនឿព្រលឹងនិយម *(Animism)*។ ពេលក្រោយមក គំនិតមានការវិវត្ត ពួកគេជឿថាវត្ថុធម្មជាតិទាំងនោះគ្មានចិត្តវិញ្ញាណទេ តែវត្ថុធម្មជាតិទាំងនោះមានទេវៈមួយរូបៗថែរក្សា ដែលអាចបណ្តាលឱ្យមានបាតុភូតបែបណាមួយស្រេចតែទេវៈទាំងនោះបញ្ជាឱ្យកើតឡើង ដូច្នេះហើយបានជាដើម្បីកំចាត់បង់កុំឱ្យគ្រោះមហន្តរាយទាំងនោះកើតឡើង ពួកគេបន់ស្រន់ទេវៈទាំងនោះ។ ក្រោយមកទៀត មានគំនិតថ្មីបញ្ចេញ

ទស្សនៈថា មានទេវៈដ៏ធំមួយបង្កើតលោកដែលហៅថា ព្រះអាទិទេព បានដល់ព្រះព្រហ្ម។ និយាយកាត់ឱ្យខ្លីនៅពេលនោះ **ព្រះពុទ្ធព្រះបរមគ្រូព្រះសមណគោត្តម** បានត្រាស់ដឹងឡើងក្នុងលោក។ ព្រះអង្គមានព្រះនាមមួយក្នុងពុទ្ធគុណគឺ **លោកវិទូ** ប្រែថា ព្រះអង្គជ្រាបច្បាស់នូវលោក។ ព្រះអង្គជ្រាបច្បាស់នូវសង្ខារលោក គឺវត្ថុគ្មានវិញ្ញាណទាំងអស់ គ្មានអ្នកណាបង្កើតទេ គឺ កើតឡើងឯងតាមច្បាប់ធម្មជាតិ *(Natural Law)*។ ព្រះអង្គជ្រាបនូវសត្វលោក គឺរបស់មានវិញ្ញាណទាំងអស់ ដូចមនុស្សសត្វកើតឡើង និងស្លាប់ទៅវិញតាមអំពើល្អអាក្រក់របស់ខ្លួន។ ដូច្នេះព្រះពុទ្ធបានត្រាស់ដឹងឡើងបដិសេធព្រះបង្កើតលោក។ បន្ទាប់មកទៀត មានសាសនាធំពីរទៀតប្រកាសថា ព្រះរបស់គេបង្កើតលោកដែរ។

ចំពោះជំនឿខ្មែរជំនាន់ដើមក៏ដូចជាជំនឿមនុស្សដើមដែលទើបកកើតទីកដីដែរ គឺជឿព្រលឹងនិយម បន្ទាប់មកជឿថា មានទេវៈថែរក្សាវត្ថុធម្ម-ជាតិទាំងនោះ រហូតជឿខ្មោចបិសាចអារក្សអ្នកតា ចេះឱ្យសុខទុក្ខដល់មនុស្ស។ ទោះបីមានជំនឿក្នុងព្រះពុទ្ធសាសនាដែលប្រៀនប្រដៅឱ្យជឿកម្មផលរបស់ខ្លួនហើយក៏ដោយ ប្រជាពលរដ្ឋខ្មែរនៅមានជំនឿលើខ្មោចបិសាចអារក្សអ្នកតាដែរ។ កាលពីជំនាន់មុន នៅតាមសសរកន្លោងនៃផ្ទះខ្មែរនីមួយៗមានធ្វើច្រំមួយអំពីឫស្សីរាងដូចសាជីដាក់សំរាប់ឱ្យខ្មោចស្នាក់នៅ ហៅថាជំនាងផ្ទះសំរាប់ឱ្យថែរក្សាផ្ទះ។ នៅតាមផ្ទះមានរៀបចំអាសនៈបូជាខ្មោចសំបួជួរហើយមានធ្វើពិធីលៀងអារក្ខតាមផ្ទះខ្លះរៀងរាល់ឆ្នាំដើម្បីសុំសេចក្ដីសុខ

សប្បាយ។ នៅតាមភូមិមានធ្វើកូនខ្ទមតូចមួយ ហៅថាផ្ទះព្រះភូមិ។ នៅតាមស្រុកនីមួយៗ មានធ្វើកូនខ្ទមមួយហៅថាខ្ទមអ្នកតាចាស់ស្រុក នៅពេលចៅហ្វាយស្រុកមកកាន់ការថ្មីតែងតែធ្វើពិធីឡើងអ្នកតាចាស់ស្រុក ដើម្បីខ្លួនមកកាន់ការបានសុខសប្បាយ និងរីកចំរើនក្នុងស្រុក។ ឯរានទេវតាមានធ្វើ តែផ្ទះខ្មែរខ្លះពុំមានធ្វើទូទៅឡើយ។ នៅពេលមានអាសន្នអន់ក្រមានវិបត្តិគ្រោះថ្នាក់ មានជម្ងឺដម្កាត់ជាដើមបៀតបៀន ជនជាតិខ្មែរតែងតែមានការបន់ស្រន់ខ្មោចបិសាច ខ្មោចដូនខ្មោចតា រហូតបន់ព្រះសំពះទេវតា សូមឱ្យវិបត្តិទាំងនោះបាត់បង់ទៅ។

មកដល់ចុងសតវត្សរ៍ទី២០ ដើមសតវត្សរ៍ទី២១ នៅពេលដែលពុទ្ធិកសិក្សា គឺការសិក្សាខាងព្រះពុទ្ធសាសនាបានលូតលាស់ចំរើន យល់កាន់តែច្បាស់នូវធម្មវិន័យរបស់ព្រះពុទ្ធជាម្ចាស់អំពីហេតុផល និងកម្មផល ទន្ទឹមគ្នានឹងវិទ្យាសាស្ត្រក៏កាន់តែចំរើនលូតលាស់ ជាពិសេសលូតលាស់ខាងវិជ្ជាពេទ្យផ្នែករោគសាស្ត្រ ជំនឿប្រជាពលរដ្ឋខ្មែរខាងការបន់ស្រន់សុំសេចក្ដីសុខលើខ្មោចបិសាចត្រូវចុះខ្សោយ កន្លែងខ្លះបាត់ទាំងស្រុងតែម្តង។ គេឈប់ធ្វើជំនាងផ្ទះខ្ទមព្រះភូមិ ខ្ទមអ្នកតាចាស់ស្រុកជាទូទៅដូចមុនទៀតហើយ។ ពេលមានវិបត្តិគេតែងតែដោះស្រាយតាមយថាហេតុស្របតាមន័យរបស់ព្រះពុទ្ធសាស-នា ហើយបើជម្ងឺដម្កាត់បៀតបៀនគេតែងតែទៅព្យាបាលនៅមន្ទីរពេទ្យ។

ដោយឥទ្ធិពលព្រះពុទ្ធសាសនាខ្មែរជឿបុណ្យជឿបាប ស្គាល់គុណស្គាល់ទោស ជនជាតិខ្មែរនៅជាមួយគ្នាក្នុងសង្គមប្រកបដោយសុខដុមរមនា។

ខ្មែរមានចិត្តស្មោះត្រង់នឹងគ្នា កាលពីជំនាន់ដើមដូចនៅពេលខ្ចីប្រាក់កាសឬវត្ថុផ្សេងៗពីអ្នកណាម្នាក់ សន្យាគ្នាដោយមាត់ទទេ ពុំដែលធ្វើសំបុត្រស្នាមឱ្យអាជ្ញាធរខ្មែរដឹងឮឡើយ ប៉ុន្តែពុំដែលបោកប្រាសគ្នាឡើយ ដល់ពេលកំណត់តែងតែយកទៅសងគេវិញ ព្រោះមានជំនឿថា បើមិនយកទៅសងគេទេជាតិក្រោយនឹងទៅបំរើគេ៥០០ជាតិ។ ស្រូវបោកបែនហើយទុកចោលក្នុងលាន ពុំដែលមានចោរលួចឡើយ។ កូនចៅស្ត្រីៗ ទោះបីដើរទៅណាក៏ពុំឮថាមានបុរសចាប់រំលោភផ្លូវភេទឡើយ ។ល។ សម័យក្រោយមកដោយវប្បធម៌ដទៃទៀតជ្រៀតចូល ធ្វើឱ្យឧត្តមគតិល្អដូចពោលមកនេះ ត្រូវបានបាត់បង់ខ្លះដោយមានខ្មែរខ្លះប្រព្រឹត្តប្រាសចាកគន្លងធម៌។

តើព្រលឹងខ្មែរ ជំនឿខ្មែរ ទំនោរខ្មែរឬមនោសញ្ចេតនាខ្មែរនៅត្រង់ណា? អ្នកស្រាវជ្រាវខាងប្រវត្តិវិទ្យាបានជ្រាបហើយថា ជនជាតិខ្មែរចាប់ពីបានរស់នៅជាមួយគ្នាជាសង្គម តែងមានមនោសញ្ចេតនាគោរពមេជាងគោរពបា (គោរពម្តាយជាងគោរពឪពុក) ដូចមានពាក្យថា "សូវស្លាប់បាកុំឱ្យតែស្លាប់មេ"។ ប្រុសត្រូវតែទៅស្ដីដណ្ដឹងស្ត្រី មានឪពុកក្មេក ម្ដាយក្មេកខ្លះតម្រូវឱ្យខាងប្រុសសង់ផ្ទះឱ្យខាងស្ត្រីមួយ តម្រូវឱ្យខាងប្រុសទៅបំរើខាងស្ត្រី២ឆ្នាំសិនដើម្បីមើលចិត្តគំនិត ឫកពា មារយាទ ខាងប្រុស។ គំនិតខ្មែរដើមជឿខ្មោចបិសាចអារក្ស អ្នកតា ខ្មោចដូនតា ដោយយល់ថាអាចផ្ដល់ទុក្ខឱ្យដល់ខ្លួន ប៉ុន្តែទស្សនៈខ្មែរពុំជឿព្រះបង្កើតលោកឡើយ។ ដូច្នេះហើយបានជាពេលដែលសាសនាព្រាហ្មណ៍ និងព្រះពុទ្ធសាសនា ចូលមកប្រទេសកម្ពុជា

ខ្មែរបាន សម្រេចច្រានចោលសាសនាព្រាហ្មណ៍ ដែលថាព្រះព្រហ្មបង្កើតលោក ហើយបានទទួលព្រះពុទ្ធសាសនាយកមកគោរពប្រតិបត្តិក្នុងជីវភាពប្រចាំថ្ងៃ រហូតមកដល់សព្វថ្ងៃនេះ ដោយឃើញថាព្រះពុទ្ធសាសនាជាញាណទស្សនវិជ្ជាដ៏ខ្ពង់ខ្ពស់ មានសច្ចភាព ជាមាគ៌ាធ្វើឱ្យអ្នកប្រតិបត្តិតាមដល់នូវការរំលត់ទុក្ខ។ បន្ទាប់ពីបានទទួលប្រតិបត្តិតាមធម៌របស់ព្រះពុទ្ធមក ជំនឿទៅលើខ្មោចបិសាចឬវត្ថុស័ក្តិសិទ្ធិខាងក្រៅ ថាឱ្យសុខឱ្យទុក្ខដល់ខ្លួនត្រូវបានលះបង់។ ធម៌របស់ព្រះពុទ្ធបានរលាយចូលក្នុងចិត្តគំនិតរបស់ប្រជាពលរដ្ឋខ្មែរ។ ដូច្នេះគំនិតនិងជំនឿថា វត្ថុស័ក្តិសិទ្ធិខាងក្រៅមានខ្មោចបិសាចនិងទេវតាជាដើម ថាឱ្យសុខឱ្យទុក្ខជាជំនឿពុំសមហេតុផល មានតែជំនឿក្នុងព្រះពុទ្ធសាសនាទេជាជំនឿប្រកបដោយហេតុផលមានសច្ចភាពពិតប្រាកដ។

អំពីព្រលឹង និងជំនឿខ្មែរ តាមសំដីលោក **កេង-វ៉ាន់សាក់** គាត់ឱ្យតម្លៃតែទៅលើអ្វីដែលជាខ្មែរសុទ្ធ ដូចជាជំនឿខ្មែរទៅលើអារក្ស អ្នកតារបៀបបន់ស្រន់ ជាលក្ខណៈមនុស្សជំនាន់ដើម ដែលអរិយធម៌ពុំទាន់លូតលាស់នៅឡើយ។ ចំណែកសាសនាព្រាហ្មណ៍ និងព្រះពុទ្ធសាសនា គាត់ថានេះជារបស់ឥណ្ឌា ពុំមែនរបស់ខ្មែរទេ។ ដូចបានពោលមកខាងដើមហើយថា មនុស្សកើតមកពុំមែនចេះឯងទេ គឺចេះមកពីការពិសោធន៍អស់រយៈពេលដ៏យូរ ឆ្លងតាមការសិក្សាពីគ្នាទៅវិញទៅមក ទោះបីមនុស្សមានឧបនិស្ស័យពីជាតិមុនមកខ្លាំងយ៉ាងណាក៏ដោយ។ យ៉ាងណាមិញ មនុស្សជំនាន់ដើមពេលកកើតទឹកដី ពុំទាន់ចេះដឹងអ្វីទេ គេរស់នៅរបៀបសត្វតិរច្ឆាន គ្មានផ្ទះសម្បែងចាប់សត្វ

បរិភោគជាអាហារ ។ មនោសញ្ចេតនារបស់មនុស្សគ្រប់រូបមិនថាមនុស្សសម័យវិទ្យាសាស្ត្រនេះទេ ទោះបីមនុស្សជំនាន់ដើមបំផុត ពេលដែលវិទ្យា-សាស្ត្រពុំទាន់លូតលាស់ ក៏មានចិត្តចង់បានសុខចង់បានការលូតលាស់ចំរើនដូចគ្នា តែមធ្យោបាយទៅរកសុខចំរើននោះ មនុស្សជំនាន់ដើមពុំទាន់មានបញ្ញារកឃើញ ដូច្នេះហើយបានជាម្តងជឿថាវត្ថុធម្មជាតិមានព្រលឹងវិញ្ញាណ ម្តងបដិសេធ ហើយជឿថាមានទេវៈនៅគ្រប់គ្រងធម្មជាតិទាំងនោះ ។ ទាំងអស់នេះជាជំនឿខុសពុំត្រឹមត្រូវតាមការពិតឡើយ ។ លុះឃើញព្រះពុទ្ធសាសនា ជាសាសនាសំដែងធម៌ពិត ជាធម៌ដឹកនាំមនុស្សឱ្យចេញចាកទុក្ខពិតមែន ជនជាតិខ្មែរក៏លះបង់ជំ-នឿខុសទាំងនោះ ហើយបែរមកជឿព្រះពុទ្ធសាសនាវិញ ។ ដូច្នេះ ជំនឿខ្មែរបានផ្លាស់ប្តូរមករកជំនឿត្រូវវិញ ។ ត្រង់ន័យនេះហើយបានជាមានពាក្យក្នុងពុទ្ធសាសនាមួយកន្លែងពោលថា **ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា** ប្រែថា មនុស្សទាំងឡាយមានចំនួនច្រើន កាលដែលភ័យគ្របសង្កត់ហើយ តែងយកភ្នំទាំងឡាយខ្លះ ព្រៃទាំងឡាយខ្លះ អារាមនិងដើមឈើដែលជាចេតិយទាំងឡាយខ្លះ ជាទីពឹង ។ បន្តសេចក្តីទៀតថា ទីពឹងនុ៎ះឯងមិនមែនជាទីពឹងដ៏ក្សេមក្សាន្ត ដ៏ឧត្តម បុគ្គលមិនអាចរួចស្រឡះចាកទុក្ខទាំងពួងព្រោះអាស្រ័យទីពឹងនុ៎ះទេ តែបុគ្គលណាបានដល់នូវ **ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ** ជាទីពឹងទីរលឹក ឃើញនូវអរិយសច្ច៤រហូតសម្រេចព្រះនិព្វាន ទើបជាទីពឹងដ៏ប្រសើរ បុគ្គលរមែងរួចចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះឯង ។ ដូច្នេះព្រះពុទ្ធរក

ឃើញសច្ចធម៌មិនសំរាប់រំដោះទុក្ខមនុស្សសត្វទូទៅ ជាពិសេសសំរាប់ជនជាតិខ្មែរ ពុំមែនសំរាប់តែជនជាតិឥណ្ឌាទេ គឺជាព្រះពុទ្ធរបស់ជនជាតិខ្មែរ។ ប្រៀបដូច អ្នកប្រាជ្ញវិទ្យាសាស្ត្រគ្រប់ផ្នែកដែលរកឃើញអ្វីមួយ ពុំមែនសំរាប់តែជនជាតិ របស់អ្នករកឃើញនោះទេ គឺសំរាប់មនុស្សលោកទូទៅក្នុងសាកលលោកដែល យកវិជ្ជានោះទៅប្រើប្រាស់ដើម្បីសេចក្ដីសុខចំរើនក្នុងប្រទេសរៀងៗខ្លួន។ យ៉ាងណាមិញ ព្រះពុទ្ធត្រាស់ដឹងឡើងពុំមែនសំរាប់តែជនជាតិណាមួយឡើយ គឺសំរាប់គ្រប់ជនជាតិទាំងអស់ក្នុងលោក ព្រោះសច្ចធម៌ដែលព្រះអង្គត្រាស់ដឹង នេះ ជាសច្ចធម៌ទូទៅ ត្រូវគ្រប់កន្លែង ត្រូវគ្រប់ពេល ព្រោះជាច្បាប់ធម្មជាតិ។ ដូចពាក្យថា ហេតុបែបណា ផលបែបនោះ ឬអំពើបែបណា ផលបែបនោះ។ ជនជាតិអាមេរិកដើម ជនជាតិកាណាដាដើម ជនជាតិបារាំងដើម ជាជនជាតិ ពុំទាន់មានអារ្យធម៌ខ្ពស់នៅឡើយ ឯជនជាតិដែលធ្វើឱ្យប្រទេសទាំងបីនេះ លូតលាស់ គឺជនជាតិចំណូលថ្មីដែលមានអារ្យធម៌ និងបញ្ញាខ្ពស់។ លោក **កេង_វ៉ាន់សាក់** បើរើកញែកប្រវត្តិសាស្ត្រខ្មែរដើម្បីការចេះដឹងពុំជាការ អ្វីទេ ឱ្យតែរើកញែកនោះត្រឹមត្រូវទៅតាមការពិត ប៉ុន្តែបើរើកញែកដើម្បី បំណងទាញខ្មែរឱ្យវិលត្រឡប់ទៅរកជំនឿណាមួយប្រាសចាកការពិត គ្មាន ប្រយោជន៍ដល់សង្គមខ្មែរនោះ ពុំគួរប្រព្រឹត្តធ្វើទេ ព្រោះបញ្ញាស្មារតីជាតិខ្មែរ បានវិវត្តមកដល់កម្រិតខ្ពស់ហើយ។

ព្រលឹងវិញ្ញាណ និងជំនឿខ្មែរ បានស្ថិតនៅជាមួយព្រះពុទ្ធសាសនា រាប់ពាន់ឆ្នាំមកហើយ។ ពិតមែនតែពុទ្ធសាសនាសំដែងអំពីសច្ចធម៌មានលក្ខ-

ណៈជាសាកលទូទៅ ប៉ុន្តែខ្មែរយកព្រះពុទ្ធសាសនាមកប្រតិបត្តិស្របទៅតាមលក្ខណៈប្រពៃណីនៃជាតិខ្លួន។ បានសេចក្តីថា ប្រតិបត្តិតាមធម៌ព្រះពុទ្ធយកធម៌ព្រះពុទ្ធជាគោល ប៉ុន្តែប្រតិបត្តិទៅតាមលក្ខណៈជាតិខ្មែរ ដែលផ្សេងពីលក្ខណៈថៃ ភូមា និង ស្រីលង្កា។ ដូចជាព្រះពុទ្ធរូបបៀបខ្មែរ ពិធីកម្មបុណ្យទានរបៀបខ្មែរ ថ្វាយបង្គំព្រះពុទ្ធរបៀបខ្មែរ វិបស្សនារបៀបខ្មែរជាដើម។ ដោយជនជាតិខ្មែរមានប្រវត្តិសាស្ត្ររបស់ខ្លួនជាងពីរពាន់ឆ្នាំហើយធ្លាប់ជាមហាអំណាចនៅសម័យមហានគរផង ជាភ័ស្តុតាងបញ្ជាក់ថា ជនជាតិខ្មែរមានអារ្យធម៌ខ្ពស់ ហើយបានជះឥទ្ធិពលរបស់ខ្លួនមកលើប្រទេសជិតខាងផង ប៉ុន្តែសម័យក្រោយមក រាជាណាចក្រនេះបានត្រូវចុះខ្សោយដោយបរទេសឈ្លានពាន ធ្វើឱ្យខ្មែរនិងខ្មែរបែកសាមគ្គីគ្នា។ ទោះបីព្រឹត្តិការណ៍របស់ប្រទេសប្រែប្រួលយ៉ាងណាក៏ដោយ ក៏ព្រះពុទ្ធសាសនាតែងស្ថិតនៅយ៉ាងរឹងមាំក្នុងចិត្តគំនិតខ្មែរជានិច្ច ភ័ស្តុតាងពួកខ្មែរក្រហមបានបំបាត់ព្រះពុទ្ធសាសនាដល់ឫសគល់ ប៉ុន្តែពួកគេពុំអាចបំបាត់ព្រះពុទ្ធសាសនាក្នុងចិត្តគំនិតខ្មែរបានឡើយ។ ដូច្នេះបញ្ជាក់ថា ព្រះពុទ្ធសាសនាជាព្រលឹង ឬជាអត្តសញ្ញាណរបស់ខ្មែរ ដែលគេពុំអាចញែកចេញឱ្យដាច់ពីគ្នារវាងព្រះពុទ្ធសាសនា និងជនជាតិខ្មែរបានឡើយ។ សីលធម៌ធ្លាក់ចុះដោយបញ្ហាសង្គម ដោយវប្បធម៌អាសអាភាសរបស់បរទេសចូលមកជ្រៀតជ្រែកក្នុងចំណោមយុវវ័យ។ បើគេចាប់អប់រំសីលធម៌ព្រះពុទ្ធសាសនាឱ្យខ្លាំងក្លា នោះសីលធម៌មានកម្រិតខ្ពស់នឹងកើតឡើងវិញ ហើយអំពើ

ហឹង្សានឹងត្រូវថយចុះ ជនជាតិខ្មែរនឹងរស់នៅប្រកបដោយ មេត្តា ករុណា តាមធម៌ព្រះពុទ្ធពុំខានឡើយ ។

# វិសេសភាពនៃវប្បធម៌ខ្មែរ

វប្បធម៌ខ្មែរមានវិសេសភាពរបស់ខ្លួន តាំងពីសម័យបុរាណមក ទោះបីផ្នែកខ្លះបានយកពីវប្បធម៌ឥណ្ឌាក៏ដោយ ប៉ុន្តែបានយកមកច្នៃរចនាឱ្យមានលក្ខណៈជាខ្មែរទាំងអស់។ ខ្មែរមានវិចារណញ្ញាណជឿកម្មផល ជឿហេតុល្អហេតុអាក្រក់ ពេលព្រះពុទ្ធសាសនាចូលមកមានលក្ខណៈ ដូចជាអត្តសញ្ញាណរបស់ខ្លួន ខ្មែរក៏ទទួលយកភ្លាម ។ អក្សរសិល្ប៍រឿងរាមកេរ្តិ៍ខ្មែរ ដែលដកស្រង់ចេញពីរឿងរាមាយណៈឥណ្ឌា ដែលលើកតម្កើងព្រះរាមជាតួអង្គអាទិទេពនោះ ក្នុងរាមកេរ្តិ៍ខ្មែរបានទាញព្រះរាមទៅជាមនុស្សសាមញ្ញធម្មតា ចេះយំចេះសោក មានការព្រាត់ប្រាស់គ្នា រហូតព្រះរាមចូលកោដិបញ្ជោតនាងសីតា។ សិល្បៈក្បាច់ក្បូរផ្សេងៗ មានលក្ខណៈខុសគ្នាពីសិល្បៈឥណ្ឌា ដូចជាប្រាសាទអង្គរវត្តជារចនាបថរបស់ខ្មែរសុទ្ធសាធ។ ផ្នែករបាំក៏ដូចគ្នា របាំឥណ្ឌាកាយវិការរាំមានចលនាទាំងដៃទាំងជើង ទាំងដងខ្លួន ទាំងក្បាល ដែលមានលក្ខណៈផ្ទុយគ្នាពីរបាំខ្មែរដែលប្រើកាយវិការតែដៃនិងជើង ឯដងខ្លួននៅត្រង់ជានិច្ច សូម្បីថៃខំចម្លងធ្វើតាមក៏មិនដូចខ្មែរដែរ។ ភាសាខ្មែរពុំប្រើវិភត្តិ ហើយពុំមានសម្លេងឡើងចុះទៅតាមសញ្ញាដាក់លើពាក្យដែលនាំឱ្យខូចន័យទេ។ ខ្មែរមានភាសាខ្មែរសុទ្ធរួចមកហើយ ក្រោយមកទើបមានកំចីពាក្យខ្លះពីភាសាបាលីនិងសំស្ក្រឹត ប៉ុន្តែយកមកច្នៃឱ្យទៅជាភាសា និងសម្លេងខ្មែរដោយវិភត្តិចោល។ ចំណែកអក្សរខ្មែរដែលមានរូបរាងសមរម្យដូចសព្វថ្ងៃនេះ បានត្រូវ

កែសម្រួលជាង១០ដងមកហើយ។ ដូច្នេះខ្មែរមានវប្បធម៌របស់ខ្លួនពិតប្រាកដរួចមកហើយ ទើបមានវប្បធម៌ដទៃចូលមកជាខាងក្រោយ ប៉ុន្តែបានច្នៃជាតួបនីយកម្មឱ្យស្របតាមលក្ខណៈរបស់ខ្លួន។ លោក B.P. Groslia និង លោក Maurice Glaize បានបញ្ជាក់ថា ជនជាតិខ្មែរមានអរិយធម៌របស់ខ្លួនមុនរួចស្រេចទៅហើយ ទើបមានឥទ្ធិពលឥណ្ឌាជាខាងក្រោយ។ អក្សរសិល្ប៍ខ្មែរទោះបីរឿងខ្លះយកសត្វធ្វើជាតួអង្គក៏ដោយ ក៏មានន័យតំណាងសង្គមមនុស្សទុកជាកញ្ចក់សម្រាប់ឆ្លុះមើលព្រឹត្តិការណ៍ក្នុងសម័យកាលនីមួយៗ។ មូលដ្ឋានរបស់វប្បធម៌ខ្មែរ គឺព្រះពុទ្ធសាសនាថេរវាទដែលរក្សាទុកនូវព្រះពុទ្ធដីកាមិនកែប្រែ ជាសាសនាស្របតាមចិត្តគំនិតរបស់ខ្មែរ។ ដូច្នេះខ្មែរមានឯកភាពខាងភាសា ឯកភាពខាងអក្សរ ឯកភាពខាងសាសនា ហើយទឹកដីខ្មែរសម្បូរសម្បត្តិធម្មជាតិ ដែលអាចច្នៃឱ្យប្រទេសចំរើនលូតលាស់បាន គួរខ្មែរគ្រប់រូបនាំគ្នារក្សាមតិក ដ៏មានតម្លៃរបស់ដូនតានេះឱ្យគង់វង់កុំឱ្យបាត់បង់។

# សទ្ធាក្នុងព្រះពុទ្ធសាសនា

ពាក្យថា **សទ្ធា** ជាភាសាបាលីមកពី **សំ** បុព្វបទ និង **ធា** ធាតុ។ **ធា** ប្រែថា ទ្រទ្រង់ **សំ** ប្រែថា **ព្រម** រួមពាក្យទាំងពីរបទ **សទ្ធា**តាមសព្ទដើម ទ្រទ្រង់ព្រម។ បានសេចក្តីថា ទ្រទ្រង់នូវសេចក្តីពិតដែលគេបានពិចារណា ឬពិសោធឃើញ ឧទាហរណ៍គណិតវិទ្យា ពីរបូកនឹងពីរត្រូវជាបួន ឃើញហេតុផលពិតនេះ ក៏ទ្រទ្រង់ពាក្យនោះទៅ។ តាមគីមីវិទ្យា ២ **អ៊ីដ្រូសែនបូក** និង ១ **អុកស៊ីសែន** កើតបានជាទឹក បើអនុវត្តទៅឃើញការពិតដូច្នោះមែន ក៏ទ្រទ្រង់ឬជឿនូវពាក្យនោះទៅ។ ដូចជឿការពិតថា លូកភ្លើងក្តៅ ដាំពូជបែបណា រមែងបានផលបែបនោះ គឺដាំពោតបានផលជាពោត ដាំស្រូវបានផលស្រូវជាដើម។ សទ្ធាឬជំនឿក្នុងព្រះពុទ្ធសាសនាមានបញ្ញានៅជាមួយ បើឃើញការពិតបែបណាក៏ទ្រទ្រង់ឬជឿបែបនោះ ដូចពាក្យថា ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប។ ជឿក្នុងព្រះពុទ្ធសាសនាគឺជឿការពិត ដែលព្រះពុទ្ធបានសំដែង ដូចជឿការត្រាស់ដឹងរបស់ព្រះពុទ្ធគឺ **អរិយសច្ច៤** មានទុក្ខសច្ចជាដើម ជឿព្រះធម៌ គឺមគ្គប្រកបដោយអង្គ៨ ជាធម៌ធ្វើឱ្យអ្នកប្រតិបត្តិតាមដល់នូវការរំលត់ទុក្ខពិតមែន ជឿព្រះសង្ឃជាអ្នកទ្រទ្រង់នូវគុណមានសីលគុណជាដើមពិតមែន។ ជឿព្រះពុទ្ធសាសនា គឺជឿហេតុផល ឬជឿកម្មផលជាយថាវត្ថុ គឺធម្មជាតិយ៉ាងណាវាប្រព្រឹត្តទៅយ៉ាងនោះជាស្វ័យប្រវត្តិដោយខ្លួនឯង ពុំមែនកើតពីព្រះជាម្ចាស់អង្គណាមួយឡើយ។ ព្រះពុទ្ធប្រៀនប្រដៅពុទ្ធបរិស័ទកុំឱ្យ

ជឿពាក្យដែលនិយាយតៗគ្នា តែត្រូវជឿការពិតបន្ទាប់ពីបានពិចារណាពិសោធរួចហើយ។ ជំនឿខុសនាំឱ្យធ្វើខុសជំនឿត្រូវនាំឱ្យធ្វើត្រូវ។ **សទ្ធា** នេះមាននិយាយក្នុង **ពលៈ៥** ហៅថា **សទ្ធាពល** ប្រែថា ធម៌ជាកម្លាំងគឺសទ្ធា នៅក្នុង **ឥន្ទ្រិយ៍៥** ហៅ **សតិន្ទ្រិយ៍** ប្រែថា ធម៌ជាធំគឺសទ្ធា ។ ពុទ្ធបរិស័ទខ្មែរបានប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដោយមានជំនឿយ៉ាងមុតមាំថាព្រះធម៌ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធនោះអាចនាំឱ្យគេបានសុខ ចំរើនរហូតដល់ការរំលត់ទុក្ខពោលគឺព្រះនិព្វាន។ ព្រះពុទ្ធសាសនាជាសាសនាមិនបង្ខំមនុស្សឱ្យជឿ នេះជាគោលការណ៍ដ៏សំខាន់របស់ព្រះពុទ្ធក្នុងការគោរពសិទ្ធិអ្នកដទៃ ដោយព្រះពុទ្ធដីកាថា អ្នកទាំងឡាយមានសិទ្ធិដ៏ពេញលេញក្នុងការពិចារណានូវធម៌របស់តថាគតមុននឹងសម្រេចចិត្តជឿ។ ផ្ទុយទៅវិញ មានសាសនាខ្លះបានបង្ខំគេឱ្យជឿសាសនាខ្លួនដោយមធ្យោបាយផ្សេងៗ មានផ្តល់ជាវត្ថុផ្សេងៗជាធ្នាក់ទាក់ទឹកចិត្ត ។

# បុណ្យទក្ខិណានុប្បទាន

**បុណ្យទក្ខិណានុប្បទាន** ជាបុណ្យមួយធ្វើឡើង ដើម្បីឧទ្ទិសកុសលជូនដល់អ្នកដែលចែកឋានទៅ។ តាមធម្មតា មនុស្សណាម្នាក់មានបំណងជូនវត្ថុដល់អ្នកណាម្នាក់ គេអាចជូនដោយកាយ ឬដោយវាចា, នេះជូនចំពោះអ្នកនៅរស់។ ប៉ុន្តែចំពោះអ្នកដែលស្លាប់ទៅ ពុំអាចជូនបែបនេះបានឡើយ គឺត្រូវធ្វើបុណ្យកុសល មានធ្វើទានសមាទានសីលជាដើម ហើយតាំងចិត្តជូនទៅ ដែលហៅថា **បុណ្យទក្ខិណានុប្បទាន** នេះឯង។ បុណ្យទក្ខិណានុប្បទាននេះត្រូវធ្វើឱ្យត្រឹមត្រូវ ទើបសម្រេចផលដល់អ្នកដែលចែកឋានទៅដោយអង្គ៣ប្រការ គឺ **មួយ** ត្រូវធ្វើបុណ្យកុសល មានការធ្វើទានរក្សាសីលភាវនាជាដើម ជាពិសេសត្រូវធ្វើទានចំពោះអ្នកមានសីល ដែលក្នុងបាលីថា **សង្ឃម្ហិ សុបតិដ្ឋិតា** ប្រែថាទានបានដំកល់ល្អហើយក្នុងព្រះសង្ឃ។ **ពីរ** គឺ **ឧទ្ទិសេន** ប្រែថា ដោយការតាំងចិត្តជូនកុសលទៅ។ បានសេចក្តីថា ត្រូវតាំងចិត្តឧទ្ទិសកុសលដែលបានធ្វើនោះជូនដល់អ្នកដែលចែកស្ថានទៅ ទើបអ្នកស្លាប់មានសិទ្ធិទទួល។ បើពុំបានឧទ្ទិសជូនទៅទេ អ្នកស្លាប់គ្មានសិទ្ធិទទួលឡើយ ប្រៀបដូចជនណាម្នាក់ពុំហ៊ានយកវត្ថុដែលគេពុំបានឱ្យដោយកាយ ឬដោយវាចា បើយកទុកជាបទលួច។ ការឧទ្ទិសកុសល គឺឧទ្ទិសតាមមនោទ្វារ គឺផ្លូវចិត្តទុកជាបានការ។ បើបញ្ចេញវាចាដូចជាធម៌វេវថែមទៀតក៏រឹតតែល្អ មាន

អ្នកខ្លះសរសេរឈ្មោះអ្នកស្លាប់ ព្រោះខ្លាចភ្លេចនឹកពុំអស់។ **បី** គឺ **អនុមោទនៃន** គឺ អ្នកស្លាប់ដែលបានទៅកើតជាអ្វីមួយនោះអាចទទួលត្រេកអរបានផង។ ក្នុង **តិរោកុឌ្ឌសូត្រ** បញ្ជាក់ថាសត្វដែលអាចទទួលផល ដែលញាតិមិត្តឧទ្ទិសទៅឱ្យ ភាគច្រើនបានដល់ប្រេតពពួក មានប្រេតឈ្មោះ **បរទត្តូបជីវិកប្រេត** ប្រែថា ប្រេតរស់នៅដោយសារអំណោយផល ដែលញាតិមិត្តឧទ្ទិសទៅឱ្យជាដើម នេះជាអង្គ៣យ៉ាងនៃការធ្វើបុណ្យទក្ខិណានុប្បទាន។ មានទំនៀមទម្លាប់ក្រៅពុទ្ធសាសនាមួយគឺការសែនព្រេន ដោយគេរៀបចំបាយទឹកនំចំណីហើយនិយាយអញ្ជើញអ្នកដែលចែកស្ថានទៅ ឱ្យមកសេពសោយ។ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ការសែនបែបនេះ អ្នកដែលស្លាប់ទៅពុំអាចមកបរិភោគភោជនាហារនោះបានឡើយ ព្រោះអ្នកស្លាប់ទៅបានទៅកើតជាអ្វីមួយ មានអាហារផ្សេងៗគ្នា ប៉ុន្តែបានផលដល់អ្នកធ្វើខ្លះត្រង់នឹកគុណដល់អ្នកស្លាប់។

ចំណែកព្រះសង្ឃសូត្រធម៌ធម្មសង្វេគ ដែលពុទ្ធបរិស័ទនិយមហៅថាធម៌បង្សុកូលនោះ គ្រាន់តែជាកិច្ចអនុមោទនាទៅលើអង្គទាំង៣នៃទក្ខិណានុប្បទាននោះប៉ុណ្ណោះ។ តាមពិត ការសូត្រធម៌ធម្មសំវេគ ដែលហៅថាធម៌បង្សុកូលនោះ មានគោលបំណងពិសេសឱ្យអ្នកនៅរស់ដែលជាសមាជិកគ្រួសាររបស់អ្នកស្លាប់ពិចារណាឱ្យឃើញភាពពុំទៀងនៃជីវិត ដូចព្រះសង្ឃសូត្រធម៌ថា **អនិច្ចា វត សង្ខារា** ។ល។ ប្រែថា សង្ខារទាំងឡាយពុំទៀងមែនពិត មានកិរិយាកើតឡើងហើយវិនាសទៅវិញជាធម្មតា លុះតែរលត់នូវសង្ខារទាំង

ឡាយនោះហើយ ទើបបាននូវសេចក្តីសុខគ្រប់យ៉ាង។ **សទ្ធារ** ក្នុងធមិនេះ សំដៅយកខន្ធ៥របស់មនុស្សសត្វ។ អ្នកដែលបានធ្វើបុណ្យឧទ្ទិសទៅនេះរមែង មានចិត្តជ្រះថ្លា នៅពេលធ្វើបុណ្យហើយបានបុណ្យម្យ៉ាងទៀត គឺត្រង់នឹកដល់ គុណអ្នកដែលចែកស្ថានទៅ។ ក្នុង "**ខ**" ទី៥ នៃធមិដែលបុត្តធីតាប្រុសស្រ្តី ត្រូវតបគុណចំពោះមាតាបិតាថា បន្ទាប់ពីមាតាបិតាអនិច្ចកម្មទៅ បុត្រធីតា ប្រុសស្រី ត្រូវធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសលជូនគាត់។ ចំណែក សមាជិកគ្រួសារដែលស្លាប់ទៅក្រៅពីមាតាបិតា ក៏ក្រុមគ្រួសារត្រូវឧទ្ទិស កុសលជូនទៅដូចគ្នា។ ការឧទ្ទិសកុសលនេះមិនត្រឹមតែញាតិមិត្តរបស់ខ្លួនទើប ឧទ្ទិសកុសលបាននោះទេ អាចក្រាលចិត្តឱ្យទូលាយឧទ្ទិសជូនទៅគ្រប់សព្វសត្វ ទាំងអស់ ដូចការសូត្រធមិ **យំ កិញ្ចិ កុសលកម្មំ**។ ការឧទ្ទិសកុសល នេះក្នុងឧត្តមគតិថា ទោះបីក្រុមគ្រួសារស្លាប់ទៅហើយក៏នៅតែនឹករលឹកគុណ ពុំភ្លេច ហើយជាការជួយសង្គ្រោះក្រែងអ្នកស្លាប់ទៅនោះ ទទួលរងទុក្ខវេទនា ក្នុងភពណាមួយ ជាការឧទ្ទិសជួយរំលែកទុក្ខដែលចាត់ទុកជាជាតបគុណចំពោះ អ្នកស្លាប់។

# អត្ថន័យបុណ្យចូលឆ្នាំខ្មែរ

បុណ្យចូលឆ្នាំខ្មែរតែងធ្វើនៅថ្ងៃទី១៣ខែមេសារៀងរាល់ឆ្នាំ តែយូរៗមានធ្វើនៅថ្ងៃទី១៤ ខែមេសាម្តង។ ពេលវេលានៃការកំណត់ចូលឆ្នាំនេះ គឺកំណត់ទៅតាមក្បួនហោរាសាស្រ្ត ដែលចេញផ្សាយជាផ្លូវការពីព្រះបរមរាជវាំងខ្មែរ។ ទាក់ទងនឹងពេលវេលានៃការចូលឆ្នាំនេះ មានរឿងបុរាណមួយនិទានថា **កបិលមហាព្រហ្ម** ភ្នាល់ចាញ់ **ធម្មបាលកុមារ** ជាមនុស្សលោកអំពី **សិរី៣ប្រការ** គឺពេលព្រឹកយកទឹកលុបមុខ ពេលថ្ងៃត្រង់យកទឹកលាបទ្រូង និងពេលល្ងាចរៀបចូលដំណេកយកទឹកលាងជើង។ នាងទេពធីតាទាំង៧នាក់ជាបុត្រីព្រហ្ម បានផ្លាស់វេនគ្នាក្នុង១ឆ្នាំម្តង រាល់១២ឆ្នាំយកព្រះសិរគឺក្បាលព្រហ្មជាបិតាខ្លួនពីភ្នំកៃលាសហែប្រទក្សិណភ្នំព្រះសុមេរុ ដោយមានព្រះទេពនិករជួយហែហមផង រួចទើបយកទៅតម្កល់ទុកនៅភ្នំកៃលាសវិញ។ នាងទេពធីតាជាអ្នកនាំផ្លូវដង្ហែក្បួននោះ មានអានុភាពសាយភាយចាប់តាំងពីថ្ងៃចូលឆ្នាំទៅអស់រយៈពេល១ឆ្នាំគត់ ហើយមហាសង្ក្រាន្តក៏ចេញប្រកាសប្រាប់នូវគ្រោះកាចគ្រោះជាក្នុង១ឆ្នាំនោះ។ សេចក្តីដំណាលនោះបានប្រកាសប្រាប់ថាត្រូវឱ្យអស់មនុស្សផងទាំងឡាយខំធ្វើទាន រក្សាសីល ចំរើនមេត្តាភាវនាក្នុងឆ្នាំថ្មីនេះនឹងបានសេចក្តីសុខក្សេមក្សាន្តអាយុយឺនយូរ ហើយទេវតានឹងជួយថែរក្សា។ ទោះបីរឿងរ៉ាវនេះមិនមានក្នុងព្រះពុទ្ធសាសនា ប៉ុន្តែពុទ្ធសាសនិកជនខ្មែរបំពេញបុណ្យកុសលជាពុទ្ធសាសនា។

ពាក្យថា **សង្ក្រាន្ត** ឬ **សង្ក្រាន្តិ** ប្រែថា ដំណើរឃ្លាតចាកទី ការឈានចូលដល់ ដំណើរដែលព្រះអាទិត្យចរចូលដល់ទីជួបមួយជុំនៃរាសីចក្រ គឺដំណើរដែលដើមនិងចុងនៃរាសីចក្រជួបគ្នាពេញគ្រប់១ឆ្នាំ បានដល់ការដាច់ឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មីនេះឯង។ ដូច្នេះការកំណត់ចូលឆ្នាំខ្មែរនេះ គឺកំណត់តាមសុរិយគតិ គឺតាមដំណើរព្រះអាទិត្យ។ មានន័យសេចក្ដីថា ក្នុង១ឆ្នាំព្រះអាទិត្យធ្វើដំណើរបាន១ជុំ គឺឃ្លាតចាកពីចំណុច១ ហើយមកជួបចំណុចដដែលនោះវិញ។ ស្របនឹងវិទ្យាសាស្ត្រថា ផែនដីវិលជុំវិញព្រះអាទិត្យបាន១ជុំក្នុង១ឆ្នាំ។ ការចូលឆ្នាំនេះ កំណត់បីថ្ងៃ គឺ ថ្ងៃចូល ថ្ងៃកណ្ដាល និង ថ្ងៃឡើងស័ក។

តាមប្រពៃណីមុនថ្ងៃចូលឆ្នាំ ជនជាតិខ្មែរបានរៀបចំប្រដាប់ប្រដាសំរាប់ធ្វើបុណ្យ និងសំរាប់ប្រើប្រាស់ ព្រមទាំងសំរាប់ទទួលទានទុកជាស្រេច ព្រោះក្នុងអំឡុងពេលបីថ្ងៃនោះ គេបញ្ឈប់ការងារទាំងអស់ សូម្បីអុសទឹកអង្ករ ក៏គេបំរុងទុកឱ្យហើយដែរ។ ក្នុងឱកាសចូលឆ្នាំថ្មីនោះ រដ្ឋបានឱ្យឈប់ធ្វើការចំនួន៣ថ្ងៃ, ដូច្នេះទាំងអ្នករដ្ឋការ ទាំងប្រជាពលរដ្ឋ បានកាត់ទៅជួបជុំឪពុកម្ដាយ បងប្អូននៅភូមិកំណើតរៀង១ខ្លួន ដោយនាំយកទៅជាមួយខ្លួននូវវត្ថុសំរាប់ធ្វើបុណ្យ និងសំលៀកបំពាក់ នំចំណីសំរាប់ប្រគេនព្រះសង្ឃ និងជូនឪពុកម្ដាយខ្លួន។ ពេលល្ងាចនៃថ្ងៃបុណ្យនេះ គេនាំគ្នាទៅវត្តស្ដាប់ព្រះសង្ឃចំរើនព្រះបរិត្ត និងស្ដាប់ព្រះសង្ឃសំដែងធម្មទេសនា, ពេលថ្ងៃគេរាប់បាត្រ វេរចង្ហាន់ប្រគេនព្រះសង្ឃបង្សុកូល ឧទ្ទិសកុសលដល់អ្នកដែលចែកស្ថានទៅ។

ក្នុងថ្ងៃចូលឆ្នាំនោះមានពិធីពូនភ្នំខ្សាច់ មានកន្លែងខ្លះយកស្រូវឬអង្ករពូនជំនួសខ្សាច់។ គេពូនធ្វើជាភ្នំធំមួយនៅចំកណ្ដាល ឯភ្នំតូច៤ទៀតនៅសងខាង មានធ្វើរាជវ័តិព័ទ្ធជុំវិញ នៅជើងភ្នំមានដោតទង់ក្រដាសពណ៌ ទៀនធូប ផ្កាភ្ញីផ្សេងៗ។ មតិមួយយល់ថា ភ្នំធំកណ្ដាលជាតំណាងភ្នំព្រះសុមេរុ៍ជាស្នូលនៃពិភពលោក ឯភ្នំព័ទ្ធជុំវិញគ្រប់ទិសជាតំណាងភ្នំ **សត្តបរិភណ្ឌ** ដែលជាបរិវារភ្នំព្រះសុមេរុ៍។ ការធ្វើភ្នំដូច្នេះ វាគ្មានប្រយោជន៍អ្វីសោះក្នុងការបង្កើតជាបុណ្យជាកុសល ដូច្នេះហើយបានជាមានមតិអ្នកប្រាជ្ញយល់ផ្សេងពីនេះថា ភ្នំធំនៅចំកណ្ដាលជាតំណាងព្រះចូឡាមុនីចេតីយ៍នៅស្ថានត្រៃត្រឹង្ស ដែលតម្កល់ទុកនូវព្រះកេសា(សក់)នៃ **ព្រះពុទ្ធសមណគោត្តម** ដែលទ្រង់បានកាត់នៅពេលដែលព្រះអង្គនៅជាព្រះពោធិសត្វចេញសាងបព្វជ្ជាវិញទេ។ មានមតិបន្ថែមទៀតថា ភ្នំធំកណ្ដាលជាតំណាងព្រះសក្យមុនីចេតីយ៍ ដែលបញ្ចុះព្រះសារីរិកធាតុនៃ**ព្រះពុទ្ធ** ឯភ្នំតូចបួនទៀតជាតំណាងចេតិយ ដែលបញ្ចុះអដ្ឋិធាតុរបស់ **ព្រះសារីបុត្ត ព្រះមោគ្គល្លាន ព្រះអានន្ទ** និង **ព្រះមហាកស្សបៈ** ដែលជាសាវកដ៏សំខាន់របស់ព្រះអង្គ។ យោបល់ខាងក្រោយនេះ ឃើញថាមានន័យល្អសំរាប់បង្កើតជាបុណ្យជាកុសល គឺការធ្វើភ្នំជានិមិត្តរូបនៃចេតិយដែលបញ្ចុះព្រះសារីរិកធាតុនៃព្រះពុទ្ធ និងសាវករបស់ព្រះអង្គដែលជាព្រះអរហន្តមានគុណធម៌ដ៏ខ្ពង់ខ្ពស់កំចាត់អំពើបាបអស់ហើយ។ មួយទៀត ជំនឿរបស់មហាជនខ្មែរថា គ្រាប់ខ្សាច់មួយគ្រាប់ៗដែលចាក់ពូនភ្នំនោះអាចផ្ដល់អានិសង្សដល់អ្នកដែលពូនឱ្យបានរួចរដោះចាកបាបគ្រោះឬកម្ម

ព្យេរទៀតផង។ ពុទ្ធសាសនាពោលថា បាបគ្រោះបានត្រូវរំដោះដោយសារបុគ្គលឈប់សាងអំពើបាប។

ក្រៅពីពិធីពូនភ្នំខ្សាច់ មានពិធីស្រង់ព្រះ គឺគេយកទឹកទៅស្រោច ឬទៅរលាស់នៅលើព្រះពុទ្ធរូប។ ពិធីនេះក៏ជាកុសល ព្រោះជាមួយការស្រង់ព្រះពុទ្ធរូប, ពុទ្ធបរិស័ទ **នឹកដល់គុណធម៌ព្រះពុទ្ធ** មានព្រះនាមថា **អរហំ** ប្រែថាព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេសជាដើម រមែងធ្វើចិត្តឱ្យជ្រះថ្លាស្ងប់ផ្លូវចិត្តមួយខណៈដែលជាហេតុនៃសេចក្ដីសុខ។ មិនត្រឹមតែស្រង់ទឹកព្រះពុទ្ធរូបទេ កន្លែងខ្លះមានស្រង់ទឹកប្រគេនព្រះសង្ឃ រហូតងូតទឹកឱ្យមាតាបិតា និងចាស់ទុំដែលមានគុណធម៌ មានសីលគុណទៀតផង។

បុណ្យចូលឆ្នាំខ្មែរ មានខ្លឹមសារពិសេសរបស់ខ្លួន គឺការពិចារណានូវដំណើរជីវិតដែលប្រព្រឹត្តទៅក្នុងរយៈពេល១ឆ្នាំ ទុកជាមេរៀនសំរាប់ឆ្នាំថ្មីក្នុងការរៀបចំផែនការជីវិតទៅមុខទៀតឱ្យបានល្អជាងឆ្នាំចាស់ លះអំពើអាក្រក់ក្នុងឆ្នាំចាស់សាងអំពើល្អក្នុងឆ្នាំថ្មី។ នៅសម័យពុទ្ធកាលមានរឿងប្រេតជាញាតិរបស់ **ព្រះបាទពិម្ពិសារ** ដំណាលយ៉ាងសង្ខេបថា នៅពេលដែលព្រះបាទពិម្ពិសារបាននិមន្តព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានមកទទួលចង្ហាន់។ ព្រះបាទពិម្ពិសារពុំបានតាំងចិត្តឧទ្ទិសកុសល ដល់ពួកប្រេតដែលជាញាតិរបស់ព្រះអង្គ ពួកប្រេតទាំងនោះបានបន្លឺសម្លេងយំស្រែកជុំវិញព្រះរាជវាំងជាសញ្ញាទាមទារបុណ្យកុសល ដើម្បីឱ្យបានអាហារបរិភោគ។ ដោយទូលសួរព្រះពុទ្ធជាម្ចាស់បានជ្រាបរឿងនេះហើយ ទើបព្រះអង្គប្រញាប់ប្រញាល់ធ្វើបុណ្យជាលើក

ទី២ ហើយតាំងចិត្តឧទ្ទិសកុសលសដល់ពួកប្រេតជាញាតិ ។ ចាប់ពីពេលនោះមក សម្លេងស្រែកក៏ស្ងាត់បាត់ទៅ ជាភ័ស្តុតាងបញ្ជាក់ថា ពួកប្រេតជាញាតិបាន ទទួលផលបុណ្យនោះហើយ ។ រឿងនេះស្របនឹងរឿងក្នុងតិរោកុឌ្ឌសូត្របាន ចែងថា មានពួកប្រេតវិស័យខ្លះអត់ឃ្លាន រង់ចាំទទួលផលបុណ្យដែលញាតិមិត្ត ឧទ្ទិសឱ្យដល់ខ្លួន ។

## ☞ **<u>ន័យសង្ខេបនៃបុណ្យចូលឆ្នាំខ្មែរ</u>**

១- ពិចារណាឱ្យកើតធម្មសង្វេគថា ពេលវេលាកន្លងទៅមួយឆ្នាំ អាយុរបស់គេអស់មួយឆ្នាំដែរ ដូច្នេះពុំគួរប្រមាទក្នុងជីវិតដែលចេះតែអស់ទៅ សូន្យទៅនោះឡើយ ។

២- នាំឱ្យមានស្មារតីពិចារណាថា តើឆ្នាំចាស់កន្លងផុតទៅ ខ្លួនគេបាន ធ្វើអ្វីខ្លះ? ដោយទុកឆ្នាំចាស់ជាមេរៀន រៀបចំផែនការជីវិតទៅមុខទៀតឱ្យល្អ ជាងឆ្នាំចាស់ ។

៣- បើមានការទាស់ទែងខ្វែងគំនិតគ្នាក្នុងឆ្នាំចាស់កន្លងផុតទៅ លុះ ដល់ឆ្នាំថ្មីនេះ គេជានានឹងគ្នាវិញ ឈប់ប្រកួតប្រកាន់គ្នា ហើយស្រឡាញ់រាប់ អានគ្នាដូចដើមវិញ ។

៤- ក្រៅពីបំពេញបុណ្យកុសលចំពោះព្រះសង្ឃ គេនាំគ្នាទិញសំលៀក បំពាក់ ម្ហូបចំណី ជូនមាតាបិតាដែលជាអ្នកមានគុណ ។

៥- គេផ្សាយបុណ្យ ផ្សាយកុសល ជូនដល់មាតាបិតា ញាតិកា មិត្ត- សំឡាញ់ និងសព្វសត្វទាំងអស់ ដែលចែកស្ថានទៅ ។

៦- គេដាក់ទានដល់អ្នកក្រីក្រ លំបាកគោកយ៉ាក កំព្រាអនាថា ឥតទីពឹង ដោយទឹកចិត្តអាណិតអាសូរ ។

៧- សូម្បីសត្វតិរច្ឆាន មានគោក្របីជាដើម ដែលតែងតែប្រើវា ក៏គេឈប់ប្រើវាក្នុងរវាងបីថ្ងៃ ហើយពោលសុំខមាទោសនឹងសត្វទាំងនោះទៀតផង កុំឱ្យមានកម្មពៀរទៅអនាគតនៅពេលដែលខ្លួនប្រើធ្វើបាបវា ។

៨- ពុំមែនសូមខមាទោសចំពោះតែសត្វដែលមានវិញ្ញាណទេ សូម្បីធម្មជាតិដែលគ្មានចិត្ត គ្មានវិញ្ញាណ ក៏បុព្វបុរសខ្មែរសម័យដើម សូមខមាទោសផងដែរ ដូចជាយកទឹកទៅច្រូចលើដី ហើយពោលសូមខមាទោសថា សូមកុំឱ្យខ្ញុំមានកម្មមានពៀរ ព្រោះខ្ញុំបានបន្ទោរបង់មូត្រ លាមកពីលើ ។

៩- ក្រៅពីកម្មវិធីសាសនា គេមានលេងកំសាន្តដោយល្បែងផ្សេងៗ ដែលជាល្បែងឥតទោស ជាល្បែងហាត់ប្រាណ ជាល្បែងដែលនាំឱ្យចិត្តរីករាយ បង្កើតជាចំណងសាមគ្គីភាព ដូចជាល្បែងចោលឈូង ទាញព្រ័ត្រជាដើម ។

# បុណ្យមាឃបូជា

ពាក្យថា **មាឃបូជា** កាត់ជាពីរបទ គឺ **មាឃៈ** ១បទ និង **បូជា** ១បទ។ **មាឃៈ** គឺជាឈ្មោះខែមួយក្នុងចន្ទគតិ គឺខែមាឃ, ឯពាក្យថា**បូជា** ប្រែថាការថ្វាយ ការប្រគេន ការជូន ការប្រតិបត្តិតាម។ រួមពាក្យទាំងពីរបទ **មាឃបូជា** ប្រែថា **ការបូជាក្នុងខែមាឃ**។ ពុទ្ធសាសនិកជនអ្នកកាន់ពុទ្ធសាសនាក្នុងលោក ជាពិសេសពុទ្ធសាសនិកជនខ្មែរ ធ្វើបុណ្យមាឃបូជាក្នុងខែមាឃនេះ ដោយប្រារព្ធបុព្វហេតុពីរប្រការគឺ **ព្រះពុទ្ធសំដែងឱវាទបាតិមោក្ខ** ១ និង **ព្រះអង្គដាក់ជន្មាយុសង្ខារ** ១។

__**បុព្វហេតុទី១**__ ការប្រជុំសំដែងឱវាទបាតិមោក្ខនេះ ហៅថា **ចាតុរង្គសន្និបាត** ប្រែថាការប្រជុំប្រកបដោយអង្គ៤ គឺ : __**មួយៈ**__ ថ្ងៃនោះជាថ្ងៃ១៥កើតខែមាឃ, __**ពីរៈ**__ ព្រះអរហន្តចំនួន១២៥០អង្គនិមន្តមកជួបជុំគ្នានៅវត្តវេឡុវ័នក្រុងរាជគ្រឹះ ដោយឥតបានណាត់គ្នាជាមុនឡើយ, __**បីៈ**__ ព្រះអរហន្តទាំងនោះសុទ្ធតែបានសម្រេចបដិសម្ភិទាញាណ(កន្លែងខ្លះថាបានសម្រេចអភិញ្ញា៦), __**បួនៈ**__ ជាឯហិភិក្ខុបានបួសក្នុងសំណាក់ព្រះពុទ្ធ។

~ __**បដិសម្ភិទាញាណ**__ មាន៤ គឺ :

១- **ធម្មប្បដិសម្ភិទាញាណ** ប្រាជ្ញាយល់ធម៌,

២- **អត្ថប្បដិសម្ភិទា** យល់សេចក្ដីរបស់ធម៌,

៣- **បដិភាណបដិសម្ភិទា** ឈ្លាសវៃ ក្នុងការសំដែងធម៌,

៤. **និរុត្តិបដិសម្ភិទា** ឈ្លាសវៃក្នុងការប្រើភាសាឬប្រើពាក្យ ។

- **អភិញ្ញា ៦** គឺ :

១. **ឥទ្ធិវិធិ** សំដែងឫទ្ធិផ្សេងៗ បាន,

២. **ទិព្វសោត** ស្តាប់សម្លេងដែលមិនឮដល់ត្រចៀកបាន,

៣. **ចេតោបរិញ្ញាណ** ដឹងចិត្តអ្នកដទៃ,

៤. **បុព្វេនិវាសានុស្សតិ** រលឹកអតីតជាតិ,

៥. **ចុតូបបាតញ្ញាណ** ដឹងហេតុនៃចុតិ-បដិសន្ធិដោយសារកម្ម,

៦. **អាសវក្ខយញ្ញាណ** ដឹងអរិយសច្ចធម៌៤ ជាទីអស់ទៅនៃអាសវៈ

**បុព្វហេតុទី ២** ដែលនាំឱ្យធ្វើបុណ្យមាឃបូជា គឺព្រះអង្គដាក់ជន្មាយុសង្ខារថា នៅតែ៣ខែទៀតទេ ព្រះអង្គនឹងរំលត់ខន្ធបរិនិព្វានហើយ។ បុព្វហេតុទាំងពីរនេះកើតឡើងនៅថ្ងៃ១៥កើតខែមាឃដូចគ្នា។

ពុទ្ធបរិស័ទប្រារព្ធធ្វើពិធីបុណ្យមាឃបូជានេះ ដើម្បីរំលឹកដល់ព្រឹត្តការណ៍ដែលកើតឡើងក្នុងសម័ពុទ្ធកាលទាំងពីរនេះ ជាការគោរពគុណព្រះពុទ្ធដែលកើតមានចំពោះសព្វសត្វ។ ចំពោះការបូជាពីរប្រការ គឺ : **សក្ការបូជា** ការបូជាដោយគ្រឿងសក្ការបូជាទាំងឡាយ មានទៀនផ្កាជាដើមដល់ព្រះរតនត្រ័យ មាន**ព្រះពុទ្ធ**ជាដើម ចាត់ថាបានបុណ្យ បានកុសលមួយផ្នែកហើយ, ប៉ុន្តែព្រះពុទ្ធសំដែងថា ការបូជាឬការគោរពចំពោះព្រះពុទ្ធដ៏សំខាន់បំផុត គឺ **ការប្រតិបត្តតាមធម៌** របស់ព្រះអង្គ។ ព្រះពុទ្ធដីកាថា អ្នកឯណាមួយជាអ្នក

ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដ៏ត្រឹមត្រូវ ជាអ្នកប្រព្រឹត្ត តាមធម៌ជាប្រក្រតី អ្នកនោះឈ្មោះថាធ្វើសក្ការៈ ធ្វើសេចក្តីរាប់អានបូជា ព្រះតថាគតដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម។ ព្រះពុទ្ធដីកាមួយកន្លែងមុន បរិនិព្វានថា : **ម្នាលអានន្ទ ធម៌និងវិន័យដែលតថាគតបានសំដែងហើយ បានបញ្ញត្តិហើយ បើអស់ពីតថាគតទៅ ធម៌និងវិន័យនោះ ជាគ្រូរបស់អ្នករាល់គ្នា។ ម្នាលភិក្ខុទាំងឡាយ ពេលនេះតថាគតផ្តាំអ្នករាល់គ្នាជាចុងក្រោយ ចូរអ្នករាល់គ្នាធ្វើប្រយោជន៍ខ្លួន និងអ្នកដទៃឱ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ ដ្បិតសង្ខារទាំងឡាយមានការអស់ទៅ និងសូន្យទៅជាធម្មតា។**

**បាតិមោក្ខ** មានពីរយ៉ាងគឺ :

១. **<u>អាណាបាតិមោក្ខ</u>** បានដល់ព្រះវិន័យរបស់ព្រះភិក្ខុសង្ឃ គឺ **បាតិមោក្ខសំវរសីល** ដែលមានសិក្ខាបទ២២៧ ដែលព្រះសង្ឃសូត្ររាល់កន្លះខែ។

២. **បាតិមោក្ខ** មួយទៀតហៅថា **ឱវាទបាតិមោក្ខ** ដែលព្រះអង្គសំដែងក្នុងមហាសន្និបាតព្រះសង្ឃ១២៥០អង្គ នៅថ្ងៃ១៥កើតខែមាឃ មានឱវាទ៣យ៉ាងជាដើម។

៥០ **ឱវាទ ៣ ប្រការ** នោះគឺ :

១. "**សព្វបាបស្ស អករណំ**" ប្រែថាការមិនធ្វើអំពើបាបគ្រប់យ៉ាង គឺជា "**ខ**"ហាមមិនឱ្យប្រព្រឹត្តអាក្រក់ មានការបៀតបៀនអ្នកដទៃទាក់ទងការរំលោភសិទ្ធិមនុស្សជាដើម។

២. "**កុសលស្សូបសម្បទា**" ប្រែថា ការបំពេញកុសល គឺជា "**ខ**" ឱ្យធ្វើសេចក្តីល្អ ដោយកាយវាចាចិត្ត ទាក់ទងនឹងចិត្តមេត្តា ករុណា ស្រឡាញ់រាប់អានជួយសង្គ្រោះអ្នកដទៃជាដើម។

៣. "**សចិត្តបរិយោទបនំ**" ប្រែថា ជំរះចិត្តឱ្យស្អាតបរិសុទ្ធ។

ការសំអាតចិត្តឱ្យបរិសុទ្ធនេះជាមូលដ្ឋានសំខាន់បំផុត ព្រោះសកម្មភាពល្អកើតមកពីចិត្តបរិសុទ្ធ បើចិត្តបរិសុទ្ធនឹងធ្វើតែអំពើល្អ នឹងធ្វើឱ្យបុគ្គលម្នាក់ៗ គ្រួសារមួយៗ និងសង្គមជាតិទាំងមូលបានសុខសន្តិភាព។ បើពុទ្ធសាសនិកជនខ្មែរ ទាំងអ្នកដឹកនាំ ទាំងប្រជាពលរដ្ឋ ធ្វើតាមព្រះពុទ្ធឱវាទទាំង ៣យ៉ាងនេះហើយ ឈ្មោះថាគោរពបុណ្យ **មាឃបូជា** ក្នុងថ្ងៃមាឃបូជានេះហើយ។

# បុណ្យកាន់បិណ្ឌ និង ភ្ជុំបិណ្ឌ

បុណ្យកាន់បិណ្ឌ និង ភ្ជុំបិណ្ឌនេះត្រូវពុទ្ធសាសនិកជនខ្មែរតែងធ្វើមុនព្រះសង្ឃចេញព្រះវស្សាចំនួនមួយខែរៀងរាល់ឆ្នាំ គឺចាប់កាន់បិណ្ឌតាមវេនពីថ្ងៃ១រោច ដល់ថ្ងៃ១៤រោចខែភទ្របទ។ នៅថ្ងៃ១៥រោចជាថ្ងៃភ្ជុំបិណ្ឌគឺជាថ្ងៃសំខាន់ ដោយគេធ្វើពិធីបុណ្យនេះរួមគ្នាគ្រប់វេនទាំងអស់។ ពាក្យថា **បិណ្ឌៈ** ចេញមកពីភាសាបាលីថា **បិណ្ឌំ** ប្រែថាដុំបាយ ដូចជាពាក្យថាបិណ្ឌបាត្រ គឺយកដុំបាយទម្លាក់ក្នុងបាត្រ។ ប៉ុន្តែបាយបិណ្ឌដែលគេធ្វើក្នុងពេលកាន់បិណ្ឌនិងភ្ជុំបិណ្ឌនេះ គឺជាដុំបាយដំណើបដែលគេចំអិនលាយខ្ទិះដូងនិងល្ង ឬលាយជាមួយគ្រឿងផ្សំផ្សេងទៀតតាមទម្លាប់អ្នកស្រុក។ គេរៀបចំបាយបិណ្ឌនៅជុំវិញបាយបត្តបូរ។ **បាយបត្តបូរ** ក៏ធ្វើដូចជាបាយបិណ្ឌដែរ គ្រាន់តែគេពូតជាពំនូតធំមានកំពូលស្រួច ហើយគ្របដោយសាជីស្លឹកចេក និងមានដោតទៀនផ្កាភ្ញីផង។ កន្លែងខ្លះឱ្យន័យថា ពាក្យថា **បិណ្ឌៈ** គឺចង្ហាន់ដែលពុទ្ធបរិស័ទប្រគេនព្រះសង្ឃឆាន់ក្នុងពិធីបុណ្យឧទ្ទិសផលបញ្ជូនទៅញាតិសន្តាន មានមាតាបិតាជាដើមដែលចែកឋានទៅកាន់បរលោកហើយ ហៅថា **បិណ្ឌ** ថា**ធ្វើបុណ្យដាក់បិណ្ឌ** ថា**បុណ្យភ្ជុំបិណ្ឌ**។

មុនថ្ងៃភ្ជុំមួយថ្ងៃ គ្រួសារខ្មែរនៅគ្រប់ទីកន្លែងនាំគ្នាធ្វើនំអន្សមនំគមជាដើម បំរុងយកទៅវត្តប្រគេនព្រះសង្ឃឧទ្ទិសកុសល និងសំរាប់ចែកញាតិមិត្ត។

ឯនៅទីវត្ត ពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗបោសសំអាតទីធ្លាវត្ត សំអាតចេតិយ និងតាក់តែងសាលាបុណ្យឱ្យបានសមរម្យ ។

នៅល្ងាចថ្ងៃ១៤រោចមុនភ្ជុំមួយថ្ងៃ មានពិធីពិសេសគឺព្រះសង្ឃចំរើនព្រះបរិត្ត និងទេសនា កន្លែងខ្លះមានធ្វើពិធីអភិសេកព្រះពុទ្ធរូបផង ។ រាល់យប់ក្នុងអំឡុងពេលកាន់បិណ្ឌ និងភ្ជុំបិណ្ឌនោះ ពុទ្ធបរិស័ទបាននាំគ្នាទៅវត្តស្តាប់ព្រះសង្ឃចំរើនព្រះបរិត្ត និងទេសនា ។ រាល់ព្រឹកពុទ្ធបរិស័ទបានយកចង្ហាន់ទៅប្រគេនព្រះសង្ឃដើម្បីបង្សុកូលឧទ្ទិសកុសល ។ ពេលព្រលឹមស្រាងៗ គ្រប់វត្តអារាមគេឮសូរព្រះសង្ឃសូត្រ **បរាភវសូត្រ** លាយឡំដោយភ្លេងពិណពាទ្យ និងធម៌បទផ្សេងៗ កំដរបុណ្យផង ។ មានកន្លែងខ្លះ ពុទ្ធបរិស័ទក្រោកពីព្រលឹមបាចបាយបិណ្ឌនៅតាមខឿនព្រះវិហារដោយគេយល់ថា ពួកប្រេតតែងតែមកពេលងងឹតរកចំណីបរិភោគ ។ ស្របគ្នាក្នុងន័យនេះដែរបានជាគេធ្វើបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះខែរនោច ព្រោះគេយល់ថា ពួកប្រេតចេញដើររកចំណីពេលងងឹត ។ ប៉ុន្តែតាមគម្ពីរព្រះពុទ្ធសាសនាផ្នែកព្រះសូត្របញ្ជាក់ថា អ្នកស្លាប់ដែលអាចទទួលផលបានដោយសារក្រុមគ្រួសារញាតិមិត្តដែលបានធ្វើបុណ្យឧទ្ទិសទៅឱ្យដូចជា ការធ្វើទានរក្សាសីលជាដើម ជាពិសេសអ្នកដែលអាចទទួលផលបាន គឺពួកមនុស្សសត្វដែលបានទៅកើតជាប្រេត ។

នៅក្នុងពេលកាន់បិណ្ឌ និងភ្ជុំបិណ្ឌនោះ ព្រះសង្ឃ និងពុទ្ធបរិស័ទតែងតែសូត្រនូវសូត្រមួយ ហៅថា **បរាភវសូត្រ** ។ បានជាយកសូត្រនេះមកសូត្រធ្វើជាបទផង ព្រោះសូត្រនេះមានប្រយោជន៍ក្នុងការងារប្រចាំថ្ងៃរបស់មនុស្ស ។

គឺជាសូត្រមួយដែលពួកទេវតាទូលសួរព្រះពុទ្ធអំពីធម៌ដែលនាំឱ្យមានសេចក្តីវិនាសដែលផ្ទុយគ្នាពី **មង្គលសូត្រ** ដែលពោលអំពីធម៌ដែលនាំឱ្យមានសេចក្តីចម្រើន។ **បរាភវសូត្រ** ធម៌ដែលនាំឱ្យមានសេចក្តីវិនាស មានជាអាទិ៍ថា អ្នកស្រឡាញ់ធម៌នាំឱ្យចំរើន អ្នកស្អប់ធម៌នាំឱ្យវិនាស អ្នកសេពគប់អសប្បុរស អ្នកដេកច្រើន និយាយច្រើន អ្នកមានទ្រព្យច្រើន មិនចិញ្ចឹមមាតាបិតា ដែលចាស់ជរា អ្នកប្រព្រឹត្តល្បែងបីប្រការ ល្បែងស្រី ល្បែងស្រា ល្បែងភ្នាល់ទាំងឡាយជាដើម ទាំងអស់នេះជាប្រធាននៃសេចក្តីវិនាស។

បុណ្យកាន់បិណ្ឌ និង ភ្ជុំបិណ្ឌនេះ មានខ្លឹមសារជាពិសេស គឺការឧទ្ទិសកុសលជួយរំដោះទុក្ខដល់ញាតិមិត្តក្រុមគ្រួសារមានមាតាបិតាជាដើម ដែលចែកស្ថានទៅ ក្រែងទៅកើតទីណាមួយមានទុក្ខវេទនា ដោយមានអត្ថបទបូរាណខ្មែរពោលថា ស្តេចយមរាជបានដោះលែងសត្វនរក ឬប្រេតក្នុងឱកាសបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនោះឱ្យទៅរកបងប្អូនកូនចៅក្រែងធ្វើបុណ្យកុសលឧទ្ទិសឱ្យខ្លួន។ រហូតមានអត្ថបទខ្លះនិយាយថា បើរកមិនឃើញញាតិមិត្តណាធ្វើបុណ្យឧទ្ទិសឱ្យទេ ក៏យំសោកបោកខ្លួនដោយសេចក្តីស្រេកឃ្លានហើយក៏ប្រទេចផ្តាសាដល់ញាតិមិត្តបងប្អូនកូនចៅរបស់ខ្លួន ដែលមានចិត្តអាក្រក់ពុំនឹកនាដល់សេចក្តីទុក្ខវេទនារបស់ខ្លួន។ ដូច្នេះបុណ្យនេះចាត់ទុកជាបុណ្យឧទ្ទិសកុសលជួយរំលែកទុក្ខ ក្រែងជាតិកំណើតណាមួយបានធ្វើអំពើបាប ហើយធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិ។

បុណ្យនេះមានអត្ថន័យសំខាន់មួយទៀត គឺការពិចារណានូវសង្សារវដ្ដ ដែលកើតមកហើយតែងតែស្លាប់ទៅវិញ ដែលអាចជម្រុញទឹកចិត្តឱ្យលះបង់នូវអំពើបាប ហើយសាងតែអំពើល្អ ព្រោះខ្លាចធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិទាំង៤ មាននរកជាដើម ។

តាមការស្រាវជ្រាវ បុណ្យនេះពុំទាន់ដឹងប្រាកដថាកើតឡើងក្នុងសម័យណាទេ។ នៅសម័យពុទ្ធកាល គេទំនុកបំរុងព្រះសង្ឃដោយបច្ច័យ៤ ក្នុងរយៈកាល៣ខែ ពេលដែលព្រះសង្ឃចូលព្រះវស្សានោះតែម្ដង។ ខ្លះថា បុណ្យនេះយកតាមលំនាំរឿងប្រេតជាញាតិរបស់ព្រះបាទពិម្ពិសារនៅក្នុងគម្ពីរធម្មបទ ដោយមានសេចក្ដីដំណាលជាសង្ខេបថា នៅពេលដែលព្រះបាទពិម្ពិ-សារ បាននិមន្តព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានមកទទួលចង្ហាន់ ព្រះអង្គពុំបានតាំងព្រះទ័យឧទ្ទិសកុសលដល់ព្រះញាតិរបស់ព្រះអង្គ ពួកព្រះញាតិដែលទៅកើតជាប្រេត បានបន្លឺសម្លេងយំស្រែកជុំវិញព្រះរាជវាំងជាសញ្ញាទាមទារផលបុណ្យ ព្រោះខ្លួនមានទុក្ខវេទនាអត់ឃ្លានជាយូរមកហើយ ។ ដោយទូលសួរព្រះពុទ្ធជាម្ចាស់ថា តើសម្លេងនោះជាសម្លេងអ្វី? ព្រះពុទ្ធត្រាស់ថា សម្លេងនោះជាសម្លេងពួកប្រេតជាញាតិរបស់ព្រះអង្គ ពួកគេយំស្រែកព្រោះមហារាជពុំបានផ្សាយកុសលដល់ពួកគេ។ **ព្រះបាទពិម្ពិសារ** បានជ្រាបហេតុការណ៍នេះហើយ ទើបព្រះអង្គប្រញាប់ប្រញាល់ធ្វើបុណ្យដូចគ្នានេះ ជាលើកទី២ ហើយតាំងចិត្តឧទ្ទិសកុសលដល់ពួកប្រេតជាញាតិ។ ចាប់ពីពេលនោះមក សម្លេងស្រែកក៏ស្ងាត់បាត់ទៅ ជាភ័ស្តុតាងបញ្ជាក់ថា ពួកប្រេតជាញាតិបានទទួលផល

បុណ្យនោះហើយ។ បុណ្យនេះពុំមែនឧទ្ទិសចំពោះតែសត្វដែលកើតជាប្រេត នោះឡើយ ព្រោះពាក្យថា បេតះ ជាភាសាបាលី, សំស្ក្រឹតថា ប្រេតៈ, ខ្មែរថា ប្រេត ប្រែជាសេចក្ដីថាអ្នកទៅកាន់បរលោក ឬអ្នកដែលធ្វើមរណកាលទៅកាន់បរលោក។ **ប្រើជានាម** សំដៅយកសត្វប្រេតក្នុងអបាយភូមិ។ **ប្រើជាគុណនាម** សំដៅយកមនុស្សដែលស្លាប់ទៅហើយ។

នៅល្ងាចថ្ងៃ១៥រោចខែភទ្របទនៃថ្ងៃភ្ជុំនោះ ប្រជាពលរដ្ឋខ្មែររៀបសែនដូចតាដោយពិធីផ្សេងៗ ក្រៅព្រះពុទ្ធសាសនាខ្លះ គឺនៅវេលាល្ងាចនោះមានរៀបកន្ទេលខ្មើយ ក្រាលសំពត់សពីលើកន្ទេល ដាក់នំចំអាប១ថាសបង្អែម ១ថាស មានក្រាសម្បៀជាដើម ហើយឱ្យកូនចៅច្រូចទឹកលើសំណែននោះប្រតិស្ឋអធិដ្ឋានជូនទៅដូនតា។ លុះព្រឹកឡើងថ្ងៃ១កើតខែអស្សុជ មានធ្វើទូកស្រទបចេកដាក់នំចំណី អុជ ទៀន បណ្ដែតលើខ្នងទឹកទន្លេស្ទឹងព្រែក ឬអូរតាមស្ថានភាពនៃស្រុកនីមួយៗ បញ្ជូនដូនតាទៅស្រុកវិញ។ ពិធីទាំងអស់នេះមកដល់បច្ចុប្បន្ននេះ ហាក់ដូចជាបាត់បង់ទៅហើយ ពុំសូវឃើញមានធ្វើដូចពីដើមទេ អាចមានធ្វើខ្លះនៅតាមជនបទ។ ទោះបីពិធីនេះក្រៅព្រះពុទ្ធសាសនា ប៉ុន្តែមានន័យរំលឹកគុណចូលក្នុងន័យព្រះពុទ្ធសាសនា។ បុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះមានអត្ថន័យសំខាន់ណាស់ ក្នុងអារ្យធម៌ខ្មែរ ក្នុងចំណងសាមគ្គីភាព ភាតរភាព មេត្រីភាព ទោះបីញាតិមិត្ត ចែកស្ថានទៅហើយ ក៏នៅតែនឹករលឹកតបគុណជួយរំដោះទុក្ខដែរ។

# បុណ្យកឋិនទាន

ពាក្យថា **កឋិន** ប្រែថា រស់នៅដោយកម្រ ដោយវិគ្គហៈថា **កឋតិ កិច្ឆេន ជីវិតីតិ ➢ កឋិនោ** ប្រែថា សភាវៈឯណារស់នៅបានដោយកម្រ សភាវៈនោះហៅថា **កឋិន**។ ប្រៀបដូចជាឈើស្នឹងដែលបុគ្គលកាត់ចេញចាកដើមហើយយកទៅបោះភ្ជាប់នឹងដី រមែងដុះលូតលាស់ឬរស់នៅបានដោយកម្រយ៉ាងណា ឯកិច្ចនឹងកើតឡើងជា**កឋិន** ក៏បានដោយកម្រយ៉ាងនោះដែរ។ **បុណ្យកឋិនទាន** នេះមានពុទ្ធានុញ្ញាតទាក់ទងនឹងព្រះវិន័យ ដោយមានរឿងយ៉ាងសង្ខេបថា មានភិក្ខុ៣០អង្គជាអ្នកប្រតិបត្តិធម៌ក្នុងព្រៃនាំគ្នាទៅក្រុង **សាវត្ថី** ដើម្បីថ្វាយបង្គំព្រះពុទ្ធជាម្ចាស់មុនថ្ងៃចូលវស្សា តែទៅពុំទាន់ក៏នាំគ្នារកសេនាសនៈនៅចាំវស្សានៅក្នុងជនបទមួយ។ ពេលចេញវស្សាទើបបន្តដំណើរទៅគាល់ព្រះពុទ្ធជាម្ចាស់ទាំងភ្លៀងទទឹកជោគ។ ព្រះពុទ្ធបរមគ្រូបានសំណេះសំណាលប្រាស្រ័យជាមួយនឹងភិក្ខុទាំងនោះ ហើយសំដែងធម្មិកថាថា ប្រារព្ធនូវសង្សារវដ្តមិនមានទីបំផុតប្រោសប្រទានដល់ភិក្ខុទាំងនោះ។ លុះចប់ធម្មទេសនា ភិក្ខុទាំងនោះបានសម្រេចព្រះអរហត្តទាំងអស់អង្គ។ បន្ទាប់មក ព្រះអង្គមានព្រះតម្រិះថា បើព្រះអង្គបានអនុញ្ញាត **កឋិនត្ថារកិច្ច** ទុកក្នុងពេលមុន សមភិក្ខុទាំងនោះទុកចីវរមួយនៅនឹងកន្លែង ជាប់តាមជាមួយខ្លួនតែស្បង់និងចីពរប៉ុណ្ណោះនឹងមានអត្តភាពស្រាល ហើយ **កឋិន** នេះព្រះពុទ្ធរាល់ព្រះអង្គតែងមានពុទ្ធានុញ្ញាតទុកឱ្យសាវ័កពុំដែលខានផង។ លុះព្រះតម្រិះ

ដូច្នេះហើយ ទើបត្រាស់ហៅភិក្ខុទាំងឡាយអនុញ្ញាតនូវ **កឋិនត្ថារកិច្ច** ថា **អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ចកប្បិស្សន្តិ** ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុទាំងឡាយដែលបានចាំវស្សារួចហើយទទួលក្រាលកឋិន។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុទាំងឡាយបានក្រាលកឋិនហើយ នឹងបានសម្រេចនូវអានិសង្ស៥ប្រការ។

## ប្លែកពីទានដទៃ៥ប្រការ

**១.<u>ប្លែកដោយកាល</u>** : កឋិនទាននេះព្រះសម្ពុទ្ធមានពុទ្ធានុញ្ញាតតែ២៩ថ្ងៃ គឺចាប់ពីថ្ងៃ១រោច ខែអស្សុជដល់ថ្ងៃ១៥កើត ខែកត្តិក ក្នុងរយៈកាលនេះ ទាយកចង់ធ្វើថ្ងៃណាក៏បាន វត្តមួយទទួលកឋិនបានតែម្តង បើមានម្ចាស់ច្រើនត្រូវធ្វើរួមគ្នាតែមួយថ្ងៃ។

**២.<u>ប្លែកគ្នាដោយវត្ថុ</u>** : សំពត់ដែលអាចក្រាលកឋិនបាន គឺស្បង់ចីពរឬសង្ឃាដីណាមួយដែលបានកាត់ដេរត្រឹមត្រូវតាមពុទ្ធានុញ្ញាត។ បើទាយកវេរជាសំពត់សុទ្ធ ត្រូវភិក្ខុសង្ឃធ្វើឱ្យទៅជាត្រៃចីវរទាំង៣នេះណាមួយ ទើបក្រាលឡើងជាកឋិន។

**៣.<u>ប្លែកដោយអំពើ</u>** : ទាយកអ្នកធ្វើត្រូវធ្វើឱ្យត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិ ឯព្រះសង្ឃក៏គប្បីក្រាលគ្រងនិងអនុមោទនាឱ្យត្រឹមត្រូវតាមវិន័យបញ្ញត្តិដែរ ទើបឡើងជាកឋិនពេញលក្ខណៈ។ ជំនុំសង្ឃដែលមានពី៥រូបឡើងទៅត្រូវប្រគល់សំពត់កឋិនដោយវិធីសូត្រ **ញត្តិយកម្មវាចា**។ បើសំពត់នោះ

ទាយកបានធ្វើ **បុព្វករណៈ**ទាំង៧ គឺការបោកគក់វាស់កាត់ដានជ្រលក់ធ្វើពិន្ទុកប្បរួចហើយ គប្បីយកទៅក្រាលតែម្តង បើពុំទាន់បានធ្វើទេគឺនៅជាសាច់សំពត់សុទ្ធ ព្រះសង្ឃគប្បីនាំគ្នាធ្វើឱ្យរួចក្នុងថ្ងៃនោះ។ បើក្រាលសង្ឃាដី ភិក្ខុមួយអង្គដែលជាអ្នកក្រាលគ្រងនោះ គប្បីបញ្ចេញវាចាឱ្យសង្ឃឮច្បាស់ថា **ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ** ប្រែថា ខ្ញុំក្រាលកឋិនដោយសង្ឃាដីនេះ។ ចំណែក ភិក្ខុអ្នកអនុមោទនាខ្ទីវស្សាជាងអ្នកក្រាលគ្រង ត្រូវបញ្ចេញវាចាថា **អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទាម** ប្រែថា បពិត្រលោកម្ចាស់ដ៏ចំរើនកឋិនរបស់សង្ឃ លោកម្ចាស់ក្រាលរួចហើយ ការក្រាលកឋិននេះប្រកបដោយធម៌ យើងទាំងឡាយសូមអនុមោទនា។

**៤. ថ្លែងដោយបដិគ្គាហកៈ** : ភិក្ខុដែលអាចទទួលក្រាលគ្រងនិងអនុមោទនាកឋិនបាន លុះត្រាតែបានចាំវស្សាបីខែ ចូលជា **បុរិមិកវស្សា** ហើយទទួលកឋិនបានតែម្តង ភិក្ខុដែលមិនបានចាំវស្សាឬមានវស្សាដាច់ ពុំអាចទទួលកឋិនបានឡើយ។ ភិក្ខុដែលត្រូវបាន ជ្រើសឱ្យក្រាលគ្រងកឋិនបាន គឺភិក្ខុដែលមានចីវរដាច់ដាច ហើយចេះនូវ**អានិសង្ស៥** ចាំនូវ **មាតិកា៨ អនត្ថតាការ២៤ អត្ថតាការ១៧**។ **មាតិកា៨** សំដៅយកការដោះកឋិនមានការសូត្រដករបស់សង្ឃដើម្បីឱ្យបានលាភដល់ភិក្ខុដែលមកដល់ថ្មី ដែលពុំបានទទួលកឋិនជាដើម។ **អនត្ថតាការ២៤** សំដៅយកអាការៈដែលភិក្ខុមិនអាចក្រាលឡើងជាកឋិន ព្រោះសំពត់ដែលធ្វើពុំត្រឹមត្រូវតាមវិន័យ។ **អត្ថតាការ** សំដៅ

យកអាការៈដែលភិក្ខុអាចក្រាលឡើងជាកឋិន ព្រោះសំពត់ធ្វើត្រឹមត្រូវតាមវិន័យ ។

**៥-ផ្នែកដោយអានិសង្ស** : កឋិនទាននេះ បានអានិសង្សទាំងពីរផ្នែក គឺបានអានិសង្សទាំងទាយកអ្នកធ្វើ ទាំងព្រះសង្ឃអ្នកទទួលក្រាលគ្រងនិងអនុមោទនា ។ ព្រះសង្ឃរមែងបានអានិសង្ស៥ប្រការ រវាង៥ខែ ដោយសម្រាលចាកអាបត្តិខ្លះ គឺទៅណាពុំបានលាភិក្ខុអ្នកដែលនៅជាមួយគ្នាបាន ធ្វើដំណើរមិនចាំបាច់យកចីវរគ្រប់ប្រដាប់ ឆាន់គណៈភោជនបាន ទុកអតិរេកចីវរបាន មានសិទ្ធិទទួលសង្ឃលាភដែលកើតក្នុងអាវាសដែលខ្លួននៅនោះ ។ ឯទាយកអ្នកធ្វើរមែងបានអានិសង្សដូចបាលីថា **យេ ជនា សុខមិច្ឆន្តា ទត្វាន កឋិនចីវរំ តេបិ ទុក្ខា បមុច្ចន្តិ** ប៉ុណ្ណេះជាដើម ប្រែថា ជនទាំងឡាយណាប្រាថ្នានូវសេចក្ដីសុខដោយឱ្យនូវចីវរដើម្បីកឋិន ជនទាំងឡាយនោះរមែងរួចចាកទុក្ខក្នុងទេវតានិងមនុស្សទាំងឡាយ និងមិនទៅកើតក្នុងអបាយទាំងឡាយមាននរកជាដើមឡើយ ។ **បុណ្យកឋិនទាន** នេះបង្កើតបានជាសាមគ្គីជាតិខ្មែរយ៉ាងសំខាន់ណាស់ ។ មួយទៀត ក្រៅពីបុណ្យកុសលលះអំពើអាក្រក់តាមផ្លូវចិត្ត ក្នុងឱកាសនោះ មានលេងកំសាន្តដោយសិល្បៈផ្សេងៗផង ។ គ្រប់វត្តអារាមក្នុងប្រទេសនិងក្រៅប្រទេស ពុទ្ធសាសនិកខ្មែរតែងតែចូលរួមក្នុង **បុណ្យកឋិនទាន** នេះដោយសទ្ធាជ្រះថ្លា ។

# បុណ្យពិសាខបូជា

រៀងរាល់ឆ្នាំ ពុទ្ធសាសនិកជនពិភពលោក ជាពិសេសពុទ្ធសាសនិកជនខ្មែរតែងធ្វើពិធីបុណ្យមួយហៅ **បុណ្យពិសាខបូជា**។ បុណ្យនេះ ធ្វើឡើងដើម្បីរំលឹកនូវបុព្វហេតុ៣ប្រការ ដែលកើតឡើងក្នុងសម័យពុទ្ធកាលគឺ :

១- ព្រះពោធិសត្វព្រះនាមព្រះសិទ្ធត្ថប្រសូត។

២- ព្រះអង្គត្រាស់ជាព្រះពុទ្ធឃើញអរិយសច្ច៤ គឺសេចក្ដីទុក្ខហេតុដែលនាំឱ្យកើតទុក្ខ ការរំលត់ទុក្ខនិងវិធីប្រតិបត្តិដើម្បីរំលត់ទុក្ខ។

៣- ព្រះអង្គរំលត់ខន្ធបរិនិព្វាន។

បុព្វហេតុទាំងបីកើតឡើងនៅថ្ងៃ១៥កើត ខែពិសាខដូចគ្នា។ បុណ្យនេះគេចាត់ទុកជាបុណ្យសំខាន់ជាងគេក្នុងព្រះពុទ្ធសាសនា។ ពាក្យថា **ពិសាខបូជា** កាត់ជាពីរបទ **ពិសាខ**មួយបទ និង **បូជា**មួយបទ។ ពាក្យថា **ពិសាខ** ជាឈ្មោះខែមួយក្នុងចន្ទគតិ គឺខែពិសាខ ឯពាក្យថា បូជា ប្រែថា ការថ្វាយ ការប្រគេន ការជូនតាមពាក្យខ្ពស់ទាប បើនិយាយអំពីការថ្វាយឬប្រគេនវត្ថុផ្សេងៗ។ បូជាម្យ៉ាងទៀត ប្រែថា ការប្រតិបត្តិតាម។ រួមទាំងពីរបទ **ពិសាខបូជា** ប្រែថាការបូជាក្នុងខែពិសាខ គឺជាបុណ្យរំលឹកដល់បុព្វហេតុ៣ប្រការក្នុងសម័យពុទ្ធកាលក្នុងខែពិសាខដូចពោលមកហើយ។ ព្រះពុទ្ធនាមដើមសិទ្ធត្ថគោត្តនាមគោតមប្រសូតនៅសតវត្សរ៍ទី៦មុនគ.ស. ព្រះមាតាព្រះនាមសិរិមហាមាយា ព្រះបិតាព្រះនាមសុទ្ធោទន ជាស្ដេចសោយរាជ្យនៅនគរ

កបិលព័ស្តុ ប្រទេសឥណ្ឌា ។ ព្រះជន្ម១៦ព្រះវស្សា ព្រះអង្គរៀបអភិសេកជាមួយព្រះនាង **ពិម្ពា** មានព្រះរាជបុត្រមួយព្រះអង្គព្រះនាម **រាហុល**។ ព្រះជន្ម២៩វស្សាព្រះអង្គចេញទៅបួសជាតាបសឥសី ស្វែងរកការត្រាស់ដឹង ដើម្បីរំដោះទុក្ខមនុស្សសត្វ។ ជាដំបូងព្រះអង្គបានសិក្សាពិសោធជាមួយនឹងគ្រូប្រដៅសាសនាដ៏ល្បីឈ្មោះនាសម័យនោះ គឺគ្រូឈ្មោះ **អាឡារតាបស** និង **ឧទកតាបស** តែពុំបានសម្រេច ទើបលាអាចារ្យទាំងពីរនាក់នោះរកវិធីប្រតិបត្តិដោយខ្លួនព្រះអង្គឯងវិញ។ ព្រះអង្គធ្វើទុក្ករកិរិយា គឺការព្យាយាមធ្វើបាបកាយអស់៦ឆ្នាំ មានការបន្ថយចង្ហាន់ជាដើម តែវិធីនេះនៅតែពុំបានសម្រេចទៀតទើបសោយចង្ហាន់តាមធម្មតាវិញ។ ទីបំផុតនៃការពិសោធ ព្រះអង្គរកឃើញផ្លូវត្រាស់ដឹង គឺមគ្គប្រកបដោយអង្គ៨ប្រការហើយដោយការប្រតិបត្តិតាមមាគ៌ានោះ ទើបធ្វើឱ្យព្រះអង្គឃើញអរិយសច្ច៤ បានត្រាស់ជាព្រះពុទ្ធនៅក្រោមដើមពោធិព្រឹក្ស សព្វថ្ងៃកន្លែងនោះហៅថា **ពោធគយា** នៃប្រទេសឥណ្ឌាក្នុងព្រះជន្ម៣៥ព្រះវស្សា។ បន្ទាប់មក ព្រះអង្គសំដែងធម្មទេសនាប្រោសសត្វអស់រយៈវេលា៤៥ឆ្នាំ។ លុះព្រះជន្ម៨០វស្សាព្រះអង្គរំលត់ខន្ធបរិនិព្វានទុកធម៌វិន័យ ដែលព្រះអង្គសំដែងសម្រាប់មនុស្សសត្វប្រតិបត្តិរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងយប់ថ្ងៃបុណ្យពិសាខបូជាពុទ្ធបរិស័ទខ្មែរបាននាំគ្នាទៅវត្តនមស្ការព្រះរតនត្រ័យសមាទានសីលប្រកាសពិសាខបូជា វេរគ្រឿងសក្ការៈ ស្តាប់ព្រះសង្ឃចំរើនព្រះបរិត្តនិងទេសនា លុះព្រឹកឡើង មានពិធីរាប់បាត្រនិងវេរចង្ហាន់ប្រគេនព្រះសង្ឃ។ ក្នុងឱកាសបុណ្យពិសាខបូជានេះ

រាជរដ្ឋាភិបាលខ្មែរបានអនុញ្ញាតឱ្យមន្ត្រីរដ្ឋការឈប់សម្រាកធ្វើការ ដើម្បីបំ-ពេញបុណ្យកុសលនេះ ដែលចាត់ទុកជាបុណ្យជាតិស្របតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ដែលចែងថាព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ ជិតបរិ-និព្វានព្រះអង្គបានត្រាស់ជាចុងក្រោយថា **សង្ខារទាំងឡាយមានការអស់ទៅសូន្យទៅជាធម្មតា ចូរអ្នករាល់គ្នា ខំប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ដោយសេចក្តីមិនប្រមាទចុះ**។ ពេលនោះ ភិក្ខុទាំងឡាយដែលកំពុងគង់នៅជិតព្រះពុទ្ធបរមគ្រូលុះបានជ្រាបថា ព្រះអង្គនឹងបរិនិព្វាន ក៏សំដែងនូវការក្រៀមក្រំសោកស្តាយចំពោះព្រះអង្គ ចំណែកព្រះអរហន្តជាព្រះខីណាស្រពកើតក្តីសង្វេគចំពោះសង្ខាររបស់សព្វសត្វដោយគិតថា សូម្បីតែព្រះពុទ្ធជាបុគ្គលឈ្នះមារ ក៏ព្រះអង្គរលត់ខន្ធនិព្វានដែរ។ ប្លែកតែភិក្ខុមួយអង្គ គេចខ្លួនពីទីនោះទៅចំរើនធម៌តែម្នាក់ឯងធ្វើឱ្យភិក្ខុទាំងឡាយលើកទោសថា ភិក្ខុអង្គនេះពុំគោរពព្រះពុទ្ធជាម្ចាស់ទេ។ ដើម្បីបំបាត់សេចក្តីសង្ស័យ ព្រះពុទ្ធបានត្រាស់ឱ្យហៅភិក្ខុនោះមកសាកសួរ ភិក្ខុនោះឆ្លើយថា ខ្ញុំព្រះអង្គពុំទាន់បានសម្រេចមគ្គផលអ្វីនឹងគេទេ ខ្ញុំព្រះអង្គគេចទៅចំរើនធម៌ឱ្យបានសំរេចមគ្គផលមុនព្រះអង្គបរិនិព្វាន។ ព្រះពុទ្ធបានប្រទានពរសព្ទសាធុការថាប្រពៃហើយ ម្នាលភិក្ខុទាំងឡាយបើជនណាមួយគោរពរាប់អានតថាគត ចូរធ្វើតាមភិក្ខុអង្គនេះដោយប្រតិបត្តិតាម **សីល សមាធិ បញ្ញា** រហូតសម្រេចមគ្គផលនិព្វាន ឈ្មោះថា បូជាតថាគតដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តមប្រសើរជាងសក្ការបូជាដោយផ្កាភ្ញីទៀនធូបជាដើមទៅទៀត។

# រឿងកូនចៀម និង ឆ្កែចចក

រឿងក្នុងគតិលោក ជារឿងបង្ហាញនូវសកម្មភាពល្អអាក្រក់របស់សង្គមមនុស្ស ដែលអ្នកសិក្សាអាចយល់បានបញ្ហាមួយភាគក្នុងសង្គមមនុស្ស ទោះបីរឿងខ្លះយកសត្វធ្វើជាតួអង្គក៏ដោយ ដូចជារឿងកូនចៀមនិង ឆ្កែចចក ដែលអ្នកនិពន្ធមានបំណងបង្ហាញនូវអ្នកតូចទន់ខ្សោយត្រូវអ្នកធំមានឥទ្ធិពលធ្វើបាប ទោះបីអ្នកតូចនោះស្លូតបូតត្រឹមត្រូវយ៉ាងណាក៏ដោយ។ មានដំណើររឿងដោយសេចក្ដីដូចតទៅនេះ ។

មានកូនចៀមមួយចុះទៅផឹកទឹកក្នុស្រះទឹកមួយ ស្របពេលនោះឆ្កែចចកក៏ចុះទៅដែរ។ ឆ្កែចចកឃើញកូនចៀមនោះហើយ ក៏ចង់ស្ទុះទៅចាប់ស៊ី ភ្លាមតែឆ្កែចចកនោះគិតថា បើអញចាប់ស៊ីតែម្ដងក៏បាន ប៉ុន្តែដូចជាពុំអស្ចារ្យ ចាំចាប់កំហុសវាសិន។ គិតហើយឆ្កែចចកក៏កំហែងកូនចៀមថា វើយអាកូនសត្វតូចនេះ ម្ដេចក៏ឯងព្រហើនម៉្លេះមកចុះក្នុងទឹកធ្វើឱ្យទឹកល្អក់អស់រកតែអញផឹកផងពុំបាន។ កូនចៀមឮឆ្កែចចកស្ដីចាប់ទោសដូច្នេះក៏ភ័យញ័រ ប៉ុន្តែខំប្រឹងប្រែងប្រមូលសេចក្ដីក្លាហាន ដើម្បីការពារជីវិតតាមគតិយុត្តិធម៌ថា លោកម្ចាស់ខ្ញុំបាទផឹកទឹកនៅពីក្រោមលោកទេ ទឹកពុំដែលហូរច្រាសទៅខាងលើវិញឡើយ តាមពិតលោកនៅខាងលើខ្ញុំបាទ។ ឆ្កែចចកទាល់ប្រាជ្ញា ទើបយកល្បិចមួយទៀតមកចាប់ទោសដោយចោទថា អើពីឆ្នាំទៅអាឯងដើរនិយាយដើមអញៗរកតែមុខទេតើ។ កូនចៀមឆ្លើយថា បាទលោកពីឆ្នាំទៅរូបខ្ញុំបាទនេះមិន

ទាន់កើតផង បើកើតសោតក៏នៅពុំទាន់ចេះនិយាយទេ ហេតុដូចម្ដេចបានជាលោកចោទខ្ញុំបាទថានិយាយដើមលោកពីឆ្នាំទៅ។ ឆ្កែចចកទាល់ប្រាជ្ញាទៀតទើបយកល្បិចមួយទៀតចោទថា បើអាឯងមិននិយាយព្រោះនៅតូចបើដូច្នេះគឺបងអាឯងនិយាយដើមអញ។ កូនចៀមឆ្លើយថាខ្លួនខ្ញុំបាទនេះកើតក្នុងឧទរដំបូងនៃមេខ្ញុំបាទ ខ្ញុំបាទគ្មានបងទេ។ ឆ្កែចចកបន្តចោទទៀតថា បើបងអាឯងគ្មាន បើដូច្នេះមានតែជីដូនជីតាម៉ែឪអាឯងនិយាយដើមអញ។ កូនចៀមឮឆ្កែចចកចោទនូវពាក្យមានទម្ងន់ងាប់ក្រឡាដូច្នេះ ក៏នៅស្ងៀមពុំអាចឆ្លើយបាន ព្រោះអ្នកណាក៏មានជីដូនជីតាឪពុកម្ដាយដែរ។ ឆ្កែចចកលុះឃើញកូនចៀមនៅស្ងៀមឆ្លើយពុំរួចហើយ ក៏ស្ទុះចូលទៅខាំស៊ីក្នុងពេលនោះទៅ។

ទាញយករឿងនេះមកឆ្លុះបញ្ចាំងមើលសង្គមមនុស្ស គឺឆ្កែចចកប្រៀបមកអ្នកមានអំណាច ឯកូនចៀមប្រៀបដូចអ្នកទន់ខ្សោយគ្មានអំណាច។ រឿងនេះមានន័យថា អ្នកធំ អ្នកមានអំណាចតែងតែរំលោភទៅលើអ្នកតូចតាចជានិច្ច បើអ្នកធំមានអំណាចនោះគ្មានធម៌ក្នុងខ្លួន គ្មានមេត្តា គ្មានការគោរពសិទ្ធិមនុស្សទេ។ ឯអ្នកតូចចាំតែទទួលគ្រោះថ្នាក់ពីអ្នកធំជានិច្ច ទោះបីអ្នកតូចជាអ្នកស្លូតត្រង់គ្មានកំហុសអ្វីក៏ដោយ។ ការចោទរបស់ឆ្កែចចកទៅលើកូនចៀម គ្រាន់តែជាឆាកកំប្លែងកែអផ្សុករបស់ឆ្កែចចកប៉ុណ្ណោះបើវាមិនចោទក៏វាអាចទៅខាំស៊ីបាន ហើយបើទោះបីកូនចៀមឆ្លើយរួចទាំងអស់ ដែលធ្វើឱ្យឆ្កែចចកទាល់ប្រាជ្ញាក៏ឆ្កែនៅតែស៊ីកូនចៀមដដែល។ កូនចៀមដឹងខ្លួនជាមុនថា ខ្លួនពិតជាពុំអាចរួចពីកណ្ដាប់ដៃឆ្កែចចកស៊ីឡើយ ប៉ុន្តែត្រូវតែតស៊ូឆ្លើយ

មុននឹងបាត់បង់ជីវិត។ រឿងមួយទៀត តាមរយៈការចោទរបស់ឆ្កែចចកថា ជីដូនជីតា ម្តាយឪពុកដេរ គឺកំហុសរបស់ជីដូនជីតាម្តាយឪពុកត្រូវមានទោសដល់កូន គឺជាច្បាប់ព្រៃផ្សៃបំផុត។ រឿងនេះយើងនឹកគួរឱ្យរន្ធត់នូវអំពើឃោរឃៅរបស់មេឃាតករខ្មែរក្រហម ដែលសម្លាប់ខ្មែរទាំងគ្រួសារ បើមានសមាជិកគ្រួសារណាម្នាក់ធ្វើខុសសូម្បីកូនតូចមិនទាន់ដឹងក្តីក៏ត្រូវរងគ្រោះស្លាប់ដែរ។ បានជាមានពាក្យមួយឃ្លាពោលថា យុត្តិធម៌មិនៅលើអ្នកធំ អ្នកមានអំណាច ឯអ្នកតូចចាំតែទទួលកំហុសជានិច្ច។ មនុស្សរបៀបឆ្កែចចកនេះនៅតែមាននៅឡើយក្នុងសង្គមមនុស្ស ចំពោះប្រទេសដែលចុះខ្សោយខាងសីលធម៌និងការគោរពសិទ្ធិមនុស្ស។ ល្បិចមនុស្សដែលគ្មានសីលធម៌មានវិធីច្រើនយ៉ាង ដើម្បីបំផ្លាញជីវិតនិងសេចក្តីសុខរបស់អ្នកដទៃ។ ជួនកាលគេបំផ្លាញជីវិតអ្នកដទៃដោយសម្ងាត់។ ជួនកាលគេបង្កើតលេសដោយខ្លួនគេ ហើយចោទកំហុសនេះទៅលើអ្នកណាដែលខ្លួនគេចង់ព្យាបាទ។ ដូចឆ្កែចចកចោទកំហុសទៅលើកូនចៀមដែលគ្មានកំហុស។ អំពើខ្លះគេបង្កើតឱ្យស្របតាមបំណងរបស់អ្នកដែលគេចង់ព្យាបាទ ដោយបំភ័ន្តឱ្យចូលស៊ងគេដើម្បីមើលជំហរអ្នកណាដែលប្រឆាំងគេ។ ល្បិចកិច្ចកល់របស់មនុស្សក្នុងលោកមានច្រើនយ៉ាង បើមិនបានពិនិត្យពិចារណាឱ្យបានហ្មត់ចត់ទេ អាចច្រឡំ។ ជួនកាលគេជួលមនុស្សពីរបីនាក់ឱ្យធ្វើជាសាក្សីមួលបង្កាច់អ្នកណាម្នាក់ដែលគេចង់កំចាត់។ ជួនកាលគេប្រើធម៌ព្រៃ ជួនកាលគេប្រើផ្លូវច្បាប់ ប៉ុន្តែជាច្បាប់ដែលគេរៀបចំទុកជាមុន

ហើយអ្នកដែលកាត់សេចក្តីសុទ្ធតែជាមនុស្សដូចឆ្កែចចក។ អ្នកដែលបានធ្វើបាបកម្មទៅលើអ្នកស្លូតត្រង់នឹងត្រូវវិនាសខ្លួនឯងវិញក្នុងទីអវសាន ។

# ប្រយ័ត្នខ្លាចាស់ចាំសីល

ពាក្យថា **ខ្លាចាស់ចាំសីល** នេះ មាននិទានរឿងមួយក្នុងសៀវភៅស្រីហិតោបទេស ។ រឿងនោះដំណាលថា មានខ្លាមួយស្គមអត់ចំណីក្លែងខ្លួនធ្វើជាអ្នករក្សាសីលពុំសម្លាប់សត្វតទៅទៀត ដោយបំណងបោកបញ្ឆោតបុរសម្នាក់ដើម្បីយកជាចំណី បានជាចាស់បុរាណពោលថា ប្រយ័ត្នខ្លាចាស់ចាំសីល ដូចមានរឿងដោយសេចក្តីសង្ខេបថា មានខ្លាចាស់មួយអត់ចំណីកាយស្គមស្គាំងហេវហត់អស់កម្លាំងដើរទៅណាពុំរួច ពុំអាចរត់ទៅចាប់សត្វឬមនុស្សស៊ីបានក៏ប្រើល្បិចធ្វើជាអ្នករក្សាសីល ។ ថ្ងៃមួយឃើញមនុស្សម្នាក់ដើរមកពីចម្ងាយខ្លាធ្វើជាមុជទឹកលាងបាប ។ លុះបុរសនោះដើរមកជិត ខ្លាបានលើកកងមាសមកបង្ហាញហើយស្រែកហៅបុរសនោះឱ្យចូលមកយក ។ បុរសឃើញក៏មានសេចក្តីលោភលន់ចង់បានតែមានសេចក្តីភ័យខ្លាច ខ្លាដឹងហើយក៏និយាយឱ្យទុកចិត្តថា ខ្ញុំកាលនៅពីក្មេងបានចាប់មនុស្សនិងសត្វស៊ីជាអាហារពិតមែន ដោយអំពើដែលខ្ញុំធ្វើនេះ កូនចៅខ្ញុំបានស្លាប់អស់ តាបសម្នាក់បានប្រៀនប្រដៅខ្ញុំឱ្យឈប់ប្រព្រឹត្តធ្វើដូច្នេះតទៅទៀត ចាប់ពីពេលនោះមក ខ្ញុំបានធ្វើទានរក្សាសីលចំរើនមេត្តាភាវនាមុជទឹកលាងបាបរាល់ថ្ងៃ ខ្ញុំកាន់តែចាស់ហើយខ្ញុំឈប់ធ្វើបាបហើយ ។ បន្ទាប់មកខ្លាបានលើកយកធម៌អាថិខ្លះមកពន្យល់រហូតបុរសនោះស្លាប់គំនិតជឿថាខ្លាចាស់កាន់សីលពិតមែន ។ ពេលដឹងថាបុរសនោះជឿហើយខ្លាពោលថា មុននឹងមកទទួលយកកងមាសពីខ្ញុំ ចូរអ្នកមុជទឹកលាងបាប

សិន ព្រោះថាអ្នកឱ្យបរិសុទ្ធអ្នកទទួលក៏បរិសុទ្ធទើបទាននោះមានផលច្រើន។ ការពិតវិញ ការដែលខ្លាឱ្យបុរសនោះចុះទៅក្នុងទឹកដោយមានគោលបំណងពីរយ៉ាងគឺ :

១- ដើម្បីឱ្យបុរសនោះទុកចិត្តកាន់តែខ្លាំងឡើងថែមទៀត ។

២- បើខ្លាស៊ីពេលដែលរបស់បុរសនោះមកយកកងខ្លាចក្រែងបុរសនោះគេចខ្លួនរួចពេលដែលវាខាំត្របាក់ស៊ី ដូច្នេះត្រូវទុកឱ្យបុរសនោះជាប់ផុងក្នុងភក់ ពេលដែលចុះទៅខ្លួននឹងខាំស៊ីបានដោយស្រួល។ បុរសនោះក៏ចុះទៅក្នុងទឹកជាប់ផុងក្នុងទឹករើខ្លួនពុំរួច ខ្លាឃើញហើយក៏ធ្វើជានិយាយថា អ៊ូ! អ្នកឯងជាប់ផុងមិនអីទេចាំខ្ញុំទៅជួយ ដោយខ្លាផុងដែរខ្លាក៏ដើរទៅសន្សឹម១ ដល់ភ្លាមក៏ខាំបុរសនោះជាប់។ ដោយដឹងថាខ្លួននឹងស្លាប់ បុរសនោះក៏យំអាណិតខ្លួនដោយសារតែមានសេចក្ដីលោភ ខ្វះការពិចារណាឱ្យយល់ហេតុផលពិតចាញ់ឧបាយកលរបស់សត្វខ្លា។ ខ្លាក៏ទំពារស៊ីបុរសនោះភ្លាមតាមសេចក្ដីស្រេកឃ្លានរបស់ខ្លួនដែលអត់ចំណីជាយូរថ្ងៃមកហើយ។ បុរសនោះក៏ដល់នូវមរណភាពទៅ។ រឿងនេះជាឧទាហរណ៍សំខាន់ណាស់ សម្រាប់ទាញការប្រយ័ត្នរបស់ជនជាតិខ្មែរទៅលើបញ្ហាគ្រួសារ បញ្ហាស្រុកទេសកុំឱ្យចាញ់ឧបាយកលទុច្ចរិត ដោយការពុំបានពិចារណាឱ្យដឹងការពិតនាំឱ្យមានគ្រោះថ្នាក់ដល់ជាតិខ្លួន ដោយសារតែអាការៈទន់ភ្លន់និងសំដីផ្អែមល្ហែមខាងក្រៅ។ ធម្មតាជាតិជាសត្វខ្លាធ្លាប់ស៊ីសាច់សត្វសាច់មនុស្សពុំអាចលះបង់នូវអំពើនេះបានឡើយ។ យ៉ាងណាមិញ ជនពាលធ្លាប់ធ្វើអំពើបាបពីដើមមកហើយ គេនៅតែពុំលះ

បង់នូវអំពើនោះឡើយ ។ នៅសម័យពុទ្ធកាល គ្រូសញ្ជ័យទោះបីមានកូនសិស្ស មានសារីបុត្រជាដើមរត់ចោលមកបួសក្នុងសំណាក់ព្រះពុទ្ធជាម្ចាស់ក៏ដោយ ក៏លោកនៅតែមានមានះប្រកាន់លទ្ធិរបស់ខ្លួនដដែល ។ ការប្រកាន់ទិដ្ឋិនិងមានះរបស់គ្រូសញ្ជ័យមានកម្លាំងខ្លាំងក្លាណាស់ រហូតឈឺចាប់ក្នុងចិត្តធ្លាក់ឈាមស្លាប់មិនព្រមលះបង់ទិដ្ឋិការប្រកាន់ខុសនោះ រួចមកបួសក្នុងសំណាក់ព្រះពុទ្ធឡើយ ។ ដូចពួកមេឃាតករខ្មែរក្រហម ពុំមែនបំរើមនោគមវិជ្ជាកុម្មុយនិស្តសុខចិត្តស្លាប់ខ្លួនឯង ពុំបៀតបៀនអ្នកដទៃដូចគ្រូសញ្ជ័យទេ តែពួកនេះបានឃោសនាដោយប្រើល្បិចបោកបញ្ឆោតប្រជាពលរដ្ឋខ្មែរឱ្យជឿដូចខ្លាចាស់ចាំសីល ទីបំផុតប្រជាពលរដ្ឋខ្មែរកន្លះនគរកម្ពុជាបានត្រូវពួកនេះសម្លាប់ ។ ពួកខ្មែរក្រហមដែដល់និងអ្នកដែលជួយឱ្យខ្មែរក្រហមឈ្នះ ច្បាប់កម្មផលនឹងកាត់ទោសពួកនេះ ក៏ដូចជាផ្លូវយុត្តិធម៌ក្នុងផ្លូវអាណាចក្រនឹងយកមេឃាតករនិងអ្នកដែលជួយឱ្យខ្មែរឈ្នះយកមកកាត់ទោសនៅពេលអនាគត ។

# ផលវិបាកនៃការឈ្លោះគ្នា

ពាក្យខ្មែរមួយបទពោលថា :

**- ឈ្លោះគ្នាក្នុងគ្រួសារ ដូចស្រាតកាយា បង្ហាញញាតិ**
**ឈ្លោះគ្នាក្នុងសង្គមជាតិ ដូចលាតកំណាប់ បង្ហាញចោរ ។**

ពាក្យថា **ឈ្លោះគ្នាក្នុងគ្រួសារ ដូចស្រាតកាយាបង្ហាញញាតិ** មានសេចក្ដីថា បើមានការឈ្លោះទាស់ទែងខ្វែងគំនិតគ្នាក្នុងសង្គមគ្រួសាររវាងម្ដាយឪពុកប្ដីប្រពន្ធកូនចៅ បើជម្លោះនោះមានលក្ខណៈស្រាលជាជម្លោះធម្មតានឹងស្ងប់ទៅវិញពុំឮខ្ចរខ្ចាយទៅក្រៅឡើយ ។ ប៉ុន្តែបើជម្លោះនោះមានលក្ខណៈខ្លាំងដល់ថ្នាក់រកខុសរកត្រូវរៀងៗខ្លួនតែងតែឮខ្ចរខ្ចាយទៅខាងក្រៅ ជួនកាលសាម៉ីខ្លួនដែលឈ្លោះគ្នានោះ និយាយប្រាប់ញាតិមិត្ត និងអ្នកជិតខាងហែកកេរ្តិ៍គ្រួសារខ្លួនឱ្យគេស្ដាប់ដើម្បីឱ្យគេជួយកាន់ជើងទៀតផង ។ ពេលនោះហើយដែលកេរ្តិ៍ឈ្មោះអាក្រក់របស់គ្រួសារខ្លួន បានឱ្យអ្នកខាងក្រៅដឹងឮដោយសារតែការបាក់បែកគ្នានេះឯង ។

ពាក្យថា **ដូចស្រាតកាយាបង្ហាញញាតិ** គឺបង្ហាញកេរ្តិ៍ឈ្មោះអាក្រក់ដល់ញាតិ ។

ពាក្យថា **ឈ្លោះគ្នាក្នុងសង្គមជាតិ ដូចលាតកំណាប់បង្ហាញចោរ** មានសេចក្ដីថា ប្រទេសមួយទាស់ទែងគ្នាកើតឡើង ដោយខ្លួនឯងក្ដី ដោយអ្នកខាងក្រៅបង្កើតឱ្យមានឡើងក្ដី សុទ្ធតែជាហេតុពុំល្អសំរាប់ប្រទេសរបស់ខ្លួន ។

អាចិកំបាំងរបស់ជាតិទាំងប៉ុន្មាន បានផ្សាយឱ្យប្រទេសដទៃដឹងទាំងអស់ ។ ពាក្យថា **កំណាប់ទ្រព្យ** សំដៅយកទាំងទ្រព្យសម្បត្តិរបស់ជាតិទាំងច្បាប់ក្បួនរបៀបរក្សាឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដីជាដើម ធ្វើឱ្យគេដឹងទាំងចំណុចខ្សោយទាំងចំណុចខ្លាំងរបស់ជាតិ ហើយអ្នកខាងក្រៅដែលមានមហិច្ឆិតាក៏ឆ្លៀតឱកាសនោះចូលមកជ្រៀតជ្រែកឬចូលមកឈ្លានពានប្រទេសរបស់ខ្លួនដោយការបែកបាក់គ្នានេះឯង ។ ដូចពួកចោរដែលតែងតែរំពៃចាំមើលពេលណាដែលម្ចាស់ទ្រព្យភ្លេចខ្លួន ឬធ្វេសប្រហែស ក៏លួចឆក់យកទ្រព្យសម្បត្តិ. ពាក្យរបស់ខ្មែរនេះ ជាការរំលឹកដាស់តឿនខ្មែរគ្រប់ឋានៈឱ្យប្រុងប្រយ័ត្នគប្បីរក្សាការពារឯករាជ្យជាតិបូរណភាពទឹកដីឱ្យគង់វង់ ។ ដើម្បីរារាំងសត្រូវខាងក្រៅកុំឱ្យចូលមកឈ្លានពានប្រទេសរបស់ខ្លួនបាន មានតែពង្រឹងផ្ទៃក្នុងកុំបែកបាក់គ្នា ដោយខ្មែរគ្រប់ឋានៈបំពេញកិច្ចការតាមមុខងាររបស់ខ្លួនដោយឈរលើមូលដ្ឋានជាតិ ។

# ទោសនៃការផឹកនិងជក់គ្រឿងស្រវឹង

ព្រះពុទ្ធជាម្ចាស់សម្តែងអំពីទោសនៃការផឹកការជក់គ្រឿងស្រវឹង គ្រឿងញៀនមានស្រាជាដើមនេះ ពុំមែនព្រះអង្គបង្កើតឱ្យមានទោសទេ គឺទោសកើតមកអំពីការផឹក ការជក់នេះឯង។ ទោសនៃការផឹកស្រា ៦យ៉ាង រមែងកើតឡើងក្នុងបច្ចុប្បន្ន ៖

១- **សន្ទិដ្ឋិកា ធនជានិ** វិនាសទ្រព្យសម្បត្តិក្នុងបច្ចុប្បន្ន ៖ សេចក្តីថា គ្រួសារមួយចំណាយក្នុង១ខែសម្រាប់ចំណីអាហារ ប្រដាប់ប្រដាប្រើប្រាស់អស់ប៉ុណ្ណេះ ប៉ុន្តែបើក្នុងចំណោមគ្រួសារនោះមានសមាជិកគ្រួសារណាម្នាក់ផឹកស្រាផង នោះត្រូវចំណាយប្រាក់កាសថែមទៀតដែលជាការចំណាយលើសធម្មតានៃថវិកាគ្រួសារដែលធ្លាប់ចំណាយមក ដែលជាការចំណាយចំពោះវត្ថុដែលពុំមែនជាការចាំបាច់សំរាប់ជីវិត។

២- **កលហប្បវឌ្ឍនី** នាំបង្កើតជម្លោះ ៖ អ្នកផឹកស្រាតែងមានស្មារតីពុំនឹងន់ មាត់រអិល និយាយគ្មានដឹងខុសត្រូវ ដែលជាហេតុនាំបង្កើតជម្លោះជាមួយគ្រួសារខ្លួន រហូតមានជម្លោះជាមួយអ្នកដទៃ ដែលនាំឱ្យមានសត្រូវដល់ខ្លួន។

៣- **រោគានំ អាយតនំ** ជាហេតុនាំឱ្យកើតរោគ :

ស្រាជាភេសជ្ជៈមានជាតិពុលមានធាតុក្តៅ ផឹកច្រើននាំឱ្យអាការក្នុងខ្លួនដើរខុសប្រក្រតីដែលបណ្តាលឱ្យកើតជាជម្ងឺផ្សេងៗ តាមវេជ្ជបណ្ឌិតបានពិនិត្យឃើញថា ជម្ងឺខួរ ដូចជាជម្ងឺក្រពះ ជម្ងឺថ្លើម ជម្ងឺសួតមួយភាគបណ្តាលមកពីការផឹកស្រាច្រើន។

៤- **អកិត្តិសញ្ជននី** មានកេរ្តិ៍ឈ្មោះអាក្រក់ :

អ្នកផឹកស្រាតែងមានកេរ្តិ៍ឈ្មោះអាក្រក់ អ្នកដទៃពុំរាប់រកគេពុំជឿទុកចិត្ត ហើយមានឥទ្ធិពលអាក្រក់មកដល់កូនទៀត បើទោះបីកូនពុំផឹកស្រាដូចឪពុកឬម្តាយក៏ដោយ ក៏គេញញើតក្នុងការស្តីដណ្តឹងកូន ព្រោះគេគិតដល់ពូជអម្បូរអ្នកផឹកស្រានេះឯង ដូចពាក្យខ្មែរថា “ធ្វើស្រែឱ្យមើលស្មៅ ទុកដាក់កូនចៅឱ្យមើលផៅសន្តាន”។

៥- **កោបិននិទ្ធំសនី** បង្ហាញកេរ្តិ៍ខ្មាស :

អ្នកផឹកស្រាច្រើនរហូតក្លាយជាប្រមឹកគ្មានអៀនខ្មាសអ្វីឡើយ ទាំងសំលៀកបំពាក់ ទាំងសំដីនិយាយ ទាំងឥរិយាបថទាំង៤ ដេក ដើរ ឈរ អង្គុយ ពុំបានសមរម្យឡើយ។

៦- **បញ្ញាយ ទុព្វលីករណី** ធ្វើឱ្យខ្សោយប្រាជ្ញាស្មារតី :

អ្នកផឹកស្រាច្រើនតែងឱ្យក្តៅសរសៃប្រសាទ មានសរសៃខួរក្បាលជាដើម ទៅជាវង្វេងភ្លេចភ្លាំងស្មារតីបញ្ញាចុះខ្សោយ។ ដោយភាពទន់ខ្សោយប្រាជ្ញាស្មារតី មានអ្នកផឹកស្រាខ្លះ បានប្រើអំពើហិង្សា រករឿងវាយដំប្រពន្ធកូនថែមទៀត

ផង។ មិនតែប៉ុណ្ណោះ មានអ្នកស្រវឹងស្រាខ្លះ ប្រព្រឹត្តចោរកម្មដើម្បីបានប្រាក់យកមកទិញស្រាផឹកទៀត។

ក្នុងសិក្ខាបទទី៥នៃសីល៥ ដែលព្រះពុទ្ធហាមមិនឱ្យផឹកស្រាថាជាទីតាំងនៃសេចក្ដីប្រមាទនោះ ព្រោះអ្នកផឹកស្រាជោកជាំរាល់ថ្ងៃនាំឱ្យភ្លេចបំពេញសេចក្ដីល្អខាងកុសល ហើយធ្វេសប្រហែសក្នុងកិច្ចការគ្រប់យ៉ាងដែលខ្លួនត្រូវបំពេញ ព្រោះអ្នកផឹកស្រាច្រើនចាត់ទុកថាជាអ្នកមានជំងឺ គឺជំងឺស្រវឹង ពុំអាចធ្វើការងារតាមផ្លូវកាយផ្លូវប្រាជ្ញាឱ្យបានមាំទាំ និងទាន់ពេលវេលាឡើយ។ ជួនកាលការងារដែលចាំបាច់ត្រូវធ្វើពេលនេះថាចាំសម្រាក ឬដេកបន្តិចទៀតសិន ឬក៏ថាចាំស្វាងស្រាសិន, នេះឯងដែលហៅថាជាទីតាំងនៃសេចក្ដីប្រមាទ។ នៅក្នុង **មង្គលសូត្រ** ពោលថា ការសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹងជាមង្គលដ៏ឧត្ដម។

មិនចំពោះតែស្រាទេ ភេសជ្ជៈដទៃទៀតឱ្យតែផឹកទៅស្រវឹង ត្រូវចាត់ចូលក្នុងប្រភេទស្រា ដែលនាំឱ្យមានទោសដូចគ្នា។ មានភេសជ្ជៈទំនើបខ្លះខ្លាំងជាងស្រាក៏មាន។ ភេសជ្ជៈទំនើបទាំងនោះ មិនមាននិយាយក្នុងសិក្ខាបទស្រានេះ ព្រោះសម័យពុទ្ធកាលពុំទាន់មាន។ មានភេសជ្ជៈខ្លះដែលគេធ្លាប់ស្គាល់ដូចជា *Beer, Viski...* ជាដើម ឬទឹកត្នោតជូរ ជាភេសជ្ជៈរបស់ខ្មែរ។

គ្រឿងជក់ គ្រឿងហិត ដូចជាអាភៀន កញ្ឆា កាកូអ៊ីនជាដើម បើជក់ឬហិតទៅ នាំឱ្យពុលខូចសុខភាព ត្រូវចាត់ចូលក្នុងលក្ខណៈស្រាទាំងអស់។ ពិសេសចំពោះអាភៀនដាំក្ដី លក់ដូរក្ដី ជក់ក្ដីមានទោសធ្ងន់ ជាទោសឧក្រិដ្ឋ

ប្រទេសខ្លះកាត់ទោសប្រហារជីវិតផង។ អាភៀនមានគ្រោះថ្នាក់ខ្លាំងណាស់ទៅលើសុខភាពរបស់មនុស្សដែលប្រើវា បានជាគេត្រូវបំបាត់ជាអន្តរជាតិ។ បារីក៏ជាថ្នាំមួយធ្វើឱ្យអ្នកជក់កើតរោគដែរ។ តាមវេជ្ជបណ្ឌិតពិនិត្យទៅឃើញថា មានរោគកើតនៅក្នុងសួតមួយប្រភេទកើតមកអំពីការជក់បារី។ សព្វថ្ងៃនេះនៅកន្លែងសាធារណៈ ដូចជាមន្ទីរពេទ្យ សាលារៀន ការិយាល័យ កន្លែងធ្វើការគ្រប់កន្លែង តាមយន្តហោះ គេហាមមិនឱ្យជក់បារីឡើយ។ នៅសហរដ្ឋអាមេរិក មានខ្មែរម្នាក់យកកូនទៅមន្ទីរពេទ្យមើលជម្ងឺ គ្រូពេទ្យពិនិត្យទៅឃើញថាកូននោះឈឺ ព្រោះមានផ្សែងចូលទៅក្នុងសួត។ ឪពុកប្រាប់គ្រូពេទ្យថាគ្រួសារខ្លួនឥតមានជក់បារីទេ ចុះផ្សែងបារីនោះមកពីណា គិតមួយសន្ទុះទើបនឹកឃើញកាលមុននេះមួយថ្ងៃ ខ្លួនបានយកកូនទៅវត្ត ទើបសន្និដ្ឋានថាកូនខ្លួនស្រូបផ្សែងបារី ដែលព្រះសង្ឃឆាន់ក្នុងវត្ត។ ដូច្នេះ ព្រះសង្ឃខ្មែរណាដែលឆាន់បារីគួរឈប់ឆាន់ ហើយពុទ្ធបរិស័ទគួរឈប់ប្រគេនបារីលោកទៀត ព្រោះឆាន់ទៅនាំឱ្យខូចសុខភាពផង ហើយប៉ះពាល់ដល់សាធារណជនដែលមកធ្វើបុណ្យផង ជាទានមិនបានបុណ្យទេ ព្រោះជាទាននាំឱ្យខូចសុខភាព។

បញ្ហាការផឹកស្រា ខ្លះថាគេផឹកស្រាដើម្បីបំបាត់ទុក្ខឬបំភ្លេចទុក្ខ។ តាមពិតសេចក្តីទុក្ខមកអំពីមានបញ្ហាដែលនាំឱ្យកើតទុក្ខ គឺសេចក្តីទុក្ខត្រូវរលត់ បើបានដោះស្រាយបញ្ហាដែលនាំឱ្យកើតទុក្ខ។ ស្រាពុំអាចជួយបំបាត់ទុក្ខបានទេ ផ្ទុយទៅវិញ ទុក្ខកើតមានមួយជាន់ថែមទៀតដោយទោសនៃការផឹកស្រានេះឯង។ ការផឹកស្រាថ្នាំ ដូចជាស្ត្រីខ្មែរនៅឆ្ងាយពីមន្ទីរពេទ្យ ជាអ្នក

ក្រីក្រ ភាគច្រើនឆ្លងទន្លេនៅផ្ទះ រួចអាំងភ្លើង និងផឹកស្រាថ្នាំ ស្ត្រីខ្លះមានជម្ងឺនៅពេលអាំងភ្លើងនោះ ហើយយល់ថាព្រាយក្រឡាភ្លើងធ្វើឱ្យឈឺ។ តាមពិតជំងឺនោះបណ្ដាលមកពីការដកដង្ហើមស្រូបយកផ្សែងអុស ឬផ្សែងធ្យូងដែលដុតអាំងនោះ ដែលមានជាតិពុលនិងបណ្ដាលមកពីការផឹកស្រាថ្នាំច្រើនទៅជាស្រវឹងវិញទេ។

អំពីទោសនៃការផឹកស្រា ពេលស្លាប់ទៅ នៅក្នុងនិរយកថា ដែលនិយាយពីស្ថាននរក មាននរកមួយឈ្មោះ **វេត្តរណីនរក** ប្រែថា **នរកផ្ដៅ** ឬ **ស្ទឹងទឹកប្រៃ**។ គឺនរកនេះ មានស្ទឹងមួយមានទឹកប្រៃខ្លាំង ហើយមានផ្ដៅធំៗមានបន្លាស្រួចមុតដូចកាំបិតកោរ សត្វនរកឃើញទឹកក៏នាំគ្នាទៅផឹកទឹក ក៏ក្លាយទៅជាភ្លើងឆេះពោះក្ដៅងំ ហើយរត់ទៅប៉ះនឹងផ្ដៅដាច់ធ្លុះមុតសាច់ចេញឈាមលំបាកវេទនាយ៉ាងខ្លាំងក្លា។ ទោសធ្លាក់នរកនេះ មកពីជាតិមុន បោកគេស៊ីចាយ ផឹកសុរា និងមេរ័យ កុហកភូតភរគេ មានអាហារ មានទឹកកំណាញ់មិនធ្វើទាន។

ដោយស្រាមានគុណវិបត្តិដូចពោលមកហើយ គួររាជរដ្ឋាភិបាលខ្មែរឈប់កុំឱ្យផលិត កុំឱ្យលក់ កុំឱ្យនាំស្រាគ្រប់ប្រភេទចូលប្រទេសកម្ពុជាតទៅទៀត ដូចជាគេកំចាត់អាភៀនដូច្នោះដែរ។ មួយទៀត មិនត្រូវអនុញ្ញាតឱ្យផ្សាយពាណិជ្ជកម្មស្រា និងបារីនៅលើកញ្ចក់ទូរទស្សន៍តទៅទៀត។ បើបំបាត់បាននូវអំពើអបាយមុខទាំងបី គឺល្បែងស្រី ល្បែងស្រា និង ល្បែងស៊ីសងគ្រប់

ប្រភេទ ឈ្មោះថាគោរពតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ទើបសមជាប្រទេសគោរពប្រតិបត្តិព្រះពុទ្ធសាសនា។

# ទសពិធរាជធម៌ ១០យ៉ាង

មុនព្រះពុទ្ធសំដែងទសពិធរាជធម៌នេះ ភូមិភាគនានានៃពិភពលោកជាពិសេសទីកន្លែងកំណើតព្រះអង្គ សុទ្ធតែមានស្តេចសោយរាជ្យដាច់ដោយឡែកពីគ្នា ជាភូមិភាគតូចៗរបៀបស្តេចត្រាញ់។ ព្រះអង្គយល់ថា ស្តេចដែលកាន់អំណាចទាំងនោះ ពុំបានគ្រប់គ្រងប្រជាពលរដ្ឋដោយអំណាចច្បាប់ទេ ច្រើនប្រើអំណាចខុសគន្លងធម៌។ ដោយព្រះបំណងចង់ឱ្យប្រជាពលរដ្ឋរស់នៅក្នុងសុខសន្តិភាព ជៀសវាងការគាបសង្កត់ពីអ្នកកាន់អំណាច ទើបព្រះពុទ្ធសំដែង **ទសពិធរាជធម៌**នេះ សំរាប់ឱ្យស្តេចទាំងនោះអនុវត្តតាម។ ព្រះអង្គប្រកាសថា **ទសពិធរាជធម៌១០ប្រការ**នេះ ធ្វើបុគ្គលដែលប្រតិបត្តិតាមឱ្យទៅជាស្តេច។ បើមិនប្រតិបត្តិតាមធម៌នេះទេ ពុំអាចធ្វើជាស្តេចដឹកនាំប្រជាពលរដ្ឋបានឡើយ។ សម័យពុទ្ធកាល ការគ្រប់គ្រងប្រទេសភាគច្រើនដឹកនាំដោយព្រះមហាក្សត្រដែលគេចាត់ជាវណ្ណៈខ្ពង់ខ្ពស់ពីកំណើត តាមលក្ខណៈសាសនាព្រាហ្មណ៍។ ពេលនោះព្រះអង្គបានយាងប្រោស **ព្រះបាទពិម្ពិសារ ព្រះបាទបសេនទិកោសល**ឱ្យប្រតិបត្តិតាម **ទសពិធរាជធម៌**នេះ ហើយឱ្យលុះមគ្គផលនិព្វានផង។

**ទសពិធរាជធម៌**១០យ៉ាងនោះគឺ :

១. **ទានៈ** ការធ្វើអំណោយដល់ប្រជាពលរដ្ឋក្រីក្រអត់ឃ្លាន និងខ្វះខាតជាងគេដោយសេចក្ដីអាណិតអាសូរ ព្រោះព្រះមហាក្សត្រជាភ្នែកជាច្រមុះរបស់ប្រជារាស្ត្រ គប្បីដឹងសុខដឹងទុក្ខប្រជារាស្ត្រដោយតាំងព្រះទ័យថា សេចក្ដីទុក្ខរបស់ប្រជារាស្ត្រស្មើនឹងសេចក្ដីទុក្ខរបស់ព្រះអង្គ។ បើប្រជារាស្ត្រអត់ឃ្លានក៏រកមធ្យោបាយដោះស្រាយបំបាត់ការអត់ឃ្លាននោះ។

២. **សីល** : រក្សាសីល៥ជានិច្ច មិនសម្លាប់ មិនលួច មិនរំលោភយកប្រពន្ធអ្នកដទៃ មិននិយាយកុហក មិនសេពសុរា គ្រឿងស្រវឹង។ សីល៥នោះជាមូលដ្ឋាននៃសីលធម៌ បានជាតម្រូវឱ្យប្រជាពលរដ្ឋ និងព្រះមហាក្សត្រត្រូវតែមានដូចគ្នា។ បើអ្នកដឹកនាំមិនមានសីល៥នេះទេ អាចបៀតបៀន ឬសម្លាប់បុគ្គលណាដែលប្រឆាំងអាចលួចប្រាក់ជាតិជាដើម។

៣. **បរិច្ចាគ** : ការចំណាយព្រះរាជទ្រព្យទំនុកបំរុងប្រទេស និងឧបត្ថម្ភសាសនា គឺសម្រាប់បណ្ដុះបណ្ដាលសីលធម៌ឱ្យមានវឌ្ឍនភាពទន្ទឹមគ្នានឹងការលូតលាស់ខាងសេដ្ឋកិច្ចជាតិ។ នៅសម័យពុទ្ធកាល ក្រៅពីការស្ថាបនាជាតិ និងការពារជាតិ ព្រះបាទបសេនទិកោសល ព្រះបាទពិម្ពិសារ បានថ្វាយខ្លួនចំពោះ **ព្រះពុទ្ធ ព្រះធម៌** និង **ព្រះសង្ឃ** ជាញោមឧបដ្ឋាកទំនុកបំរុងព្រះពុទ្ធសាសនាយ៉ាងមុតមាំបំផុត បានជាគំរូដ៏ល្អដល់ប្រជារាស្ត្រទូទៅ។

៤. **<u>អាជ្ជវ</u>** ៖ ប្រែថាមានសេចក្តីត្រង់ គឺមានសេចក្តីទៀងត្រង់ ឬស្មោះត្រង់ចំពោះប្រជារាស្ត្រ។ គ្រប់កិច្ចការដែលអនុវត្តនធ្វើ ឬមានបញ្ជាឱ្យអនុវត្តធ្វើ គឺស្របទៅតាមផលប្រយោជន៍របស់ប្រជារាស្ត្រ និងសេចក្តីត្រូវការរបស់ប្រជារាស្ត្រ មិនប្រើល្បិចកិច្ចកលអ្វីមួយទៅលើរាស្ត្រដោយព្រះទ័យអកុសលឡើយ។

៥. **<u>មទ្ទវ</u>** ៖ ប្រែថាការទន់ភ្លន់សុភាពរាបសាទៅកាន់ប្រជារាស្ត្រ គឺមានសេចក្តីរាប់អានប្រជារាស្ត្រទូទៅដូចជាបុត្របង្កើត។ បានសេចក្តីថា មិនប្រកាន់ តែងតែមានការស្និទ្ធស្នាលជានិច្ច ទៅលើមនុស្សទូទៅ តែងមានការសន្ទនាដកស្រង់យកយោបល់ប្រជារាស្ត្រដើម្បីរៀបចំផែនការស្រុកទេសឱ្យមានយុត្តិធម៌។ សកម្មភាពបែបនេះទើបឈ្មោះថា ព្រះអង្គដាក់ខ្លួនបំរើប្រជារាស្ត្រដោយស្មោះត្រង់។

៦. **<u>តប</u>** ៖ ការកាន់ **ឧបោសថសីល** តាមកាលកំណត់ ដើម្បីបន្ថយនូវកាមារម្មណ៍ គឺបន្ថយនូវការសប្បាយក្នុងរូប សម្លេង ក្លិន រស និងសម្ផស្ស ធ្វើព្រះទ័យឱ្យស្ងប់ចាកកាម ក្នុងថ្ងៃ**ឧបោសថ**នោះ ព្រោះថាបើអ្នកដឹកនាំរដ្ឋជាន់ខ្ពស់ សប្បាយក្នុងកាមខ្លាំងពេក នាំឱ្យរវល់ច្រើនក្នុងកាម ខាតពេលវេលាទៅបំពេញកិច្ចការរដ្ឋ។

៧. **<u>អក្កោធន</u>** ៖ មិនក្រេវក្រោធ មិនធ្វើឱ្យប្រជារាស្ត្រ ឬមនុស្សទូទៅក្តៅក្រហាយ គឺរម្ងាប់ក្តីកំហឹង មិនក្រោធតបនូវមនុស្សដែលក្រេវក្រោធ។

៩. **<u>អវិហឹសា</u>** : មិនបៀតបៀនប្រជារាស្ត្រ និងមនុស្សទូទៅ គឺមិនធ្វើឱ្យប្រជារាស្ត្រមានទុក្ខដោយផ្លូវកាយ និងផ្លូវចិត្ត តែមានព្រះទ័យករុណាអាណិតអាសូរ ជួយដោះស្រាយគ្រប់បញ្ហាទុក្ខលំបាកគ្រប់យ៉ាង និងចំពោះពាក្យរិះគន់គ្រប់បែប ដោយមិនតបតដោយអំពើហឹង្សាឡើយ ។

១០. **<u>អវិរោធន</u>** : មិនបំពានច្បាប់ ដោយលះបង់ប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍ព្រះញាតិ មិនរំលោភច្បាប់ព្រះពុទ្ធសាសនា និងច្បាប់រដ្ឋ ។

**ទសពិធរាជធម៌** ទាំង១០ប្រការនេះ ពុំមែនប្រតិបត្តិតែព្រះមហាក្សត្រទេ អ្នកដឹកនាំរដ្ឋជាន់ខ្ពស់ដទៃទៀតក៏ត្រូវអនុវត្តន៍ដូចគ្នា ព្រោះ **រាជៈ** នេះពុំមែនសំដៅតែព្រះមហាក្សត្រសោយរាជ្យទេ គឺសំដៅយកជនណាដែលធ្វើឱ្យប្រជារាស្ត្រត្រេកអរបាន គឺត្រេកអរដោយសារមានការធ្វើឱ្យជាតិអភិវឌ្ឍន៍គ្រប់វិស័យ មានវិស័យសង្គមកិច្ច និងវប្បធម៌ជាដើម ។ តាមន័យនេះជនណាក៏អាចធ្វើជាព្រះមហាក្សត្របានដែរ ឱ្យតែប្រតិបត្តិឱ្យបានត្រឹមត្រូវតាម **ទសពិធរាជធម៌** ទាំង១០ប្រការនេះ ។ បើប្រតិបត្តិតាមមិនបានទេ មិនអាចធ្វើជាព្រះមហាក្សត្រ ឬអ្នកដឹកនាំរដ្ឋជាន់ខ្ពស់បានឡើយ ។ <u>**ព្រះពុទ្ធសាសនា** សំដែងថា **ទំនាប** និង **ភំពស់** របស់មនុស្ស ត្រូវស្ថិតនៅលើអំពើអាក្រក់ និងអំពើល្អដែលគេបានប្រព្រឹត្តធ្វើ ពុំមែនស្ថិតនៅលើជាតិត្រកូល ទ្រព្យសម្បត្តិ យសសក្តិឡើយ</u> ។

# ធម៌ដែលមាតាបិតាត្រូវសង្គ្រោះកូន

ព្រះពុទ្ធសាសនាសំដែងថា មាតាបិតាក្រៅពីការចិញ្ចឹមកូនឱ្យរស់រាន មានជីវិតហើយ ត្រូវមានភារកិច្ចសង្គ្រោះកូនដោយធម៌៥យ៉ាងទៀត គឺ:

១. **បាបា និវារេន្តិ** ប្រែថា ហាមឃាត់កូនកុំឱ្យធ្វើអំពើបាប។ មានសេចក្តីថា មាតាបិតាជាបុព្វាចារ្យ ប្រែថាជាគ្រូខាងដើម មុនគ្រូក្នុងសាលារបស់រដ្ឋ កូនប្រុសស្រីនៅក្នុងបឋមវ័យ ពុំទាន់ដឹងខុសត្រូវ បុណ្យបាបគុណទោសអ្វីឡើយ ដូច្នេះមាតាបិតាមានភារៈ និងមុខនាទីជាចាំបាច់ មិនត្រឹមតែបង្រៀនកូនឱ្យចេះនិយាយស្តីប៉ុណ្ណោះទេ តែត្រូវបង្រៀនកូនឱ្យចេះនិយាយស្តីត្រឹមត្រូវ និងបង្រៀនឱ្យជៀសវាងអំពីអាក្រក់គ្រប់យ៉ាង ដែលជាអំពើនាំឱ្យគ្រួសារក៏ដូចជាប្រទេសជាតិចុះខ្សោយខាងសីលធម៌។

២. **កល្យាណេ និវេសេន្តិ** ប្រែថា ឱ្យកូនតាំងនៅក្នុងសេចក្តីល្អ។ មានន័យថា មាតាបិតាក្រៅពីការហាមឃាត់កូនកុំឱ្យប្រព្រឹត្តធ្វើអំពើអាក្រក់ ត្រូវបង្ហាត់បង្រៀនអប់រំកូនឱ្យប្រព្រឹត្តធ្វើអំពើល្អ។ ក្នុងន័យនេះបញ្ជាក់ថា មាតាបិតា មិនត្រឹមតែចិញ្ចឹមកូនឱ្យរស់ប៉ុណ្ណោះទេ តែត្រូវពន្យល់បង្ហាញកូនឱ្យស្គាល់មាគ៌ាជីវិត របៀបរស់នៅក្នុងសង្គមដើម្បីឱ្យកូនយល់ច្បាស់ ព្រោះថាកូននឹងត្រូវគ្រប់គ្រងជីវិតដោយខ្លួនឯងនាអនាគតនៅពេលដែលបែកចេញពីមាតាបិតាទៅ។ ការអប់រំនេះជាធាតុសំខាន់ណាស់ បើមាតាបិតាមានវិជ្ជាសម្បត្តិ និងចរិយាសម្បត្តិខ្ពស់ ការអប់រំកូនក៏មានកម្រិតខ្ពស់ដែរ។

៣. **សិប្បំ សិក្ខាបេន្តិ** ប្រែថា ឱ្យកូនសិក្សានូវវិជ្ជាផ្សេងៗ។ មានន័យថា មាតាបិតាបានអប់រំកូនទុកជាការត្រួសត្រាយផ្លូវឱ្យបានយល់អំពីមាគ៌ាជីវិតបានមួយភាគហើយ តមកទៀតត្រូវបញ្ជូនកូនឱ្យទៅសិក្សានូវវិជ្ជាផ្សេងៗនៅក្នុងសាលារដ្ឋចាប់ពីបឋមវ័យទៅ ដើម្បីឱ្យកូនមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ទោះបីទៅធ្វើការបំរើរដ្ឋក្តី ទៅប្រកបការងារណាមួយក្តី នឹងបានជោគជ័យក្នុងវិជ្ជាជីវៈ ព្រោះមានសមត្ថភាពគ្រប់គ្រាន់។

៤. **បដិរូបេន ទារេន សំយោជេន្តិ** ប្រែថា កូនរៀបចំកូនឱ្យមានស្វាមីភរិយាដ៏សមគួរដល់ឋានៈរបស់ខ្លួន។ ប្រពៃណីខ្មែរ ការរើសគូស្រករក៏បន្ទុកស្ថិតនៅលើមាតាបិតាជាមួយនឹងការព្រមព្រៀង ឬមិនព្រមរបស់កូនផង។ **ពាក្យថាដ៏សមគួរ** បានសេចក្តីថា ត្រូវពិនិត្យមើលចរិយាមារយាទ ចំណេះចេះដឹង ទ្រព្យសម្បត្តិ យសសក្តិរបស់កូនប្រសារឱ្យត្រូវគ្នា ឬកុំឱ្យខុសគ្នាឆ្ងាយពេកពីកូនខ្លួន ព្រោះកុំឱ្យមានការពិបាកនៅពេលក្រោយដោយសារការប្រកាន់ឋានៈគ្នា។ មាតាបិតាបំពេញក្នុងធម៌ទី៤នេះ ចំពោះតែកូនប្រុសស្រីដែលគេចង់បានស្វាមីភរិយាប៉ុណ្ណោះ។ បើកូនមិនចង់បានទេ ដូចជាកូនប្រុសចង់ទៅបួស ហើយចង់រស់នៅក្នុងភេទជាអ្នកបួសរហូត, ឯកូនស្រីចង់នៅលីវរហូត ចង់រក្សាសីលធ្វើជាដូនជី ជាសីលវតីដោយមានការនឿយណាយក្នុងជីវភាពមានគូស្រករនោះមាតាបិតាត្រូវតែធ្វើតាមបំណងរបស់កូនដោយមិនត្រូវបង្ខំកូនឱ្យមានគូស្រករឡើយ។

**៥. សមយេ ទាយជ្ជំ និយ្យាទេន្តិ** ប្រែថា ចែកទ្រព្យសម្បត្តិដល់កូនក្នុងសម័យដ៏គួរ។ មានន័យថា មាតាបិតាពុំមែនចិញ្ចឹមកូនរហូតទេ នៅពេលកូនធំពេញរូបរាងមានសមត្ថភាពអាចរកស៊ីធ្វើការដោយខ្លួនឯងបានហើយ ត្រូវផ្តល់ដើមទុនឱ្យកូនរកស៊ី។ ពាក្យខ្មែរថា កូនមានស្លាបហើរបានហើយ មាតាបិតាគ្រាន់តែជូនដំណើរ កវែកកផ្តាំងឱ្យកូនប៉ុណ្ណោះ កូនត្រូវបន្តដំណើរជីវិតដោយខ្លួនឯងតទៅទៀត។ មតិកដ៏សំខាន់ដែលមាតាបិតាចែកឱ្យកូន គឺចំណេះវិជ្ជាដែលមាតាបិតាត្រូវតែជម្រុញឱ្យកូនសិក្សារៀនសូត្រឱ្យបានកម្រិតខ្ពស់ ព្រោះនេះជាកិត្តិយសគ្រួសារ និងជាអនាគតយុវជន និងយុវនារីដ៏ល្អរបស់ជាតិ។

ក្នុងន័យនេះ ក្រសួងអប់រំខ្មែរមានភារកិច្ចចាំបាច់ណាស់ក្នុងការធ្វើកម្មវិធីសិក្សាបណ្តុះស្មារតីជាតិដល់យុវជន និងយុវនារីខ្មែរ ដោយតម្រូវឱ្យសិក្សានូវមុខវិជ្ជាចាំបាច់ ដូចជាពលរដ្ឋវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា និង ចរិយាវិជ្ជាជាដើម។

# ធម៌ដែលបុត្រធីតាប្រុសស្រីតបគុណមាតាបិតា

នៅក្នុងគម្ពីរព្រះពុទ្ធសាសនា មានគម្ពីរ**មង្គលសូត្រ**ជាដើមបាន ពោលថា ការដឹងថាមាតាបិតាមានគុណ ហៅថា**កតញ្ញូ** ហើយបានធ្វើតប ហៅថា **កតវេទី**។ គុណគឺសេចក្តីល្អរបស់មាតាបិតាមកលើកូនប្រុសស្រី គឺ នៅត្រង់គាត់ទាំងពីរមានព្រហ្មវិហារធម៌ មានមេត្តាជាដើម ហើយបញ្ចេញជា សង្គហធម៌ចិញ្ចឹមបីបាច់រក្សាឱ្យកូនរស់រានមានជីវិត ហើយបង្ហាត់បង្រៀនឱ្យ ចេះដឹង ប្រកបដោយសង្គហធម៌៥យ៉ាង មានអប់រំកូនមិនឱ្យធ្វើអំពើបាប ជាដើម ដូចបានពោលមកហើយក្នុងធម៌ ដែលមាតាបិតាសង្គ្រោះកូនប្រុសស្រី។ ចាស់បូរាណពោលថា មាតាបិតាមានគុណដ៏ធ្ងន់លើសភ្នំព្រះសុមេរុ ជ្រៅជាង មហាសមុទ្រ គឺនិយាយអំពីជម្រៅទឹកចិត្តរបស់គាត់មានមេត្តា ករុណាជាដើម ដែលមានចំពោះកូនប្រុសស្រី។ ពាក្យខ្មែរមួយបទ ពោលថា:

- *ម៉ែឪមានគុណ គុណមានទម្ងន់ ធ្ងន់ដូចប្រថពី*
  *គ្មានអ្វីនឹងសង គុណលោកទាំងពីរ មាសប៉ុនគិរី*
  *ថ្លៃពុំស្មើហោង ។*

ពាក្យខ្មែរថា **គុណឪពុក២១ គុណម្តាយ១២** នោះ ពុំមែន និយាយពីជម្រៅទឹកចិត្តមាតាបិតាទេ គឺនិយាយអំពីអាការៈសាច់ឈាមរបស់

កូនកើតពីមាតាបិតាចែកឱ្យ គឺធាតុដីមាន២០ ធាតុទឹក១២ ដែលនិយាយក្នុងអាការៈ៣២។

ធម៌៥យ៉ាងដែលកូនប្រុសស្រីត្រូវបំពេញចំពោះមាតាបិតាខ្លួនគឺ :

១. **ភរណៈ** ប្រែថា ការចិញ្ចឹមមាតាបិតា។ បានសេចក្ដីថា កាលកូននៅតូចមាតាបិតាចិញ្ចឹម លុះដល់ពេលកូនធំពេញរូបពេញរាង ចេះរកស៊ីធ្វើការខ្លួនឯងបានហើយ ត្រូវចិញ្ចឹមមាតាបិតាវិញ ជាពិសេសនៅពេលដែលគាត់មានវ័យចាស់ជរាធ្វើការពុំកើត។

២. **កិច្ចករណៈ** ប្រែថា ត្រូវធ្វើកិច្ចការជំនួស។ បានសេចក្ដីថា បើកូនរស់នៅជាមួយមាតាបិតា កូនត្រូវធ្វើការជំនួសចំពោះការងារណាដែលពិបាកហើយធ្ងន់។ បើនៅផ្ទះផ្សេងពីគាត់ កូនត្រូវឧស្សាហ៍អើតមើលមាតាបិតាឱ្យបានញឹកញាប់ ក្រែងគាត់មានបញ្ហាអ្វីមួយត្រូវជួយដោះស្រាយដោយតាំងចិត្តថានឹងរង់ចាំបំរើអ្នកមានគុណគ្រប់ពេលវេលា។ កូនមិនត្រូវឱ្យមាតាបិតាបំរើខ្លួនរហូតដល់គាត់ចាស់ជរាទេ ព្រោះវ័យនេះ ត្រូវឱ្យគាត់សម្រាកពីការងារដើម្បីទុកពេលឱ្យគាត់ធ្វើទានរក្សាសីល ចំរើនមេត្តាភាវនា ស្ដាប់លោកទេសនា។

៣. **កុលវំសំ ឋបេស្សាមិ** ប្រែថា រក្សាវង្សត្រកូល។ បានសេក្ដីថា កូនប្រុសស្រីត្រូវរក្សាវង្សត្រកូលមាតាបិតាដែលល្អ ឱ្យបានគង់វង់ កុំប្រព្រឹត្តអាក្រក់ដែលនាំឱ្យខូចតម្លៃវង្សត្រកូលរបស់មាតាបិតា។

៤. **ទាយជ្ជំ បដិបជ្ជាមិ** ប្រែថា ប្រតិបត្តិឱ្យល្អ សមទទួលមតិក។ បានសេចក្ដីថា កូនដែលសមគួរជាអ្នកទទួលមតិក គឺកូនដែលមានចរិយា

សម្បត្តិល្អ យកមតិកនោះនៅប្រើក្នុងផ្លូវត្រូវ មិនយកទៅប្រើក្នុងអំពើអបាយមុខផ្សេងៗ។

**៥. ទក្ខិណានុប្បទានំ** ប្រែថា ការធ្វើបុណ្យទក្ខិណានុប្បទាន។ បានសេចក្តីថា ពេលដែលមាតាបិតាអនិច្ចកម្មទៅ កូនប្រុសស្រីត្រូវធ្វើបុណ្យឧទ្ទិសកុសលជូនគាត់។

ការសង្គ្រោះមាតាបិតាដោយធម៌៥យ៉ាងនេះ គ្រាន់តែធ្វើឱ្យគាត់បានសុខស្រួលក្នុងជីវិតបច្ចុប្បន្នប៉ុណ្ណោះ ប៉ុន្តែជីវិតរបស់មនុស្សសត្វត្រូវវិលស្លាប់វិលកើតក្នុងសង្សារវដ្ត ទៅតាមកម្មផលល្អអាក្រក់របស់ខ្លួន។ ដូច្នេះកូនប្រុសស្រីត្រូវមានភារកិច្ចមួយទៀត ដែលត្រូវបំពេញជូនមាតាបិតា គឺត្រូវណែនាំមាតាបិតា ឬបើកូនគ្មានសមត្ថភាពទេ ត្រូវរកលោកអ្នកសប្បុរស ជួយណែនាំមាតាបិតា **ឱ្យស្ថិតនៅក្នុងសទ្ធាក្នុងសីល ក្នុងចាគៈ ក្នុងបញ្ញា**។ កុសលធម៌ទាំង៤នេះសំរាប់ជាទីពឹងរបស់មាតាបិតាក្នុងលោកខាងមុខ។ **សូម្បីព្រះពុទ្ធជាម្ចាស់** ព្រះអង្គសំដែងធម្មទេសនាប្រោស **ពុទ្ធមាតា** និង **ពុទ្ធបិតា** បង្ហាញមគ្គផលនិព្វាន ទុកជាការតបគុណរបស់ព្រះអង្គចំពោះព្រះមាតា និងព្រះបិតា។

# ភារកិច្ចរបស់មាតាបិតា និងបុត្រធីតានៅបរទេស

## ១. ភារកិច្ចមាតាបិតា ៖

ដោយព្រឹត្តិការណ៍ប្រែប្រួលនៃប្រទេសកម្ពុជា បានជំរុញឱ្យជាតិខ្មែរខ្លះ មកតាំងលំនៅឆ្ងាយពីមាតុប្រទេសរបស់ខ្លួននៅបរទេសដូចជា **សហរដ្ឋអាមេរិច កាណាដា បារាំង អូស្ត្រាលី** ជាដើម។ ដូច្នេះឪពុកម្តាយត្រូវមានភារកិច្ចថ្មីមួយទៀតក្នុងការអប់រំកូនចៅលើទឹកដីថ្មី។ ភារកិច្ចជាចម្បងគឺជំរុញកូនឱ្យខំសិក្សារៀនសូត្រឱ្យមានចំណេះចេះដឹងកម្រិតខ្ពស់ ព្រោះមរតកដែលឪពុកម្តាយចែកឱ្យកូននៅទីនេះគឺចំណេះវិជ្ជានេះឯង។ ជាមួយគ្នានឹងការជំរុញកូនឱ្យរៀន ត្រូវណែនាំអប់រំកូនឱ្យមានចរិយាល្អស្របតាមទំនៀមទម្លាប់សណ្តាប់ធ្នាប់ដ៏ល្អរបស់ជាតិខ្លួនគឺជាតិខ្មែរ។ បានសេចក្តីថា កូនចៅបានសិក្សារៀនសូត្រក្រេបជញ្ជក់យកចំណេះវិជ្ជាពីសាលារដ្ឋរបស់គេហើយ មិនត្រូវបំភ្លេចចោលវប្បធម៌របស់ជាតិខ្លួនឡើយ។ គប្បីជំរុញកូនឱ្យនិយាយភាសាខ្មែរនៅក្នុងគ្រួសារ ហើយលៃពេលឱ្យកូនរៀនអក្សរខ្មែរផង។ ពេលត្រឡប់មកពីធ្វើការវិញ ឆ្លៀតនិយាយពន្យល់កូនអំពីប្រវត្តិសាស្ត្រនិងភូមិសាស្ត្រខ្មែរ ព្រមទាំងទំនៀមទម្លាប់ដ៏ល្អរបស់ខ្មែរ ដើម្បីឱ្យកូនចៅនៅទីនោះដឹងច្បាស់និងយល់ចូលចិត្តអំពីវប្បធម៌របស់ជាតិខ្លួន។ គប្បីនាំកូនចៅទៅវត្ត ដើម្បីឱ្យព្រះសង្ឃជួយពន្យល់ណែនាំកូនអំពីតម្លៃនៃវិជ្ជាសម្បត្តិ និងចរិយាសម្បត្តិ។ វត្តពុទ្ធសាសនា

ជាមជ្ឈដ្ឋានសំខាន់សម្រាប់អប់រំកូនចៅខ្មែរតាំងពីសម័យបុរាណមកតាមមាគ៌ារបស់ព្រះពុទ្ធជាម្ចាស់ ជាមាគ៌ាដ៏ល្អបរិសុទ្ធ ដែលធ្វើឱ្យជីវិតថ្លៃថ្នូរពិសេសកូនចៅបានទទួលឱវាទអំពីព្រះសង្ឃអំពីព្រះធម៌ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលជាមូលដ្ឋាននៃវប្បធម៌ខ្មែរ ។

ក្រៅពីនិស្ស័យវាសនាកូន ដែលបានទាក់ទងនឹងបុព្វជាតិមក ម្ដាយឪពុកក៏ត្រូវតែទទួលខុសត្រូវចំពោះវាសនាកូនចៅទៅមុខទៀតដែលទាក់ទងនឹងការអប់រំ ព្រោះការអប់រំជាគោលសំខាន់កម្រិតវាសនាកូនក្នុងបច្ចុប្បន្ននេះនិងទៅអនាគត ។ ម្ដាយឪពុកណាដែលមិនចង់ឱ្យកូនចេះនិយាយខ្មែរចេះអក្សរខ្មែរនិងចេះដឹងវប្បធម៌ខ្មែរ ជាកំហុសធ្ងន់ណាស់ចំពោះកូនទៅអនាគត ដែលម្ដាយឪពុកត្រូវទទួលខុសត្រូវចំពោះការបំបាត់វប្បធម៌របស់ជាតិខ្លួននេះ ។ នៅប្រទេសភូមា ប្រទេសស្រីលង្កា និងប្រទេសថៃ រៀងរាល់ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ម្ដាយឪពុកបាននាំកូនចៅមកកាន់វត្ត ដើម្បីឱ្យព្រះសង្ឃអប់រំសីលធម៌ព្រះពុទ្ធសាសនាមានឱ្យសមាទានសីល៥ រហូតបង្ហាត់ឱ្យអង្គុយសមាធិទៀតផង ។ ផ្ទុយទៅវិញម្ដាយឪពុកខ្មែរខ្លះនៅបរទេស នៅថ្ងៃសៅរ៍និងថ្ងៃអាទិត្យបែរជានាំកូនចៅដើរលេងនិងទុកឱកាសឱ្យសាសនាដទៃមកបញ្ចុះបញ្ចូលឱ្យទៅកាន់សាសនាគេ ។ នៅពេលដែលកូនដើរផ្លូវខុស មិនស្ដាប់ដំបូន្មានខ្លួនអំពីរឿងគូស្រករ ដោយសារតែទទួលវប្បធម៌របស់បរទេស មិនធ្វើតាមទំនៀមទម្លាប់ខ្លួន ទើបម្ដាយឪពុកខ្លះនឹកស្ដាយក្រោយ ប៉ុន្តែវាហួសពេលទៅហើយ ។

**២~ ភារកិច្ចកូនប្រុសស្រី :**

តាមធម្មតាកូនប្រុសស្រី នៅក្នុងបឋមវ័យ គឺជាវ័យនៅក្មេងម្ដាយឪពុកឬអាណាព្យាបាលតែងតែបញ្ជូនឱ្យទៅសិក្សា។ ភារកិច្ចកូនដែលជាសិស្សគឺការខំប្រឹងប្រែងសិក្សារៀនសូត្រ និងធ្វើកិច្ចការដែលគ្រូដាក់ឱ្យ។ ក្រៅពីនេះកូនប្រុសស្រីត្រូវមានចរិយាមារយាទថ្លៃថ្នូរ កុំរត់ចោលសាលា ត្រូវរៀនឱ្យមានវិជ្ជាខ្ពង់ខ្ពស់ កុំដើរលេងសប្បាយរហូតភ្លេចការសិក្សា។ កូនប្រុសស្រីមានភ័ព្វសំណាងណាស់ ដែលបានមកនៅប្រទេសដែលសម្បូរការសិក្សា ដូច្នេះកុំឱ្យពេលកន្លងទៅដោយពុំមានការសិក្សាត្រូវដើរឱ្យទាន់ការលូតលាស់នៃពិភពលោក ព្រោះវិជ្ជានិងចរិយាល្អជាសម្បត្តិរបស់មនុស្ស។ ថ្ងៃក្រោយបើកូនចៅប្រុសស្រីមានបំណងចង់ទៅកសាងមាតុប្រទេសវិញ ក៏មានលទ្ធភាពជួយបានព្រោះមានសមត្ថភាពគ្រប់គ្រាន់។ ប្រទេសកម្ពុជាពីដើម ការអប់រំកូនចៅមានការងាយស្រួលជាងនៅបរទេស ព្រោះជាប្រទេសកំណើតរបស់ខ្លួន ហើយរដ្ឋាភិបាលក៏ជារដ្ឋាភិបាលខ្មែរ ឯកម្មវិធីសិក្សានៅក្នុងសាលាក៏តម្រូវទៅតាមប្រពៃណីទំនៀមទម្លាប់ខ្មែរនិងស្របតាមមុខវិជ្ជាទូទៅដែលគ្រប់ប្រទេសក្នុងពិភពលោកលើកយកមកសិក្សា។ កូនខ្មែរសិក្សាជាច្រើនម៉ោងនៅក្នុងសាលារដ្ឋគេ លុះត្រឡប់មកផ្ទះវិញ ម្ដាយឪពុកពុំសូវមានពេលទំនេរពន្យល់កូនចៅអំពីវប្បធម៌របស់ជាតិខ្លួនឡើយ ព្រោះរវល់ធ្វើការ។ ដូច្នេះកូនចៅខ្មែរបានទទួលវប្បធម៌ពីរ គឺវប្បធម៌ជាតិខ្លួនផង និងវប្បធម៌របស់ប្រទេសដែលខ្លួនស្នាក់នៅផង ថ្ងៃក្រោយអាចមានទំនាស់ជាមួយឪពុកម្ដាយអំពីទស្សនៈនិង

ការអនុវត្តខុសគ្នានេះ។ កូនចៅប្រុសស្រីគប្បីគិតថា ម្តាយឪពុកខ្លះទោះបីគាត់មានចំណេះវិជ្ជាតិចតួចជាងកូនសម័យនេះក៏ដោយ ក៏គាត់មានការពិសោធច្រើនក្នុងបញ្ហាជីវិតដែរ ដូច្នេះកូនប្រុសស្រីត្រូវយកយោបល់គាត់មកពិចារណាផ្សំនឹងចំណេះវិជ្ជារបស់ខ្លួនដែលបានសិក្សាផង ដើម្បីឱ្យផែនការជីវិតប្រព្រឹត្តទៅបានសុខចំរើន។ ច្បាប់នៅសហរដ្ឋអាមេរិក និងប្រទេសកាណាដា កូនប្រុសស្រីដែលមានអាយុ១៨ឆ្នាំឡើងទៅ អាចរើសគូស្រករដោយខ្លួនឯងបាន ឯទំនៀមទម្លាប់ខ្មែរទោះបីកូនប្រុសស្រីមានអាយុលើសពី១៨ក៏ដោយ ការសម្រេចឱ្យមានគូស្រករ ក៏បន្ទុកនៅលើឪពុកម្តាយរួមជាមួយយោបល់ផ្ទាល់របស់កូនផង។ ដូច្នេះកូនប្រុសស្រីខ្មែរនៅបរទេស គួរសិក្សាប្រពៃណីនេះដោយសម្របសម្រួលបញ្ហារើសគូស្រករនេះជាមួយឪពុកម្តាយ កុំសម្រេចតាមទំនើងចិត្តខ្លួនឯង។ ម្តាយឪពុកក៏គួរស្តាប់ពាក្យកូនដែលមានយោបល់ល្អ ឯកូនប្រុសស្រីក៏គប្បីស្តាប់បង្គាប់គាត់ បើគាត់ណែនាំទៅរកផ្លូវល្អហើយ។ ម្តាយឪពុកជាអ្នកមានគុណ កូនមិនត្រូវមានគំនិតថា ខ្លួនមានចំណេះវិជ្ជាសម័យថ្មី ហើយមើលងាយឪពុកម្តាយរបស់ខ្លួនឡើយ ព្រោះវិជ្ជាថ្មីក៏កើតពីគំនិតចាស់ដែលបានត្រួសត្រាយផ្លូវដែរ។ កូនដែលស្ថិតក្នុងបឋមវ័យកំពុងសិក្សា ពុំទាន់មានការពិសោធនៅក្នុងបញ្ហាជីវិតនៅឡើយ បើមានបញ្ហាណាមួយកើតឡើង គប្បីយកបញ្ហានោះពិគ្រោះជាមួយនឹងឪពុកម្តាយ ដើម្បីជៀសវាងការវិនិច្ឆ័យខុស។ មួយទៀត ការប្រើមនោសញ្ចេតនាតាមយុវវ័យ ឆាប់អរឆាប់សប្បាយ ឆាប់រំភើបឆាប់ខឹង ក៏នាំឱ្យវិនិច្ឆ័យនិងសម្រេចចិត្តខុសដែរ។ កុំអាលបន្ទោស

មនុស្សជំនាន់ចាស់ៗថាធ្វើខុសដោយពុំបានប្រមូលហេតុផលនិងភ័ស្តុតាងច្បាស់លាស់ ព្រោះជួនកាលសិស្សនិងនិស្សិតចេះវិជ្ជាតាមតែសៀវភៅ តាមតែទ្រឹស្តីមើលឃើញការងារនោះងាយ លុះដល់អនុវត្តទើបដឹងច្បាស់ថា ការងារនោះពិបាកហើយជួនកាលអនុវត្តពុំកើតផង មានការងារខ្លះអនុវត្តពុំកើតត្រូវតែកែទ្រឹស្តីវិញផង។ ម្យ៉ាងទៀត សិស្សនិងនិស្សិតដែលបានសិក្សាវិជ្ជាបរទេសមុននឹងយកអនុវត្តនៅប្រទេសខ្មែរ ចាំបាច់ត្រូវតែសិក្សាលក្ខណៈខ្មែរឱ្យយល់ច្បាស់លាស់ជាមុនសិន ទើបអាចច្នៃវិជ្ជាដែលបានសិក្សានោះឱ្យមានលក្ខណៈជាខ្មែរ ព្រោះមានវិជ្ជាខ្លះអាចអនុវត្តបានជោគជ័យតែកន្លែងមួយពុំបានជោគជ័យនៅកន្លែងមួយទៀតក៏មាន។ ត្រូវសិក្សាថា ប្រទេសកម្ពុជាមានទឹកដីធាតុអាកាសនិងទឹកចិត្តខ្មែរមានលក្ខណៈបែបណាដែលអាចយកវិជ្ជានោះទៅអនុវត្តបានជោគជ័យ។ ដូចជាការយកលទ្ធិកុម្មុយនីស្តខ្មែរក្រហមទៅអនុវត្តនៅប្រទេសកម្ពុជាកន្លងទៅនេះដែលជាលទ្ធិផ្ទុយពីទឹកចិត្តខ្មែរ បានធ្វើឱ្យប្រទេសកម្ពុជាវិនាសអន្តរាយ។ ទីបំផុតនេះ សូមអំពាវនាវព្រះអង្គចៅអធិការគ្រប់វត្តនៅបរទេស ដូចនៅសហរដ្ឋអាមេរិក កាណាដា បារាំង និងអូស្ត្រាលីជាដើម សូមចាត់ចែងឱ្យមានបង្រៀនអក្សរខ្មែរនិងសីលធម៌ព្រះពុទ្ធសាសនាដល់កូនចៅគ្រប់វត្ត ដើម្បីចូលរួមវិភាគទានក្នុងការរក្សាប្រពៃណី និងវប្បធម៌ខ្មែរឱ្យបានគង់វង់ ហើយឱ្យវប្បធម៌ទាំងនោះស្ថិតនៅក្នុងសន្តានចិត្តនៃកូនចៅខ្មែរគ្រប់គ្នានៅបរទេស។ សប្បុរសរបស់ព្រះសង្ឃក្នុងការជួយអប់រំកូនចៅខ្មែរចាត់ទុកថា ជាវិភាគទានដ៏ឧត្តុង្គឧត្តមមិនអាចកាត់ថ្លៃបាន។ ចំណែកម្តាយ

ឪពុកឬអាណាព្យាបាលរបស់កូនចៅខ្មែរគួរយកចិត្តទុកដាក់ធ្វើសហការជាមួយព្រះសង្ឃ ដោយបញ្ជូនកូនចៅឱ្យទៅសិក្សាអក្សរខ្មែរ និងសីលធម៌ព្រះពុទ្ធសាសនានៅទីវត្ត តាមកម្មវិធីរបស់វត្តនីមួយៗ។ សង្ឃឹមថា ព្រះសង្ឃនិងជនជាតិខ្មែរនៅបរទេសមិនបំភ្លេចចោលនូវសេចក្តីអំពាវនាវនេះឡើយ។

# ពុទ្ធមណ្ឌលកម្ពុជា

បើគេធ្វើដំណើរតាមផ្លូវជាតិលេខ១ ពីស្ពានមុនីវង្សទៅស្ពានអ្នកលឿងបានចម្ងាយជាង២០គីឡូម៉ែតបត់ស្តាំ គេនឹងឃើញពុទ្ធមណ្ឌលកម្ពុជា ដែលស្ថិតក្នុងឃុំជីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ប្រទេសកម្ពុជា។ ពួកទេសចរទាំងក្នុង និងក្រៅប្រទេសបានធ្វើទស្សនកិច្ចជារៀងរាល់ថ្ងៃ ជាពិសេសនៅថ្ងៃសៅរ៍និងថ្ងៃអាទិត្យមានចំនួនអ្នកទេសចរច្រើន ដើម្បីទៅនមស្ការបូជនីយដ្ឋាននានាដែលកសាងនៅក្នុងពុទ្ធមណ្ឌលនោះ។ បូជនីយដ្ឋានដ៏សំខាន់៤កន្លែងគឺ ប្រសូត ត្រាស់ដឹង សំដែងធម្មចក្រ និងបរិនិព្វាន។ ក្រៅពីបូជនីយដ្ឋាន៤កន្លែងនេះ មានសំណង់ផ្សេងៗទៀតគឺ ព្រះពុទ្ធប្រទានពរ ព្រះពុទ្ធទ្រង់បាត្រ ឧបដ្ឋានសាលា អាស្រមសមាធិ សាលាធម្មវិន័យ សាលាសំណាក់ជាដើម។ គេឃើញស្រះទឹកជាច្រើនដែលលំអដោយដើមផ្កាព័ទ្ធជុំវិញ និងដើមឫស្សីដុះជាជួរ ធ្វើជាផ្លូវដែលមានមែកកោងរកគ្នាធ្វើជាដំបូលផ្លូវដែលជារមនីយដ្ឋានគួរីករាយចិត្ត។

នៅជិតឧបដ្ឋានសាលាមានដើមត្នោតមួយដើម ចម្លែកអស្ចារ្យ គឺមានមែក៨ដុះឡើងស្មើគ្នាបែកចេញទៅទិសទាំង៨ ដែលអ្នកប្រាជ្ញពុទ្ធសាសនាថាជាតំណាងអដ្ឋង្គិកមគ្គ គឺមង្គប្រកបដោយអង្គ៨ជាផ្លូវប្រតិបត្តិ ដើម្បីមគ្គផលនិព្វានក្នុងការចេញចាកទុក្ខមានជាតិទុក្ខជាដើម។ បាតុភូតអស្ចារ្យនេះ កើតឡើងគួរនឹកដល់ពាក្យចាស់ខ្មែរដែលខ្លះថាជាពុទ្ធទំនាយថា កាលណាកោះស្លា

កែតផុសប្រាសាទមាសប្រាសាទប្រាក់ហើយ ប្រទេសយើងនឹងបានសុខសប្បាយ។ កោះស្លាកែតគឺស្ថិតនៅម្តុំនេះឯង។ ពុទ្ធមណ្ឌលនេះដែលមានទំហំដីជាង១០០ហិកតា កំពុងផុសឡើងនូវបូជនីយដ្ឋាននានាតាមពុទ្ធប្រវត្តិតាមរចនាបថខ្មែរជាបន្តបន្ទាប់គ្នា។ ប្រទេសកម្ពុជាជាប្រទេសគោរពព្រះពុទ្ធសាសនា២០០០ឆ្នាំមកហើយ ដែលសព្វថ្ងៃនេះ មានវត្តចំនួនបួនពាន់ និងព្រះសង្ឃមានប្រាំមួយម៉ឺនអង្គ ។

ដូច្នេះការបង្កើតឱ្យមានពុទ្ធមណ្ឌលជាចាំបាច់បំផុត ជាតំណាងវត្តទាំងបួនពាន់ ព្រោះមានពុទ្ធមណ្ឌលទំហំដ៏ធំ ជាខ្នាតអន្តរជាតិ សម្រាប់ស្ថាបនាបូជ-នីយដ្ឋាននានារបស់ព្រះពុទ្ធ និងអាគារផ្សេងៗសម្រាប់បង្រៀនធម៌ និងអប់រំចិត្ត។ នៅប្រទេសកម្ពុជាមានប្រាសាទរាប់ពាន់ ប៉ុន្តែពុំមែនជាបូជនីយដ្ឋានរបស់ពុទ្ធសាសនាឡើយ ភាគច្រើនសង់ដើម្បីឧទ្ទិសចំពោះព្រះអាទិទេពក្នុងសាសនាព្រាហ្មណ៍។ ចំណែក ព្រះពុទ្ធសាសនា**ថេរវាទ**ដូចប្រទេសថៃ ភូមាស្រីលង្កា និងប្រទេសនេប៉ាល់ជាដើម មានពុទ្ធមណ្ឌលជាខ្នាតអន្តរជាតិជាយូរមកហើយ។ ភាពក្រីក្រនៃប្រជាពលរដ្ឋខ្មែរនិងការកើនឡើងនៃអំពើហិង្សាគ្រប់យ៉ាងមកអំពីការធ្លាក់ចុះនៃសីលធម៌។ ដូច្នេះការស្ថាបនានូវពុទ្ធមណ្ឌលនេះឡើងស្របតាម **កាលៈទេសៈ** ឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋខ្មែរ ដែលទុកជាមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្សក្នុងការសិក្សារៀនសូត្រ បណ្តុះបញ្ញាស្មារតីឱ្យមានសីលធម៌ឡើងវិញ។ អ្នកដែល

បង្កើតពុទ្ធមណ្ឌលនេះ គឺកើតឡើងពីព្រះសង្ឃ និងពុទ្ធបរិស័ទខ្មែរនៅក្នុងនិងក្រៅប្រទេស។ បច្ច័យជាវដីជាង១០០ហិកតា កើតឡើងពីពុទ្ធខ្មែរនៅក្រៅប្រទេស។ ចំណែក បូជនីយដ្ឋានទាំងបួនកន្លែងគឺកន្លែងប្រសូត្រ ទទួលកសាងដោយព្រះសង្ឃនិងពុទ្ធនៅប្រទេសអូស្ត្រាលី ដែលដឹកនាំដោយព្រះអង្គ **ស្រី-សុវណ្ណ** និងព្រះអង្គ **នន្ទ-សុទេព**។ កន្លែងត្រាស់ដឹងកសាងដោយព្រះសង្ឃនិងពុទ្ធបរិស័ទនៅប្រទេសបារាំង ដែលដឹងនាំដោយព្រះអង្គ **ចិត្តភាវោ ទូច-សារិទ្ធិ**។ កន្លែងសំដែងធម្មចក្រកសាងដោយព្រះសង្ឃ និងពុទ្ធនៅសហរដ្ឋអាវិក ដឹកនាំដោយព្រះតេជគុណ **វឌ្ឍិតធម្មោ គង់-សុផាន**។ កន្លែងបរិនិព្វានកសាដោយព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរនៅប្រទេសកាណាដា ដែលដឹកនាំដោយលោក **ឧកញ៉ា យិត-ឆេង**។ សាលាធម្មវិន័យកសាងដោយព្រះសង្ឃនិងពុទ្ធស័ទខ្មែរនៅសហរដ្ឋអាមេរិកដែលដឹកនាំដោយព្រះតេជគុណ **ឃុន-ហួន**។ មានពុទ្ធបរិស័ទកសាងសំណង់ផ្សេងៗទៀត ប៉ុន្តែមិនបានរៀបរាប់នៅទីនេះ។ ក្រុមអភិបាលនៃសមាគម ធម្មទូត គឺ **សម្តេចមហាឃោសនន្ទ** ព្រះតេជគុណ **សួស-គូ** ព្រះអង្គ **យស-ហ៊ុត** ព្រះអង្គបណ្ឌិត **ហុក-សាវណ្ណ** និងព្រះអង្គ **ទូច-សារិទ្ធិ** ដឹកនាំកសាងពុទ្ធមណ្ឌលនេះ ។ ព្រះអង្គ **ទូច-សារិទ្ធី** ជាប្រធានគណកម្មការប្រតិបត្តិជាអ្នកចាត់ចែងដោយផ្ទាល់នៅទីកន្លែង។ ចំណែកព្រះតេជគុណបណ្ឌិត **ហុក-សុវណ្ណ** ជាអ្នកផ្តើមគំនិត ហើយជាអ្នកចាត់ការទូទៅដូចជាធ្វើប្លង់ និងទំនាក់ទំនងសាធារណៈជាដើម។ សំណង់ដែលត្រូវស្ថាបនាបន្តទៅទៀត គឺផ្លូវចូលពីផ្នែកខាងជើងនៃពុទ្ធមណ្ឌល និងស្ពានឆ្លង

ស្ទឹង ព្រមទាំងក្លោងទ្វារចូលពីផ្លូវជាតិលេខ១ ព្រះវិហារ មណ្ឌលវិបស្សនា សាក្យមុនីចេតិយ៍ដំកល់ព្រះសារីរិកធាតុនៃព្រះពុទ្ធ បណ្ណាល័យតម្កល់គម្ពីរក្បួនច្បាប់នៃពុទ្ធសាសនា និងសៀវភៅវប្បធម៌ ប្រវត្តិសាស្ត្រខ្មែរ សារមន្ទីរសម្រាប់តម្កល់ វត្ថុបុរាណខ្មែរ កសាងព្រះពុទ្ធរូបដ៏ធំមួយអង្គ កសាងកំពែងព័ទ្ធជុំវិញពុទ្ធមណ្ឌល កសាងស្ថានីវិទ្យុផ្សាយសម្លេងជាដើម ។

ក្នុងពុទ្ធមណ្ឌលនេះ ចែកចេញជាពីរផ្នែក គឺមួយផ្នែកកសាងបូជនីយ-ដ្ឋាននានារបស់ព្រះពុទ្ធ និងមួយផ្នែកទៀត កសាងសំណង់ផ្សេងៗដូចជាសាលាធម្មវិន័យ មណ្ឌលវិបស្សនាជាដើម សម្រាប់សិក្សារៀនសូត្រនិងអប់រំចិត្ត។ និមន្តព្រះសង្ឃដែលមានចំណេះដឹងពីពុទ្ធិកសិក្សា និងពីសាលាធម្មវិន័យមកអប់រំបន្ថែមផ្នែកគរុកោសល្យឱ្យទៅជាសមណទូតបញ្ជូនទៅទេសនាពន្យល់ពុទ្ធបរិស័ទខ្មែរ នៅតាមខេត្ត និងក្រុងនៃប្រទេសកម្ពុជា។ មួយផ្នែកទៀត និមន្តព្រះគ្រូចៅអធិការ និងអាចារ្យវត្តគ្រប់វត្តទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល មួយក្រុមម្តងមកធ្វើសិក្ខាសាលា ដើម្បីពង្រឹងសមត្ថភាពលោកគ្រូចៅអធិការនិងអាចារ្យវត្តទាំងនោះ ឱ្យបំពេញកិច្ចការឱ្យពេញលេញស្របតាមមុខងារ ។

ក្រៅពីការសិក្សារៀនសូត្រធម៌វិន័យ និងប្រតិបត្តិឱ្យបានល្អស្របតាមសមណភេទមក លោកគ្រូចៅអធិការនិងព្រះសង្ឃដទៃទៀតគួរពន្យល់ពុទ្ធបរិស័ទខ្មែរជើងវត្តឱ្យយល់តម្លៃគុណធម៌មានសីលធម៌ជាដើមឱ្យបានយល់

ច្បាស់លាស់ និងជួយផ្នែកសង្គមកិច្ចនិងវប្បធម៌ ដូចជាពន្យល់កូនចៅឱ្យខំរៀនសូត្រកុំដើរលេងប្រព្រឹត្តអបាយមុខផ្សេងៗ ដូចជាល្បែងស្រី ជក់គ្រឿងញៀនជាដើម។ ចំណែកឪពុកម្តាយត្រូវខំប្រឹងប្រែងរកស៊ីធ្វើការងារប្រកបដោយធម៌សុចរិត។ ព្រះសង្ឃក៏អាចដឹកនាំកសាងសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ជាដើម ដូចសម័យមុនមិនទាស់ខុសនឹងព្រះវិន័យព្រះពុទ្ធសាសនាឡើយ។ សូមជនជាតិខ្មែរទាំងក្នុងនិងក្រៅប្រទេសជួយរួមវិភាគទានកសាងពុទ្ធមណ្ឌលកម្ពុជានេះតទៅទៀត ឱ្យបានសម្រេចជាស្ថាពរទុកជាសម្បត្តិពុទ្ធសាសនាដែលជាស្ថាប័នដ៏ធំរបស់ប្រទេសកម្ពុជា។

# នាមអ្នកបរិច្ចាគបច្ច័យបោះពុម្ព

ឧបាសក **ឡូ ប៊ុនឡេង** និង ឧបាសិកា **អៀប ផៃគីម**

១. ឧបាសក **ឡូ ប៊ុនឡេង** និង ឧបាសិកា **អៀប ផៃគីម**
ព្រមទាំងកូនចៅ $៥០០

២. ឧបាសិកា **សោ អ៊ុំវគន** $៥០០

សៀវភៅនេះចែកជាធម្មទាន ទូរស័ព្ទទំនាក់ទំនងៈ

ក. ព្រះភិក្ខុ **ទិបុល** ០១១ ២២៥ ៥៤៧ និង
០១២ ៣១២ ៩០៨

ខ. ឧបាសិកា **សាមឿន** ០១២ ២២១ ៥០៥

---

វិភាគដោយព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណា**